# គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត
# ស្តីពី
# អភិបាលកិច្ចប្រកបដោយ
# ការទទួលខុសត្រូវលើការកាន់កាប់
# ដី ជលផល និង ព្រៃឈើ
# ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ



CFS
Committee on
World Food
Security

FAO
FIAT PANIS

គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពី

# អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់

## ដី ជលផល និង ព្រៃឈើ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ
ទីក្រុងរ៉ូម ឆ្នាំ ២០១២

ការរចនាម៉ូដទាំងឡាយ និង ការបង្ហាញឯកសារនៅក្នុងផលិតផលព័ត៌មាននេះ មិនបានឆ្លុះបញ្ចាំងពីទស្សនៈណាមួយរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ដែលពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់ ឬស្ថានភាពអភិវឌ្ឍន៍របស់ប្រទេស ដែនដី ទីក្រុង ឬ តំបន់ ឬ អាជ្ញាធរនៃប្រទេស ណាមួយនោះទេ ឬ ពាក់ព័ន្ធនឹងការកំណត់ព្រំដែន ឬ ព្រំប្រទល់របស់ប្រទេស នោះឡើយ។ ការលើកឡើងអំពីក្រុមហ៊ុន ឬ ផលិតផលរបស់ម្ចាស់ផលិតផលជាក់លាក់ណាមួយ ទោះបីជាក្រុមហ៊ុន ឬផលិតផលទាំងនេះមាន ឬ គ្មានប៉ាតង់ក្តី មិនបានបង្ហាញថាក្រុមហ៊ុន ឬ ផលិតផលទាំងនេះត្រូវបានអនុម័ត ឬណែនាំដោយអង្គការ FAO ក្នុងន័យពេញចិត្តជាងនឹងក្រុមហ៊ុន ឬ ផលិតផលស្រដៀងគ្នាដទៃទៀតដែលមិនត្រូវបានលើកឡើងនោះទេ។

ISBN ៩៧៨-៩២-៥-១០៧២៧៧-៦

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ អង្គការ FAO លើកទឹកចិត្តដល់ការចម្លង និងផ្សព្វផ្សាយឯកសារនៅក្នុងផលិតផលព័ត៌មាននេះ។ ការប្រើប្រាស់មិនមែនដើម្បីគោលបំណងពាណិជ្ជកម្ម នឹងត្រូវបានអនុញ្ញាតដោយឥតគិតថ្លៃតាមការស្នើសុំ។ ការចម្លងសម្រាប់លក់ ឬ សម្រាប់គោលបំណងពាណិជ្ជកម្មផ្សេងទៀត រួមទាំងគោលបំណងអប់រំ អាចតម្រូវឱ្យបង់ថ្លៃ។ ការសុំការអនុញ្ញាតដើម្បីចម្លង ឬ ផ្សព្វផ្សាយឯកសាររក្សាសិទ្ធិរបស់ FAO និងរាល់ការសាកសួរអំពីសិទ្ធិ និង អាជ្ញាប័ណ្ណ គប្បីផ្ញើតាមអ៊ីម៉េលទៅកាន់ copyright@fao.org ឬ ផ្ញើជូនប្រធានផ្នែកបោះពុម្ពផ្សាយ គោលនយោបាយ និងគាំទ្រ នៃការិយាល័យផ្លាស់ប្តូរចំណេះដឹង ស្រាវជ្រាវ និងផ្សព្វផ្សាយ នៃអង្គការ FAO, Viale delle Terme di Caracalla, ០០១៥៣ ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី។

© FAO ២០១២

# មាតិកា

អារម្ភកថា........................................................................................................ vi

១. បុព្វកថា........................................................................................................1

១. គោលបំណង ........................................................................................................1

២ . ប្រភេទ និង វិសាលភាព ........................................................................................................2

២. ទិដ្ឋភាពទូទៅ ........................................................................................................4

៣ . គោលការណ៍ណែនាំនៃអភិបាលកិច្ចលើការកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ............4

៣ក គោលការណ៍ទូទៅ ........................................................................................................4

៣ខ គោលការណ៍អនុវត្ត........................................................................................................6

៤ . សិទ្ធិនិងការទទួលខុសត្រូវទាក់ទិននឹងការកាន់កាប់........................................................7

៥ . ក្របខណ្ឌគោលនយោបាយ គតិយុត្តិ និង ស្ថាប័ន ទាក់ទិននឹងការកាន់កាប់......................10

៦ . ការផ្តល់សេវា ........................................................................................................11

៣. ការទទួលស្គាល់ស្របច្បាប់ និង ការបែងចែកសិទ្ធិកាន់កាប់ និង ភារកិច្ចនានា.....14

៧. វិធានការការពារ ........................................................................................................14

៨ . ដីសាធារណៈ ជលផល និង ព្រៃឈើ ........................................................................16

៩ . ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី .....18

១០. ការកាន់កាប់ក្រៅប្រព័ន្ធ........................................................................................21

## ៤. ការផ្ទេរនិងការផ្លាស់ប្តូរផ្សេងទៀតនៃសិទ្ធិកាន់កាប់ និង កាតព្វកិច្ចនានា ................ 23

១១ . ទីផ្សារ ................ 23

១២ . ការវិនិយោគ ................ 25

១៣ . ការប្រមូលផ្តុំដី និង អភិក្រមកែតម្រូវឡើងវិញផ្សេងទៀត ................ 28

១៤ . បដិទាន ................ 30

១៥ . កំណែទម្រង់បែងចែកឡើងវិញ ................ 31

១៦ . អស្សាមិករណ៍និងសំណង ................ 33

## ៥. រដ្ឋបាលនៃការកាន់កាប់ ................ 36

១៧ . ការចុះបញ្ជីសិទ្ធិកាន់កាប់ ................ 36

១៨. ការកំណត់តម្លៃ ................ 38

១៩. ការយកពន្ធ ................ 39

២០. ការធ្វើផែនការរៀបចំដែនដីដោយនិយតកម្ម ................ 39

២១ . ដំណោះស្រាយវិវាទលើសិទ្ធិកាន់កាប់ ................ 40

២២ . បញ្ហាឆ្លងដែន ................ 41

## ៦. ចម្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ និង គ្រោះបន្ទាន់ ................ 43

២៣. បម្រែបម្រួលអាកាសធាតុ ................ 43

២៤ . គ្រោះមហន្តរាយធម្មជាតិ ................ 44

២៥. វិវាទទាក់ទិននឹងការកាន់កាប់ដី ជលផល និង ព្រៃឈើ ................ 45

## ៧. ការជំរុញ ការ **អនុវត្តន៍** ការតាមដាន និង ការវាយតម្លៃ ................ 48

# អារម្ភកថា

គោលបំណងនៃគោលការណ៍ណែនាំដោយស្ម័គ្រចិត្តទាំងនេះ គឺសំដៅបំពេញមុខងារជាឯកសារយោង និង ដើម្បីផ្តល់ការណែនាំ ដើម្បីកែលម្អអភិបាលកិច្ចលើការកាន់កាប់ដី ជលផល និង ព្រៃឈើ ដោយមាន គោលដៅរួម សំដៅសម្រេចឱ្យបាននូវសន្តិសុខស្បៀងសម្រាប់មនុស្សគ្រប់រូប និងដើម្បីគាំទ្រដល់ការសម្រេច បានជាលំដាប់នូវសិទ្ធិមានស្បៀងគ្រប់គ្រាន់ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ។

គោលការណ៍ណែនាំទាំងនេះ មានបំណងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងជាសកល និង ថ្នាក់ជាតិ សំដៅ លុបបំបាត់ភាពអត់ឃ្លាន និង ភាពក្រីក្រ ដោយផ្អែកលើគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការទទួលស្គាល់អំពីសារៈសំខាន់នៃដីចំពោះការអភិវឌ្ឍ តាមរយៈការលើកកម្ពស់សិទ្ធិកាន់កាប់ និង លទ្ធភាពប្រើប្រាស់ដី ជលផល និង ព្រៃឈើប្រកបដោយសមធម៌។

ការលុបបំបាត់ភាពអត់ឃ្លាន និងភាពក្រីក្រ និង ការប្រើប្រាស់បរិស្ថានប្រកបដោយនិរន្តរភាព ពឹងផ្អែកយ៉ាង ច្រើនលើរបៀបដែលប្រជាជន សហគមន៍ និង អ្នកដទៃទៀត ទទួលបានលទ្ធភាពប្រើប្រាស់ដី ជលផល និង ព្រៃឈើ។ ជីវភាពរបស់ប្រជាពលរដ្ឋជាច្រើន ជាពិសេស ប្រជាពលរដ្ឋជនបទ ពឹងអាស្រ័យលើលទ្ធភាព ប្រើប្រាស់ និង គ្រប់គ្រងលើធនធានទាំងនេះប្រកបដោយសុវត្ថិភាព និង សមធម៌។ ធនធានទាំងនេះ គឺជា ប្រភពនៃស្បៀងអាហារ និងជម្រក ជាមូលដ្ឋានសម្រាប់ការអនុវត្តនៅក្នុងសង្គម វប្បធម៌ និង សាសនា និង ជាកត្តាចម្បងនៅក្នុងកំណើនសេដ្ឋកិច្ច។

ចាំបាច់ត្រូវកត់សម្គាល់ថា អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និង ព្រៃឈើ ត្រូវបានផ្សារភ្ជាប់យ៉ាងស្អិតរមួតទៅនឹងការគ្រប់គ្រងធនធានធម្មជាតិផ្សេងទៀត ដូចជាធនធានទឹក និងធនធានរ៉ែជាដើម។ ទន្ទឹមនឹងមានការទទួលស្គាល់អំពីវត្តមាននៃម៉ូដែល និងប្រព័ន្ធខុសៗគ្នានៃ អភិបាលកិច្ចលើធនធានធម្មជាតិទាំងនេះក្នុងបរិបទជាតិ រដ្ឋអាចមានឆន្ទៈគិតគូរពីអភិបាលកិច្ចលើធនធាន ធម្មជាតិដែលពាក់ព័ន្ធ ក្នុងការ អនុវត្តន៍គោលការណ៍ណែនាំទាំងនេះ ទៅតាមភាពសមស្រប។

របៀបដែលប្រជាពលរដ្ឋ សហគមន៍ និង អ្នកដទៃទៀត ទទួលបានលទ្ធភាពប្រើប្រាស់ដី ជលផល និង ព្រៃឈើ ត្រូវបានសង្គមកំណត់ និងធ្វើនិយតកម្ម តាមរយៈប្រព័ន្ធកាន់កាប់។ ប្រព័ន្ធកាន់កាប់ទាំងនេះកំណត់ថាតើអ្នកណាអាចប្រើប្រាស់ធនធានអ្វី សម្រាប់រយៈពេលប៉ុន្មាន និង ក្រោមលក្ខខណ្ឌណាខ្លះ។ ប្រព័ន្ធទាំងនេះអាចមានមូលដ្ឋានផ្អែកលើគោលនយោបាយ និងច្បាប់ដែលធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងទំនៀមទម្លាប់ និង អនុវត្តន៍ដែលមិនមានជាលាយលក្ខណ៍អក្សរផងដែរ។

ប្រព័ន្ធកាន់កាប់កំពុងតែជួបប្រទះភាពតានតឹង ដោយសារកំណើនប្រជាជនពិភពលោកដែលទាមទារឱ្យមានសន្តិសុខស្បៀង និង ដោយសារភាពវិចរិលនៃបរិស្ថាន និង ការប្រែប្រួលអាកាសធាតុ បានកាត់បន្ថយការមានដី ជលផល និង ព្រៃឈើ។ សិទ្ធិកាន់កាប់មិនគ្រប់គ្រាន់ និងគ្មានសុវត្ថិភាព បង្កើនភាពងាយរងគ្រោះភាពអត់ឃ្លាន និង ភាពក្រីក្រ ហើយអាចនាំឱ្យមានវិវាទ និង ការខូចខាតបរិស្ថាន នៅពេលដែលអ្នកប្រើប្រាស់ប្រជែង ដណ្តើមគ្នាដើម្បីគ្រប់គ្រងធនធានទាំងនេះ។

អភិបាលកិច្ចលើការកាន់កាប់ គឺជាធាតុដ៏សំខាន់មួយក្នុងការកំណត់ថាតើប្រជាជន សហគមន៍ និង អ្នកដទៃទៀតអាចទទួលបានសិទ្ធិ និងកាតព្វកិច្ចពាក់ព័ន្ធ តាមរបៀបណា ដើម្បីប្រើប្រាស់ និងគ្រប់គ្រងដី ជលផល និង ព្រៃឈើ។ បញ្ហាកាន់កាប់ជាច្រើនកើតឡើងដោយសារអភិបាលកិច្ចទន់ខ្សោយ ហើយរាល់ការប៉ុនប៉ងដោះស្រាយបញ្ហាកាន់កាប់នេះត្រូវទទួលរងផលប៉ះពាល់ពីគុណភាពនៃអភិបាលកិច្ចនេះវិញ។ អភិបាលកិច្ចទន់ខ្សោយ នាំឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើស្ថេរភាពសង្គម ការប្រើប្រាស់បរិស្ថានប្រកបដោយនិរន្តរភាព ការវិនិយោគ និង កំណើនសេដ្ឋកិច្ច។ ប្រជាជនអាចរស់ក្នុងភាពអត់ឃ្លាន និងភាពក្រីក្រ ប្រសិនបើពួកគេបាត់បង់សិទ្ធិកាន់កាប់លំនៅឋាន ដី ជលផល និង ព្រៃឈើរបស់គេ ព្រមទាំងបាត់បង់ជីវភាពរបស់ពួកគេ ដោយសារការអនុវត្តន៍កាន់កាប់ដោយអំពើពុករលួយ ឬ ប្រសិនបើទីភ្នាក់ងារអនុវត្តមិនបានការពារសិទ្ធិកាន់កាប់របស់ពួកគេ។ ប្រជាជនអាចបាត់បង់រហូតដល់អាយុជីវិត នៅពេលដែលអភិបាលកិច្ចទន់ខ្សោយលើការកាន់កាប់ឈានទៅដល់វិវាទហិង្សា។ ផ្ទុយទៅវិញ អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ ជំរុញឱ្យមានការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ដែលអាចជួយលុបបំបាត់ភាពក្រីក្រ និង អសន្តិសុខស្បៀង និង លើកទឹកចិត្តដល់ការវិនិយោគប្រកបដោយការទទួលខុសត្រូវ។

ឆ្លើយតបទៅនឹងចំណាប់អារម្មណ៍ដែលកំពុងមានការកើនឡើងទូលំទូលាយ អង្គការ FAO និងដៃគូរបស់ខ្លួនបានផ្តួចផ្តើមរៀបចំគោលការណ៍ណែនាំ ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់។ គំនិតផ្តួចផ្តើមនេះពង្រឹងបន្ថែម និង គាំទ្រគោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ដើម្បីសម្រេចឱ្យបានជាលំដាប់នូវសិទ្ធិមានស្បៀងអាហារគ្រប់គ្រាន់ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ (គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីសិទ្ធិមានស្បៀងអាហារ) ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់អង្គការ FAO នៅក្នុងសម័យប្រជុំលើកទីមួយរយម្ភៃប្រាំពីររបស់ខ្លួន ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៤ និង សន្និសីទអន្តរជាតិឆ្នាំ ២០០៦ ស្តីពីកំណែទម្រង់ដីធ្លីកសិកម្ម និងអភិវឌ្ឍន៍ជនបទ (ICARRD)។

នៅក្នុងសម័យប្រជុំលើកទីសាមសិបប្រាំមួយរបស់ខ្លួនក្នុងខែ តុលា ឆ្នាំ ២០១០ គណៈកម្មាធិការសន្តិសុខ

ស្បៀងពិភពលោក (CFS) បានជំរុញការបន្តកិច្ចដំណើរការដោយមានការចូលរួមពេញលេញដើម្បីអភិវឌ្ឍគោលការណ៍ណែនាំទាំងនេះ ក្នុងគោលបំណងដាក់គោលការណ៍ទាំងនេះជូន CFS ដើម្បីពិនិត្យពិចារណា និង បានសម្រេចបង្កើតក្រុមការងារបើកទូលាយមួយនៃគណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក ដើម្បីពិនិត្យមើលសេចក្តីព្រាងដំបូងនៃគោលការណ៍ណែនាំនេះ។

គោលការណ៍ណែនាំទាំងនេះ អនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមទម្រង់លិខិតតុបករណ៍ដោយស្ម័គ្រចិត្តដទៃទៀតរបស់អង្គការ FAO ដែលកំណត់គោលការណ៍ និង បទដ្ឋានដែលត្រូវបានទទួលយកជាអន្តរជាតិ សម្រាប់ការអនុវត្តប្រកបដោយការទទួលខុសត្រូវ ៖ គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីសិទ្ធិមានស្បៀងអាហារ ក្រមសីលធម៌សម្រាប់វិស័យជលផលប្រកបដោយការទទួលខុសត្រូវ ក្រមសីលធម៌អន្តរជាតិស្តីពីការចែកចាយ និងការប្រើប្រាស់ថ្នាំកសិកម្ម ការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវលើព្រៃឈើត្រូវដាំ ៖ គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត និង គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីការគ្រប់គ្រងអគ្គីភ័យ ៖ គោលការណ៍ និង សកម្មភាពយុទ្ធសាស្ត្រ។ លិខិតតុបករណ៍ទាំងនេះគឺជាឯកសារខ្លីដែលផ្តល់ក្របខ័ណ្ឌនានាដែលអាចប្រើប្រាស់បាននៅពេលអភិវឌ្ឍយុទ្ធសាស្ត្រ គោលនយោបាយ ច្បាប់ កម្មវិធី និង សកម្មភាពនានា។ គោលការណ៍ណែនាំទាំងនេះ ត្រូវបានអមដោយឯកសារបន្ថែមមួយចំនួន ដូចជាគោលការណ៍ណែនាំបន្ថែម ដែលផ្តល់ព័ត៌មានបច្ចេកទេសលម្អិតអំពីទិដ្ឋភាពជាក់លាក់នៅពេលចាំបាច់ ឯកសារបណ្តុះបណ្តាល និង ឯកសារតស៊ូមតិ និង ការណែនាំបន្ថែមសម្រាប់ជួយដល់ការ អនុវត្តន៍។

គោលការណ៍ណែនាំទាំងនេះ ត្រូវបានអនុម័តដោយគណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក (CFS) នៅក្នុងសម័យប្រជុំ (ពិសេស) លើកទីសាមសិបប្រាំបីរបស់ខ្លួន នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២។

គោលការណ៍ណែនាំ ត្រូវបានអភិវឌ្ឍដោយក្រុមការងារបើកទូលាយនៅក្នុងសម័យប្រជុំ ក្នុងខែ មិថុនា កក្កដា និង ខែ តុលា ឆ្នាំ ២០១១ និង ក្នុងខែ មីនា ឆ្នាំ ២០១២។ គោលការណ៍ណែនាំទាំងនេះ មានមូលដ្ឋានផ្អែកលើកិច្ចដំណើរការពិគ្រោះយោបល់ដោយមានការចូលរួមពេញលេញមួយ ដែលបានធ្វើក្នុងអំឡុងឆ្នាំ ២០០៩-២០១០។ ការពិគ្រោះយោបល់ថ្នាក់តំបន់ ត្រូវបានធ្វើនៅ ប្រទេសប្រេស៊ីល បួគីណាហ្វាសូ អេត្យូពី ហ្សកដានី ណាមីប៊ី ប៉ាណាម៉ា សហព័ន្ធរុស្ស៊ី សាម៉ូអា និង វៀតណាម។ ការពិគ្រោះយោបល់ថ្នាក់តំបន់ទាំងនេះ បានផ្តល់ឱកាសឱ្យមនុស្សជិត ៧០០ នាក់ មកពី ១៣៣ ប្រទេស ដែលតំណាងឱ្យវិស័យសាធារណៈ និងវិស័យឯកជន សង្គមស៊ីវិល និង គ្រឹះស្ថានសិក្សា។ ការពិគ្រោះយោបល់ចំនួនបួន ដែលត្រូវបានធ្វើជាពិសេសសម្រាប់សង្គមស៊ីវិលនៅអាហ្វ្រិក (នៅប្រទេសម៉ាលី) នៅអាស៊ី (នៅប្រទេសម៉ាឡេស៊ី) នៅអឺរ៉ុប និង អាស៊ីកណ្តាល និងអាស៊ីខាងលិច (នៅប្រទេសអ៊ីតាលី) និង នៅអាមេរិកឡាទីន (នៅប្រទេសប្រេស៊ីល) មានការចូលរួមពីមនុស្សជិត ២០០ នាក់មកពី ៧០ ប្រទេស ហើយការពិគ្រោះយោបល់បន្ថែមជាមួយវិស័យឯកជន បានទាក់ទាញអ្នកចូលរួមជាង ៧០ នាក់មកពី ២១ ប្រទេស។ គោលការណ៍ណែនាំទាំងនេះ ក៏ដាក់បញ្ចូលផងដែរនូវសំណើនានាដែលបានទទួលតាមរយៈការពិគ្រោះយោបល់អេឡិកត្រូនិកមួយ ទៅលើសេចក្តីព្រាងទីសូន្យ។ វិស័យសាធារណៈ និងវិស័យឯកជន សង្គមស៊ីវិល និង គ្រឹះស្ថានសិក្សា ពីជុំវិញពិភពលោក បានទទួលសំណើកែលម្អសេចក្តីព្រាងទីសូន្យនេះ។

គោលការណ៍ណែនាំទាំងនេះ មានសង្គតភាព និង ធ្វើការដកស្រង់ចេញពីលិខិតតុបករណ៍អន្តរជាតិ និងតំបន់ រួមមានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលដោះស្រាយបញ្ហាសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់។ នៅពេលមិត្តអ្នកអានគោលការណ៍ណែនាំទាំងនេះព្យាយាមកែលម្អអភិបាលកិច្ចលើការកាន់កាប់ ពួកគេត្រូវបានលើកទឹកចិត្តឱ្យពិនិត្យមើលឡើងវិញជាទៀងទាត់នូវលិខិតតុបករណ៍ទាំងនេះ សម្រាប់កាតព្វកិច្ចសមស្រប និង ការប្តេជ្ញាដោយស្ម័គ្រចិត្តរបស់ពួកគេ ព្រមទាំងដើម្បីទទួលបានការណែនាំបន្ថែម។

# ជំពូកទី ១

## បុព្វកថា

### ១. គោលបំណង

១.១ គោលការណ៍ណែនាំដោយស្ម័គ្រចិត្តទាំងនេះ សំដៅកែលម្អអភិបាលកិច្ចលើការកាន់កាប់ដី* ជលផល និង ព្រៃឈើ។ គោលការណ៍ណែនាំដោយស្ម័គ្រចិត្តទាំងនេះ ព្យាយាមធ្វើបែបនេះ ដើម្បីផលប្រយោជន៍មនុស្សទាំងអស់គ្នា ដោយយកចិត្តទុកដាក់លើប្រជាពលរដ្ឋងាយរងគ្រោះ និងប្រជាពលរដ្ឋដែលត្រូវគេមើលរំលង ក្នុងគោលបំណងធានាឱ្យបាននូវសន្តិសុខស្បៀង និងការសម្រេចបានជាលំដាប់នូវសិទ្ធិមានស្បៀងអាហារគ្រប់គ្រាន់ ការលុបបំបាត់ភាពក្រីក្រ ជីវភាពរស់នៅប្រកបដោយចីរភាព ស្ថេរភាពសង្គម សុវត្ថិភាពលំនៅឋាន អភិវឌ្ឍន៍ជនបទ កិច្ចការពារបរិស្ថាន និង ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ រាល់កម្មវិធីគោលនយោបាយ និង ជំនួយបច្ចេកទេសទាំងអស់ដើម្បីកែលម្អអភិបាលកិច្ចលើការកាន់កាប់តាមរយៈការអនុវត្តគោលការណ៍ណែនាំទាំងនេះ គប្បីមានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់រដ្ឋ អនុលោមតាមច្បាប់អន្តរជាតិ រួមមានសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតតុបករណ៍អន្តរជាតិដទៃទៀតស្តីពីសិទ្ធិមនុស្ស។

១.២ គោលការណ៍ណែនាំទាំងនេះ មានគោលបំណង៖

* ពុំមាននិយមន័យអន្តរជាតិអំពីដីក្នុងបរិបទនៃការកាន់កាប់ទេ។ និយមន័យនៃពាក្យនេះ អាចត្រូវបានកំណត់ក្នុងបរិបទជាតិ។

១. កែលម្អអភិបាលកិច្ចលើការកាន់កាប់ តាមរយៈផ្តល់ការណែនាំ និង ព័ត៌មានអំពីការអនុវត្ត ដែលត្រូវបានទទួលយកជាអន្តរជាតិ សម្រាប់ប្រព័ន្ធទាំងឡាយដែលចាត់ចែងសិទ្ធិប្រើប្រាស់ គ្រប់គ្រង និង ត្រួតត្រាដី ជលផល និង ព្រៃឈើ។

២. រួមចំណែកដល់ការកែលម្អ និងការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និង ក្របខ័ណ្ឌស្ថាប័ន ដែលធ្វើនិយតកម្មសិទ្ធិកាន់កាប់លើធនធានទាំងនេះ។

៣. លើកកម្ពស់តម្លាភាព និង កែលម្អដំណើរការប្រព្រឹត្តទៅនៃប្រព័ន្ធកាន់កាប់។

៤. ពង្រឹងសមត្ថភាព និងប្រតិបត្តិការនៃទីភ្នាក់ងារអនុវត្ត អាជ្ញាធរតុលាការ រដ្ឋាភិបាលមូលដ្ឋាន អង្គការកសិករ និងផលិតករខ្នាតតូច អង្គការអ្នកនេសាទ និង អង្គការអ្នកប្រើប្រាស់ព្រៃឈើ អ្នកចិញ្ចឹមសត្វ ជនជាតិដើមភាគតិច និង សហគមន៍ដទៃទៀត សង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សា និង បុគ្គលគ្រប់រូបដែលពាក់ព័ន្ធទៅនឹងអភិបាលកិច្ចលើការកាន់កាប់ ក៏ដូចជាជំរុញកិច្ចសហប្រតិបត្តិការរវាងតួអង្គទាំងឡាយដែលបានរៀបរាប់ខាងលើ។

## ២. លក្ខណៈ និង វិសាលភាព

២.១ គោលការណ៍ណែនាំទាំងនេះ មានលក្ខណៈជាការស្ម័គ្រចិត្ត។

២.២ គោលការណ៍ណែនាំទាំងនេះ គប្បីត្រូវបកស្រាយ និង អនុវត្ត ឱ្យបានស្របគ្នាជាមួយកាតព្វកិច្ចជាធរមាន អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ និង ដោយយោងតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិជាធរមាន។ គោលការណ៍ណែនាំទាំងនេះ បំពេញបន្ថែម និង គាំទ្រគំនិតផ្តួចផ្តើមនៅថ្នាក់ជាតិ តំបន់ និង អន្តរជាតិ ដែលឆ្លើយតបទៅនឹងសិទ្ធិមនុស្ស និង ផ្តល់សិទ្ធិកាន់កាប់ច្បាស់លាស់លើដី ជលផល និង ព្រៃឈើ ព្រមទាំងជាគំនិតផ្តួចផ្តើមដើម្បីកែលម្អអភិបាលកិច្ចផងដែរ។ នៅក្នុងគោលការណ៍ណែនាំទាំងនេះ គប្បីមិនត្រូវដាក់កម្រិត ឬ ធ្វើឱ្យប៉ះពាល់កាតព្វកិច្ចស្របច្បាប់ណាមួយ ដែលរដ្ឋមួយអាចត្រូវគោរពតាមច្បាប់អន្តរជាតិឡើយ។

២.៣ គោលការណ៍ណែនាំទាំងនេះ អាចត្រូវបានប្រើប្រាស់ដោយរដ្ឋ ទីភ្នាក់ងារអនុវត្ត អាជ្ញាធរតុលាការ រដ្ឋាភិបាលមូលដ្ឋាន អង្គការកសិករ និងផលិតករខ្នាតតូច អង្គការអ្នកនេសាទ និង អង្គការអ្នកប្រើប្រាស់ព្រៃឈើ អ្នកចិញ្ចឹមសត្វ ជនជាតិដើមភាគតិច និង សហគមន៍ដទៃទៀត សង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សា និង បុគ្គលដែលពាក់ព័ន្ធគ្រប់រូប ដើម្បីធ្វើការប៉ាន់ប្រមាណទៅលើអភិបាលកិច្ចលើការកាន់កាប់ និង កំណត់រកការកែលម្អ និង អនុវត្តការកែលម្អទាំងនោះ។

១

២.៤ គោលការណ៍ណែនាំទាំងនេះ មានវិសាលភាពជាសកល។ ដោយយោងទៅតាមបរិបទជាតិ គោលការណ៍ណែនាំទាំងនេះ អាចត្រូវបានប្រទេស និងតំបន់ទាំងអស់យកមកប្រើប្រាស់នៅក្នុងគ្រប់ដំណាក់កាលនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សម្រាប់អភិបាលកិច្ចលើរាល់ទម្រង់នៃការកាន់កាប់ រួមមាន ការកាន់កាប់ជាសាធារណៈ ឯកជន សហគមន៍ សមូហភាព ជនជាតិដើមភាគតិច និងតាមទំនៀមទម្លាប់។

២.៥ គោលការណ៍ណែនាំទាំងនេះ គប្បីត្រូវបកស្រាយ និងអនុវត្ត ស្របតាមប្រព័ន្ធច្បាប់ជាតិ និងស្ថាប័ននៃប្រព័ន្ធច្បាប់ជាតិទាំងនោះ។

# ជំពូកទី ២

## ទិដ្ឋភាពទូទៅ

ជំពូកនេះថែងពីទិដ្ឋភាពនៃអភិបាលកិច្ចលើការកាន់កាប់ដី ជលផល និង ព្រៃឈើ ទាក់ទងទៅនឹងសិទ្ធិ និង ការទទួលខុសត្រូវ ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និង ក្របខ័ណ្ឌស្ថាប័ន ព្រមទាំងការផ្តល់សេវា។

ក្នុងបរិបទនៃអភិបាលកិច្ចលើការកាន់កាប់ រដ្ឋមានកាតព្វកិច្ចក្រោមលិខិតតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលអាចយកមកអនុវត្តបាន។ ជំពូកទី ២ គប្បីគួរអាន យោងតាមកថាខណ្ឌ ២.២។

## ៣. គោលការណ៍ណែនាំនៃអភិបាលកិច្ចលើការកាន់កាប់ប្រកបដោយការទទួលខុសត្រូវ

### ៣ក គោលការណ៍ទូទៅ

៣.១ រដ្ឋគប្បី:

១. ទទួលស្គាល់ និងគោរពរាល់សាម៉ីជនមានសិទ្ធិកាន់កាប់ស្របច្បាប់ និង សិទ្ធិរបស់ពួកគេ។ រដ្ឋគប្បីចាត់វិធានការសមស្របដើម្បីកំណត់អត្តសញ្ញាណ ចុះបញ្ជី និង គោរពសាម៉ីជនមានសិទ្ធិកាន់កាប់ស្របច្បាប់ និង សិទ្ធិរបស់ពួកគេ ទោះបីជាត្រូវបានចុះបញ្ជីជាផ្លូវការ ឬ មិនបានចុះបញ្ជីក្តី ដើម្បីទប់ស្កាត់ការរំលោភសិទ្ធិកាន់កាប់របស់អ្នកដទៃ និង ដើម្បីបំពេញភារកិច្ចនានាទាក់ទងទៅនឹងសិទ្ធិកាន់កាប់។

២. ការពារសិទ្ធិកាន់កាប់ស្របច្បាប់ប្រឆាំងនឹងការគម្រាមកំហែង និងការរំលោភបំពាន។ រដ្ឋគប្បីការពារសាមីជនមានសិទ្ធិកាន់កាប់ ប្រឆាំងនឹងការបាត់បង់សិទ្ធិកាន់កាប់របស់ពួកគេដោយការរំលោភបំពាន រួមមានការបណ្តេញចេញដោយបង្ខំដែលមិនមានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់រដ្ឋ ក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

៣. ជំរុញ និង សម្របសម្រួលដល់ការទទួលបានសិទ្ធិកាន់កាប់ស្របច្បាប់។ រដ្ឋគប្បីចាត់វិធានការសកម្មដើម្បីជំរុញ និង សម្របសម្រួលដល់ការសម្រេចបានពេញលេញនូវសិទ្ធិកាន់កាប់ ឬ ការធ្វើប្រតិបត្តិការជាមួយសិទ្ធិទាំងនេះ ដូចជាការធានាថាប្រជាពលរដ្ឋគ្រប់រូបអាចទទួលបាននូវសេវា។

៤. ផ្តល់លទ្ធភាពទទួលបានយុត្តិធម៌ ក្នុងការដោះស្រាយការរំលោភលើសិទ្ធិកាន់កាប់ស្របច្បាប់។ រដ្ឋគប្បីផ្តល់មធ្យោបាយប្រកបដោយប្រសិទ្ធភាព និងអាចទទួលបាន ជូនប្រជាជនគ្រប់រូប តាមរយៈអាជ្ញាធរតុលាការ ឬ អភិក្រមផ្សេងទៀត ដើម្បីដោះស្រាយវិវាទលើសិទ្ធិកាន់កាប់ និង ដើម្បីផ្តល់ការអនុវត្តន៍លទ្ធផលដែលអាចធ្វើទៅបានភ្លាមៗ។ រដ្ឋគប្បីផ្តល់សំណងភ្លាមៗប្រកបដោយភាពយុត្តិធម៌ ក្នុងករណីដែលសិទ្ធិកាន់កាប់ត្រូវបានដកហូតដើម្បីប្រយោជន៍សាធារណៈ។

៥. ទប់ស្កាត់វិវាទលើការកាន់កាប់ ជម្លោះហិង្សា និង អំពើពុករលួយ។ រដ្ឋគប្បីចាត់វិធានការសកម្មដើម្បីទប់ស្កាត់វិវាទលើការកាន់កាប់កុំឱ្យកើតឡើង និង កុំឱ្យក្លាយទៅជាជម្លោះហិង្សា។ រដ្ឋគប្បីខិតខំទប់ស្កាត់អំពើពុករលួយក្នុងគ្រប់រូបភាព នៅគ្រប់កម្រិត និង ក្នុងគ្រប់ស្ថានភាពទាំងអស់។

៣.២ តួអង្គមិនមែនរដ្ឋ រួមទាំងសហគ្រាសអាជីវកម្ម មានកាតព្វកិច្ចត្រូវគោរពសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់ស្របច្បាប់។ សហគ្រាសអាជីវកម្ម គប្បីធ្វើសកម្មភាពប្រកបដោយការយកចិត្តទុកដាក់ ខ្ពស់ដើម្បីជៀសវាងការរំលោភសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់ស្របច្បាប់របស់អ្នកដទៃ។ ពួកគេគប្បីមានប្រព័ន្ធគ្រប់គ្រងហានិភ័យសមស្រប ដើម្បីទប់ស្កាត់ និង ដោះស្រាយផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់ស្របច្បាប់។ សហគ្រាសអាជីវកម្ម គប្បីរៀបចំ និង សហការនៅក្នុងយន្តការមិនមែនតុលាការ ដើម្បីផ្តល់ដំណោះស្រាយកែតម្រូវ រួមទាំងយន្តការបណ្តឹងសាទុក្ខប្រកបដោយប្រសិទ្ធភាពនៅកម្រិតប្រតិបត្តិការ ក្នុងករណីសមស្រប និងក្នុងករណីដែលពួកគេបានបណ្តាលឱ្យមាន ឬ បានរួមចំណែកបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់ស្របច្បាប់។ សហគ្រាសអាជីវកម្ម គប្បីកំណត់ និងវាយតម្លៃផលប៉ះពាល់ដែលអាចមាន ឬ ផលប៉ះពាល់ជាក់ស្តែងទៅលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់ស្របច្បាប់ ដែលពួកគេអាចមានការពាក់ព័ន្ធ។ អនុលោមតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន រដ្ឋគប្បីផ្តល់ដំណោះស្រាយតាមផ្លូវតុលាការប្រកបដោយប្រសិទ្ធភាព សម្រាប់ផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ស្របច្បាប់ ដែលបង្កឡើងដោយសហគ្រាសអាជីវកម្ម។ ក្នុងករណី

២

ដែលពាក់ព័ន្ធសាជីវកម្មឆ្លងប្រទេស រដ្ឋប្រភពដើមនៃសាជីវកម្មទាំងនោះមានតួនាទីជួយដល់សាជីវកម្មទាំងនោះផង និងរដ្ឋម្ចាស់ផ្ទះផង ដើម្បីធានាឱ្យបានថាអាជីវកម្មទាំងឡាយមិនមានជាប់ពាក់ព័ន្ធក្នុងការបំពានលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់ស្របច្បាប់។ រដ្ឋគប្បីចាត់វិធានការបន្ថែម ដើម្បីការពារប្រឆាំងនឹងការបំពានលើសិទ្ធិមនុស្ស និង សិទ្ធិកាន់កាប់ស្របច្បាប់ ដោយសហគ្រាសអាជីវកម្ម ដែលជាកម្មសិទ្ធិរបស់រដ្ឋ ឬ ត្រួតត្រាដោយរដ្ឋ ឬ ដែលទទួលការគាំទ្រច្រើននិងសេវាច្រើនពីស្ថាប័នរដ្ឋ។

## ៣ខ គោលការណ៍នៃការអនុវត្ត

គោលការណ៍នៃការអនុវត្តទាំងនេះ មានសារៈសំខាន់ក្នុងការរួមចំណែកដល់អភិបាលកិច្ចលើការកាន់កាប់ដី ជលផល និង ព្រៃឈើ ប្រកបដោយការទទួលខុសត្រូវ។

១. **សេចក្តីថ្លៃថ្នូររបស់មនុស្ស៖** ទទួលស្គាល់សេចក្តីថ្លៃថ្នូរពីកំណើត និង សិទ្ធិមនុស្សស្មើភាពគ្នា និងមិនអាចផ្តាច់បានរបស់បុគ្គលគ្រប់រូប។

២. **មិនមានការរើសអើង៖** មិនមានអ្នកណាម្នាក់គប្បីទទួលរងការរើសអើងឡើយ បើយោងតាមច្បាប់ និងគោលនយោបាយ ក៏ដូចជា ក្នុងការអនុវត្តជាក់ស្តែង។

៣. **សមធម៌ និងយុត្តិធម៌៖** ការទទួលស្គាល់សមភាពរវាងបុគ្គល អាចតម្រូវឱ្យមានការទទួលស្គាល់ភាពខុសគ្នារវាងបុគ្គល និង ការធ្វើសកម្មភាពវិជ្ជមាន រួមទាំងការផ្តល់អំណាច ដើម្បីជំរុញសិទ្ធិកាន់កាប់ប្រកបដោយសមធម៌ និង លទ្ធភាពប្រើប្រាស់ដី ជលផល និង ព្រៃឈើ សម្រាប់មនុស្សទាំងអស់គ្នា ពោលគឺ ស្ត្រី និងបុរស យុវជន និង ប្រជាជនងាយរងគ្រោះ និង ប្រជាជនដែលរមែងតែងត្រូវបានគេមើលរំលង ក្នុងបរិបទជាតិ។

៤. **សមភាពយេនឌ័រ៖** ធានាសិទ្ធិស្មើភាពគ្នារបស់ស្ត្រី និងបុរស ដើម្បីការទទួលបានរាល់សិទ្ធិមនុស្សទាំងអស់ ទន្ទឹមគ្នានឹងការទទួលស្គាល់អំពីភាពខុសគ្នារវាងស្ត្រី និងបុរស និង ចាត់វិធានការជាក់លាក់សំដៅពន្លឿនសមភាពជាក់ស្តែង នៅពេលដែលចាំបាច់។ រដ្ឋគប្បីធានាថាស្ត្រី និងកុមារីមានសិទ្ធិកាន់កាប់ និង មានលទ្ធភាពប្រើប្រាស់ដី ជលផល និង ព្រៃឈើស្មើភាពគ្នា មិនចំពោះថាតើពួកគេមានស្ថានភាពជាពលរដ្ឋ និងស្ថានភាពអាពាហ៍ពិពាហ៍យ៉ាងដូចម្តេច។

៥. **អភិក្រមពេញលេញ និងប្រកបដោយនិរន្តរភាព៖** ការទទួលស្គាល់ថាធនធានធម្មជាតិ និង ការប្រើប្រាស់ធនធានទាំងនេះ មានលក្ខណៈប្រទាក់ក្រឡាគ្នា និង ការអនុម័តអភិក្រមចម្រុះ និងប្រកបដោយនិរន្តរភាពចំពោះការគ្រប់គ្រងធនធានទាំងនេះ។

៦. **ការពិគ្រោះយោបល់ និង ការចូលរួម៖** ការចូលរួមជាមួយ និងការស្វែងរកការគាំទ្រពីអ្នកដែលមានសិទ្ធិកាន់កាប់ស្របច្បាប់ អាចទទួលផលពីការសម្រេចចិត្ត មុនពេលដែលការសម្រេចចិត្តត្រូវបានធ្វើឡើង និង ការឆ្លើយតបទៅនឹងការរួមចំណែករបស់ពួកគេ, ការពិចារណាអំពីអតុល្យភាពអំណាចរវាងភាគីផ្សេងៗ និង ការធានាឱ្យបាននូវការចូលរួមសកម្ម ដោយសេរី ប្រកបដោយប្រសិទ្ធភាព អត្ថន័យ និង ព័ត៌មានចូលរួមគ្រប់ជ្រុងជ្រោយរបស់បុគ្គល និងក្រុមនានា នៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលពាក់ព័ន្ធ។

៧. **វិធាននៃច្បាប់៖** ការអនុម័តអភិក្រមផ្អែកលើវិធាន តាមរយៈច្បាប់ដែលត្រូវបានផ្សព្វផ្សាយទូលំទូលាយ ជាភាសាសមស្រប អនុវត្តចំពោះបុគ្គលគ្រប់រូបស្មើៗគ្នា និង ត្រូវបានវិនិច្ឆ័យដោយឯករាជ្យ ព្រមទាំងមានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ពួកគេ អនុលោមតាមច្បាប់ជាតិ និង អន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។

៨. **តម្លាភាព៖** ការកំណត់និយមន័យច្បាស់លាស់ និង ការផ្សព្វផ្សាយទូលំទូលាយ អំពីគោលនយោបាយ ច្បាប់ និង នីតិវិធីនានា ជាភាសាសមស្រប និង ការផ្សព្វផ្សាយទូលំទូលាយអំពីសេចក្តីសម្រេចនានា ជាភាសាសមស្រប និង ក្នុងទម្រង់ដែលអាចប្រើប្រាស់បានដល់គ្រប់គ្នា។

៩. **គណនេយ្យភាព៖** ការធ្វើឱ្យបុគ្គល ទីភ្នាក់ងារសាធារណៈ និង តួអង្គមិនមែនរដ្ឋទទួលខុសត្រូវលើសកម្មភាព និងសេចក្តីសម្រេចចិត្តរបស់ពួកគេ ស្របតាមគោលការណ៍វិធាននៃច្បាប់។

១០. **ការកែលម្អជាប្រចាំ ៖** រដ្ឋគប្បីកែលម្អយន្តការសម្រាប់ការតាមដាន និងការវិភាគអភិបាលកិច្ចលើការកាន់កាប់ ដើម្បីអភិវឌ្ឍកម្មវិធីដែលមានមូលដ្ឋានផ្អែកលើភស្តុតាង និងធានាឱ្យបាននូវកំណែលម្អជាប្រចាំ។

## ៤. សិទ្ធិ និងការទទួលខុសត្រូវទាក់ទងនឹងការកាន់កាប់

៤.១ រដ្ឋគប្បីខិតខំធានាឱ្យបានអភិបាលកិច្ចលើការកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ដោយសាដីជលផល និង ព្រៃឈើមានសារៈសំខាន់បំផុតចំពោះការសម្រេចបាននូវសិទ្ធិមនុស្ស សន្តិសុខស្បៀង ការលុបបំបាត់ភាពក្រីក្រ ជីវភាពរស់នៅប្រកបដោយចីរភាព ស្ថេរភាពសង្គម សុវត្ថិភាពលំនៅឋាន ការអភិវឌ្ឍន៍ជនបទ និងភាពរីកចម្រើននៅក្នុងសង្គម និងកំណើនសេដ្ឋកិច្ច។

៤.២ រដ្ឋគប្បីធានាថា រាល់សកម្មភាពទាំងអស់ទាក់ទងទៅនឹងការកាន់កាប់ និង អភិបាលកិច្ចលើការ

កាន់កាប់ មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួន ក្រោមច្បាប់ជាតិ និងអន្តរជាតិ និងដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិ ដែលអាចយកមកអនុវត្តបាន។

៤.៣ គ្រប់ភាគីទាំងអស់ គប្បីទទួលស្គាល់ថា ពុំមានសិទ្ធិកាន់កាប់ណាមួយ រួមទាំងកម្មសិទ្ធិឯកជនផងមានលក្ខណៈដាច់ខាតឡើយ។ រាល់សិទ្ធិកាន់កាប់ទាំងអស់សុទ្ធតែត្រូវបានកំណត់ព្រំដែនដោយសិទ្ធិរបស់អ្នកដទៃ និង ដោយវិធានការអនុវត្តដោយរដ្ឋដែលចាំបាច់ សម្រាប់គោលបំណងសាធារណៈ។ វិធានការទាំងនេះ គប្បីត្រូវបានកំណត់ដោយច្បាប់ សម្រាប់គោលបំណងតែមួយគត់សំដៅជំរុញសុខុមាលភាពទូទៅ រួមទាំងកិច្ចការពារបរិស្ថាន និង ស្របតាមកាតព្វកិច្ចគោរពសិទ្ធិមនុស្សរបស់រដ្ឋ។ សិទ្ធិកាន់កាប់ក៏ត្រូវបានធ្វើឱ្យមានតុល្យភាពផងដែរដោយកាតព្វកិច្ចនានា។ ទាំងអស់គ្នាគប្បីគោរពកិច្ចការពាររយៈពេលវែង និង ការប្រើប្រាស់ដី ជលផល និង ព្រៃឈើប្រកបដោយនិរន្តរភាព។

៤.៤ ផ្អែកលើការពិនិត្យមើលសិទ្ធិកាន់កាប់ស្របតាមច្បាប់ជាតិ រដ្ឋគប្បីផ្តល់ការទទួលស្គាល់ស្របច្បាប់ចំពោះសិទ្ធិកាន់កាប់ស្របច្បាប់ដែលបច្ចុប្បន្នមិនត្រូវបានការពារដោយច្បាប់។ គោលនយោបាយ និងច្បាប់ទាំងឡាយដែលធានាសិទ្ធិកាន់កាប់ គប្បីមានលក្ខណៈមិនរើសអើង និង គិតគូរដល់យេនឌ័រ។ ដោយស្របតាមគោលការណ៍នៃការពិគ្រោះយោបល់ និងការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ រដ្ឋគប្បីកំណត់លក្ខណៈវិនិច្ឆ័យនៃសិទ្ធិទាំងឡាយដែលត្រូវបានចាត់ទុកថាស្របច្បាប់តាមរយៈវិធានដែលបានផ្សព្វផ្សាយទូលំទូលាយ។ គ្រប់ទម្រង់ទាំងអស់នៃការកាន់កាប់ គប្បីផ្តល់ជូនមនុស្សគ្រប់រូបនូវសុវត្ថិភាពកាន់កាប់ក្នុងកម្រិតណាមួយ ដែលធានាកិច្ចការពារតាមផ្លូវច្បាប់ប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ដែលមិនមានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់រដ្ឋ ក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ប្រឆាំងនឹងការបៀតបៀន និងការគម្រាមកំហែងផ្សេងទៀត។

៤.៥ រដ្ឋគប្បីការពារសិទ្ធិកាន់កាប់ស្របច្បាប់ និងធានាថា ប្រជាពលរដ្ឋមិនត្រូវបានបណ្តេញចេញដោយបំពាន ហើយសិទ្ធិកាន់កាប់ស្របច្បាប់របស់ពួកគេមិនត្រូវបានរំលត់ ឬ រំលោភឡើយ។

៤.៦ រដ្ឋគប្បីលុបបំបាត់ និង ហាមឃាត់រាល់ទម្រង់នៃការរើសអើងទាក់ទងទៅនឹងសិទ្ធិកាន់កាប់ រួមទាំងការរើសអើងដែលបណ្តាលមកពីការផ្លាស់ប្តូរនៃស្ថានភាពអាពាហ៍ពិពាហ៍ កង្វះសមត្ថភាពផ្នែកច្បាប់ និង កង្វះលទ្ធភាពទទួលបានធនធានសេដ្ឋកិច្ច។ ជាពិសេស រដ្ឋគប្បីធានាសិទ្ធិកាន់កាប់ស្មើភាពគ្នាសម្រាប់ស្ត្រី និងបុរស រួមមានសិទ្ធិទទួលមរតក និង សិទ្ធិផ្ទេរសិទ្ធិកាន់កាប់ទាំងនេះ។ សកម្មភាពរបស់រដ្ឋបែបនេះ គប្បីមានសង្គតភាពជាមួយកាតព្វកិច្ចជាធរមានរបស់ខ្លួន ក្រោមច្បាប់ និងនីតិកម្មជាតិ និង ច្បាប់អន្តរជាតិពាក់ព័ន្ធ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។

៤.៧ រដ្ឋគប្បីពិចារណាផ្តល់ជំនួយដែលមានលក្ខណៈមិនរើសអើង និងគិតគូរដល់យេនឌ័រ ក្នុងករណីដែលតាមរយៈសកម្មភាពរបស់ពួកគេ ប្រជាជនមិនអាចទទួលបានសិទ្ធិកាន់កាប់ ដើម្បីទ្រទ្រង់ខ្លួនឯង និងទទួលបានសេវារបស់ទីភ្នាក់ងារអនុវត្ត និងអាជ្ញាធរតុលាការ ឬ ដើម្បីចូលរួមក្នុងដំណើរការនានាដែលអាចប៉ះពាល់ដល់សិទ្ធិកាន់កាប់របស់ពួកគេ។

៤.៨ ដោយសារសិទ្ធិមនុស្សទាំងអស់មានលក្ខណៈជាសកល មិនអាចបែងចែកបាន ចំណុះគ្នាទៅវិញទៅមក និង ប្រទាក់ក្រឡាគ្នា អភិបាលកិច្ចលើការកាន់កាប់ដី ជលផល និង ព្រៃឈើ មិនត្រឹមតែគួរគិតគូរដល់សិទ្ធិទាំងឡាយដែលផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងលទ្ធភាពទទួលបាន និង ការប្រើប្រាស់ដី ជលផល និង ព្រៃឈើប៉ុណ្ណោះទេ ហើយថែមទាំងគួរគិតគូរដល់សិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ផងដែរ។ ក្នុងការធ្វើដូច្នេះ រដ្ឋគប្បីគោរព និងការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់អ្នកការពារសិទ្ធិមនុស្ស រួមមាន សិទ្ធិមនុស្សរបស់កសិករ ជនជាតិដើមភាគតិច អ្នកនេសាទ អ្នកចិញ្ចឹមសត្វ និង កម្មករជនបទ និង គប្បីអនុវត្តកាតព្វកិច្ចគោរពសិទ្ធិមនុស្សរបស់ខ្លួន នៅពេលធ្វើការងារជាមួយបុគ្គល និងសមាគមទាំងឡាយដែលធ្វើសកម្មភាពដើម្បីការពារដី ជលផល និង ព្រៃឈើ។

៤.៩ តាមរយៈស្ថាប័នតុលាការ និងរដ្ឋបាលមានសមត្ថកិច្ចដែលអព្យាក្រឹត្យ រដ្ឋគប្បីផ្តល់នូវលទ្ធភាពទទួលបានមធ្យោបាយមានតម្លៃសមរម្យ និង មានប្រសិទ្ធភាពក្នុងការដោះស្រាយជម្លោះលើសិទ្ធិកាន់កាប់ រួមមានមធ្យោបាយជាជម្រើសផ្សេងៗនៃការដោះស្រាយជម្លោះបែបនេះ និង គប្បីផ្តល់ដំណោះស្រាយកែតម្រូវប្រកបដោយប្រសិទ្ធភាព ដែលអាចរួមមានសិទ្ធិប្តឹងឧទ្ធរណ៍ ទៅតាមភាពសមស្រប។ ដំណោះស្រាយកែតម្រូវបែបនេះ គប្បីអនុវត្តភ្លាមៗ និង អាចរួមមានបដិទានថ្លៃសោហ៊ុយ សំណង និង ការប៉ះប៉ូវ។ រដ្ឋគប្បីខិតខំធានាឱ្យបានថាជនងាយរងគ្រោះ និងជនដែលគេមើលរំលង មានលទ្ធភាពប្រើប្រាស់មធ្យោបាយទាំងនេះ ស្របតាមកថាខណ្ឌ ៦.៦ និង ២១.៦។ រដ្ឋគប្បីធានាថាជនដែលត្រូវបានរំលោភសិទ្ធិមនុស្សក្នុងបរិបទនៃការកាន់កាប់ មានលទ្ធភាពប្រើប្រាស់មធ្យោបាយដោះស្រាយជម្លោះ និង ដំណោះស្រាយកែតម្រូវទាំងនេះ។

៤.១០ រដ្ឋគប្បីស្វាគមន៍ និងសម្រួលការចូលរួមរបស់អ្នកប្រើប្រាស់ដី ជលផល និង ព្រៃឈើ ដើម្បីចូលរួមឱ្យបានពេញលេញក្នុងកិច្ចដំណើរការដោយមានការចូលរួម នៃអភិបាលកិច្ចលើការកាន់កាប់ មានជាអាទិ៍ ការបង្កើត និងការអនុវត្តន៍គោលនយោបាយ និងច្បាប់ និង សេចក្តីសម្រេចនានាស្តីពីការអភិវឌ្ឍដែនដី តាមភាពសមស្របទៅនឹងតួនាទីរបស់រដ្ឋ និងភាគីមិនមែនរដ្ឋ និង ស្របតាមច្បាប់ និងនីតិកម្មជាតិ។

## ៥. ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និង ក្របខ័ណ្ឌស្ថាប័នទាក់ទងទៅនឹងការកាន់កាប់

៥.១ រដ្ឋគប្បីផ្តល់ និងរក្សាទុកក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និង ក្របខ័ណ្ឌស្ថាប័នទាំងឡាយ ដែលលើកកម្ពស់អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និង ព្រៃឈើ។ ក្របខ័ណ្ឌទាំងនេះពឹងផ្អែកលើ និង បានទទួលការគាំទ្រពីកំណែទម្រង់ទូលំទូលាយចំពោះប្រព័ន្ធគតិយុត្តិ សេវាសាធារណៈ និង អាជ្ញាធរតុលាការ។

៥.២ រដ្ឋគប្បីធានាថាក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និង ក្របខ័ណ្ឌស្ថាប័នសម្រាប់អភិបាលកិច្ចលើការកាន់កាប់ មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។

៥.៣ រដ្ឋគប្បីធានាថា ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និង ក្របខ័ណ្ឌស្ថាប័នទាំងឡាយសម្រាប់អភិបាលកិច្ចលើការកាន់កាប់ ទទួលស្គាល់ និងគោរព ស្របតាមច្បាប់ជាតិ ចំពោះសិទ្ធិកាន់កាប់ស្របច្បាប់ រួមមានសិទ្ធិកាន់កាប់ស្របច្បាប់បែបប្រពៃណីដែលបច្ចុប្បន្នមិនត្រូវបានការពារដោយច្បាប់ និង សម្របសម្រួល លើកកម្ពស់ និង ការពារការអនុវត្តសិទ្ធិកាន់កាប់។ ក្របខ័ណ្ឌទាំងនេះ គប្បីឆ្លុះបញ្ចាំងអំពីសារៈសំខាន់ផ្នែកសង្គម វប្បធម៌ សេដ្ឋកិច្ច និងបរិស្ថាននៃដី ជលផល និង ព្រៃឈើ។ រដ្ឋគប្បីផ្តល់ក្របខ័ណ្ឌនានាដែលមានលក្ខណៈមិនរើសអើង និង លើកកម្ពស់សមធម៌សង្គម និង សមភាពយេនឌ័រ។ ក្របខ័ណ្ឌទាំងនេះ គប្បីឆ្លុះបញ្ចាំងអំពីទំនាក់ទំនងដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា រវាង ដី ជលផល និង ព្រៃឈើ និងការប្រើប្រាស់របស់វា ព្រមទាំងបង្កើតអភិក្រមចម្រុះមួយសម្រាប់ការគ្រប់គ្រង។

៥.៤ រដ្ឋគប្បីពិចារណាអំពីឧបសគ្គដោយឡែកដែលស្ត្រី និងកុមារីជួបប្រទះ ទាក់ទងទៅនឹងការកាន់កាប់ និងសិទ្ធិកាន់កាប់ដែលពាក់ព័ន្ធ ព្រមទាំងចាត់វិធានការនានា ដើម្បីធានាថាក្របខ័ណ្ឌច្បាប់ និង គោលនយោបាយ ផ្តល់កិច្ចការពារគ្រប់គ្រាន់ជូនស្ត្រី និង ធានាថាច្បាប់ដែលទទួលស្គាល់សិទ្ធិកាន់កាប់របស់ស្ត្រី ត្រូវបានអនុវត្ត និងប្រតិបត្តិ។ រដ្ឋគប្បីធានាថា ស្ត្រីអាចចុះកិច្ចសន្យាដោយស្របច្បាប់ពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ ដោយឈរលើមូលដ្ឋានសមភាពជាមួយបុរស និង គប្បីខិតខំផ្តល់សេវាច្បាប់ និង ជំនួយផ្សេងទៀត ដើម្បីជួយឱ្យស្ត្រីអាចការពារផលប្រយោជន៍ពីការកាន់កាប់របស់ខ្លួន។

៥.៥ រដ្ឋគប្បីអភិវឌ្ឍគោលនយោបាយ ច្បាប់ និង នីតិវិធីពាក់ព័ន្ធនានា តាមរយៈកិច្ចដំណើរការដោយមានការចូលរួម ដែលពាក់ព័ន្ធភាគីរងផលប៉ះពាល់ទាំងអស់ ដោយធានាថា ទាំងបុរស និងស្ត្រីត្រូវបានរាប់បញ្ចូលតាំងពីដំបូង។ គោលនយោបាយ ច្បាប់ និង នីតិវិធី គប្បីគិតគូរដល់

២

សមត្ថភាពដើម្បីអនុវត្ត។ គោលនយោបាយ ច្បាប់ និង នីតិវិធី គប្បីដាក់បញ្ចូលអភិក្រមទាំងឡាយដែលគិតគូរដល់យេនឌ័រ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ជាភាសាសមស្រប និង ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

៥.៦ រដ្ឋគប្បីរៀបចំឱ្យមានការទទួលខុសត្រូវនៅគ្រប់កម្រិតរដ្ឋាភិបាល ដែលអាចផ្តល់សេវាដ៏មានប្រសិទ្ធភាពបំផុតជូនប្រជាពលរដ្ឋ។ រដ្ឋគប្បីកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នទាំងឡាយដែលធ្វើការងារលើការកាន់កាប់ដី ជលផល និង ព្រៃឈើ។ រដ្ឋគប្បីធានាឱ្យបាននូវការសម្របសម្រួលជាមួយទីភ្នាក់ងារអនុវត្ត និងរដ្ឋាភិបាលមូលដ្ឋាន ព្រមទាំងជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី។

៥.៧ រដ្ឋគប្បីកំណត់ និងផ្សព្វផ្សាយឱកាសនានាសម្រាប់សង្គមស៊ីវិល វិស័យឯកជន និង គ្រឹះស្ថានសិក្សា រួមចំណែកដល់ការអភិវឌ្ឍ និងការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌ គតិយុត្តិ និង ក្របខ័ណ្ឌស្ថាប័ន ទៅតាមភាពសមស្រប។

៥.៨ រដ្ឋ និងភាគីដទៃទៀត គប្បីពិនិត្យមើលឡើងវិញ និង តាមដានឱ្យបានទៀងទាត់នូវក្របខណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និងក្របខ័ណ្ឌស្ថាប័ន ដើម្បីរក្សាប្រសិទ្ធភាពនៃក្របខ័ណ្ឌទាំងនេះ។ ទីភ្នាក់ងារអនុវត្ត និងអាជ្ញាធរតុលាការ គប្បីចូលរួមជាមួយសង្គមស៊ីវិល តំណាងអ្នកប្រើប្រាស់ និង សាធារណជនទូទៅ ដើម្បីកែលម្អសេវា និង ខិតខំទប់ស្កាត់ប្រឆាំងអំពើពុករលួយតាមរយៈ នីតិវិធី និងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយតម្លាភាព។ ព័ត៌មានអំពីការផ្លាស់ប្តូរ និង ផលប៉ះពាល់នៃការផ្លាស់ប្តូរដែលគេបានរំពឹងទុកជាមុន គប្បីគួរបញ្ជាក់ឱ្យបានច្បាស់លាស់ និង ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាភាសាសមស្រប។

៥.៩ រដ្ឋគប្បីទទួលស្គាល់ថា គោលនយោបាយ និង ច្បាប់ស្តីពីសិទ្ធិកាន់កាប់ មានប្រតិបត្តិការក្នុងបរិបទនយោបាយ ច្បាប់ សង្គម វប្បធម៌ សាសនា សេដ្ឋកិច្ច និង បរិស្ថានដែលមានលក្ខណៈទូលំទូលាយ។ ក្នុងករណីដែលបរិបទទូលំទូលាយមានការផ្លាស់ប្តូរ និង តម្រូវឱ្យមានកំណែទម្រង់ទៅលើការកាន់កាប់ រដ្ឋគប្បីខិតខំអភិវឌ្ឍការឯកភាពជាតិលើកំណែទម្រង់ដែលបានស្នើឡើង។

## ៦. ការផ្តល់សេវា**

៦.១ យោងតាមលទ្ធភាពធនធាន រដ្ឋគប្បីធានាថា ទីភ្នាក់ងារអនុវត្ត និង អាជ្ញាធរតុលាការមានសមត្ថភាពធនធានមនុស្ស សមត្ថភាពរូបវ័ន្ត សមត្ថភាពហិរញ្ញវត្ថុ និង សមត្ថភាពក្នុងទម្រង់ផ្សេងទៀត ដើម្បីអនុវត្តគោលនយោបាយ និងច្បាប់ ឱ្យបានទាន់ពេល ប្រកបដោយប្រសិទ្ធភាព និងគិតគូរដល់យេនឌ័រ។ បុគ្គលិកស្ថាប័នគ្រប់កម្រិត គប្បីទទួលបានការបណ្តុះបណ្តាលជាប្រចាំ និង គួរត្រូវបានជ្រើសរើសដោយធានាឱ្យបាននូវសមភាពយេនឌ័រ និង សមភាពសង្គម។

** ផ្នែកទី ៦ ណែនាំដោយឡែកអំពីការអានពីផ្នែកទី ១៧ ដល់ ទី ២១។

៦.២ រដ្ឋគប្បីធានាថា ការផ្តល់សេវាទាក់ទងទៅនឹងការកាន់កាប់ និងរដ្ឋបាលលើការកាន់កាប់ មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និងដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។

៦.៣ រដ្ឋគប្បីផ្តល់សេវាដែលអាចទទួលបានភ្លាមៗ និងគ្មានការរើសអើង ដើម្បីការពារសិទ្ធិកាន់កាប់ លើកកម្ពស់ និងសម្របសម្រួលដល់ការទទួលបានសិទ្ធិទាំងនោះ និងដើម្បីដោះស្រាយវិវាទ។ រដ្ឋគប្បីលុបបំបាត់លក្ខខណ្ឌផ្នែកច្បាប់ និងនីតិវិធីមិនចាំបាច់នានា និង ខិតខំជំនះឧបសគ្គទាំងឡាយទាក់ទងទៅនឹងសិទ្ធិកាន់កាប់។ រដ្ឋគប្បីពិនិត្យមើលសេវារបស់ទីភ្នាក់ងារអនុវត្ត និង អាជ្ញាធរតុលាការ ព្រមទាំងណែនាំឱ្យមានការកែលម្អ ក្នុងករណីចាំបាច់។

៦.៤ រដ្ឋគប្បីធានាថាទីភ្នាក់ងារអនុវត្ត និងអាជ្ញាធរតុលាការ បម្រើប្រជាពលរដ្ឋទាំងមូល ដោយផ្តល់សេវាជូនប្រជាពលរដ្ឋគ្រប់រូប រួមទាំងប្រជាពលរដ្ឋដែលរស់នៅតំបន់ដាច់ស្រយាលផងដែរ។ សេវាគប្បីផ្តល់ជូនឱ្យបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្របដែលមានក្នុងស្រុក ដើម្បីបង្កើនប្រសិទ្ធភាព និង លទ្ធភាពទទួលបានសេវា។ គប្បីបង្កើតគោលការណ៍ណែនាំផ្ទៃក្នុង ដើម្បីឱ្យបុគ្គលិកអាចអនុវត្តគោលនយោបាយ និងច្បាប់នានា ក្នុងលក្ខណៈមួយដែលអាចទុកចិត្តបាន និងប្រកបដោយសង្គតភាព។ នីតិវិធីគប្បីមានលក្ខណៈសាមញ្ញ ដោយមិនបង្កការគម្រាមកំហែងដល់សុវត្ថិភាពកាន់កាប់ ឬ គុណភាពនៃយុត្តិធម៌។ ឯកសារពន្យល់ គប្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាភាសាសមស្រប និង ប្រាប់អ្នកប្រើប្រាស់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ។

៦.៥ រដ្ឋគប្បីអភិវឌ្ឍគោលនយោបាយ និងច្បាប់នានា តាមភាពសមស្រប ដើម្បីលើកកម្ពស់ការចែករំលែកព័ត៌មានអំពីទីកន្លែង និង ព័ត៌មានស្តីពីសិទ្ធិកាន់កាប់ សម្រាប់រដ្ឋ និងទីភ្នាក់ងារអនុវត្ត ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀត សង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សា និង សាធារណជនទូទៅ ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ បទដ្ឋានជាតិ គប្បីអភិវឌ្ឍសម្រាប់ការប្រើប្រាស់ព័ត៌មានរួមគ្នា ដោយពិចារណាទៅលើបទដ្ឋានតំបន់ និង អន្តរជាតិ។

៦.៦ រដ្ឋ និង ភាគីដទៃទៀត គប្បីពិចារណារកវិធានការបន្ថែមដើម្បីគាំទ្រក្រុមជនងាយរងគ្រោះ ឬ ក្រុមជនដែលគេមើលរំលង ដែលមិនអាចទទួលបានសេវារដ្ឋបាល និងសេវាតុលាការ។ វិធានការទាំងនេះ គប្បីរួមមានការជួយគាំទ្រផ្នែកច្បាប់ ដូចជា ជំនួយផ្នែកច្បាប់ដែលអាចឱ្យពួកគេលៃលកប្រើប្រាស់បាន ព្រមទាំងអាចរួមមានផងដែរនូវការផ្តល់សេវាជំនួយការមេធាវី ឬ ជំនួយការវាស់ដី និងសេវាចល័ត សម្រាប់សហគមន៍ដាច់ស្រយាល និង ជនជាតិដើមភាគតិចដែលចល័ត។

៦.៧ រដ្ឋគប្បីលើកទឹកចិត្តឱ្យទីភ្នាក់ងារអនុវត្ត និង អាជ្ញាធរតុលាការ បណ្តុះវប្បធម៌មួយដែលផ្អែកលើសេវា និងឥរិយាបថសីលធម៌។ ស្ថាប័ន និងអាជ្ញាធរតុលាការ គប្បីរិះរកមតិកែលម្អឱ្យបានទៀងទាត់ ដូចជា តាមរយៈការស្ទង់មតិ និងក្រុមគោលដៅ ដើម្បីលើកកម្ពស់បទដ្ឋាន និង កែលម្អការផ្តល់សេវា ដើម្បីបំពេញតាមការចង់បាន និង ដើម្បីបំពេញសេចក្តីត្រូវការថ្មី។ ស្ថាប័ន និងអាជ្ញាធរតុលាការគប្បីបោះពុម្ពផ្សាយបទដ្ឋានស្តាដែការងារ និង របាយការណ៍អំពីលទ្ធផលឱ្យបានទៀងទាត់។ អ្នកប្រើប្រាស់ គប្បីមានមធ្យោបាយដោះស្រាយបណ្តឹង នៅក្នុងទីភ្នាក់ងារអនុវត្តដូចជាតាមរយៈការត្រួតពិនិត្យពីផ្នែករដ្ឋបាល ឬ ការត្រួតពិនិត្យពីខាងក្រៅ ដូចជាតាមរយៈការត្រួតពិនិត្យឯករាជ្យ ឬ តាមរយៈអ្នកស៊ើបអង្កេតសាធារណៈឯករាជ្យ (ombudsman)។

៦.៨ សមាគមវិជ្ជាជីវៈដែលពាក់ព័ន្ធសម្រាប់សេវាទៅនឹងការកាន់កាប់ គប្បីអភិវឌ្ឍ ផ្សព្វផ្សាយ និង តាមដានការអនុវត្តន៍ដោយឥរិយាបថសីលធម៌កម្រិតខ្ពស់។ ភាគីវិស័យសាធារណៈ និងវិស័យឯកជន គប្បីប្រកាន់ខ្ជាប់នូវបទដ្ឋានសីលធម៌សមស្រប និង ត្រូវទទួលរងវិធានការវិន័យ ក្នុងករណីមានការរំលោភបំពាន។ ក្នុងករណីដែលមិនមានសមាគមប្រភេទនេះ រដ្ឋគប្បីធានាឱ្យបាននូវបរិយាកាសមួយដែលអំណោយផលដល់ការបង្កើតសមាគមទាំងនេះ។

៦.៩ រដ្ឋ និងតួអង្គមិនមែនរដ្ឋ គប្បីខិតខំទប់ស្កាត់អំពើពុករលួយទាក់ទងទៅនឹងសិទ្ធិកាន់កាប់។ រដ្ឋគប្បីធ្វើដូច្នេះ ជាពិសេសតាមរយៈការពិគ្រោះយោបល់ និងការចូលរួម វិធាននៃច្បាប់ តម្លាភាព និងគណនេយ្យភាព។ រដ្ឋគប្បីអនុម័ត និង ប្រតិបត្តិវិធានការប្រឆាំងអំពើពុករលួយ រួមទាំងការអនុវត្តន៍ប្រព័ន្ធត្រួតពិនិត្យនិងតុល្យភាព ការកម្រិតការប្រើប្រាស់អំណាចដោយអាជ្ញាកណ្តាល ការដោះស្រាយទំនាស់ផលប្រយោជន៍ និង ការអនុម័តវិធាន និងបទប្បញ្ញត្តិច្បាស់លាស់។ រដ្ឋគប្បីផ្តល់នូវការពិនិត្យមើលខាងរដ្ឋបាល និង/ឬ តុលាការលើសេចក្តីសម្រេចចិត្តរបស់ទីភ្នាក់ងារអនុវត្ត។ បុគ្គលិកដែលធ្វើការលើរដ្ឋបាលនៃការកាន់កាប់គប្បីទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន។ ពួកគេគប្បីទទួលបានការផ្តល់មធ្យោបាយបំពេញកាតព្វកិច្ចខ្លួនប្រកបដោយប្រសិទ្ធភាព។ ពួកគេគប្បីទទួលបានកិច្ចការពារប្រឆាំងនឹងការជ្រៀតជ្រែកក្នុងកាតព្វកិច្ចពួកគេ និង ពីការសងសឹកចំពោះការរាយការណ៍អំពីអំពើពុករលួយ។

# ជំពូកទី ៣

## ការទទួលស្គាល់ស្របច្បាប់ និង ការបែងចែកសិទ្ធិកាន់កាប់ និង ភាតព្វកិច្ចនានា

ជំពូកនេះចែងពីអភិបាលកិច្ចលើការកាន់កាប់ដី ជលផល និង ព្រៃឈើ ទាក់ទងទៅនឹងការទទួលស្គាល់ស្របច្បាប់នូវសិទ្ធិកាន់កាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ក៏ដូចជាសិទ្ធិកាន់កាប់ក្រៅប្រព័ន្ធ និង ការបែងចែកដំបូងនូវសិទ្ធិកាន់កាប់ដី ជលផល និង ព្រៃឈើ ដែលជាកម្មសិទ្ធិរបស់វិស័យសាធារណៈ ឬ គ្រប់គ្រងដោយវិស័យសាធារណៈ។

### ៧. វិធានការការពារ

៧.១ នៅពេលរដ្ឋទទួលស្គាល់ ឬ បែងចែកសិទ្ធិកាន់កាប់ដី ជលផល និង ព្រៃឈើ រដ្ឋគប្បីបង្កើតដោយអនុលោមតាមច្បាប់ជាតិ នូវវិធានការការពារដើម្បីជៀសវាងការរំលោភ ឬ ការរំលត់សិទ្ធិកាន់កាប់របស់អ្នកដទៃ រួមទាំងសិទ្ធិកាន់កាប់ស្របច្បាប់ ដែលបច្ចុប្បន្នមិនត្រូវបានការពារដោយច្បាប់។ ជាពិសេស វិធានការការពារ គប្បីការពារស្ត្រី និងជនងាយរងគ្រោះដែលមានសិទ្ធិកាន់កាប់បន្ទាប់បន្សំ ដូចជាសិទ្ធិប្រមូលផលជាដើម។

៧.២ រដ្ឋគប្បីធានាថា រាល់សកម្មភាពទាំងអស់ទាក់ទងទៅនឹងការទទួលស្គាល់ស្របច្បាប់ និងការបែងចែកសិទ្ធិកាន់កាប់ និង កាតព្វកិច្ចនានា មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។

៧.៣ ក្នុងករណីដែលរដ្ឋមានឆន្ទៈទទួលស្គាល់ ឬ បែងចែកសិទ្ធិកាន់កាប់ ជាបឋម រដ្ឋគប្បីកំណត់អត្តសញ្ញាណសិទ្ធិកាន់កាប់ដែលមានស្រាប់ និងសាមីជនដែលមានសិទ្ធិទាំងអស់ ទោះបីជាមានចុះបញ្ជីឬមិនមានចុះបញ្ជីក្តី។ ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ម្ចាស់កម្មសិទ្ធិខ្នាតតូច និង អ្នកដែលអាចរងផលប៉ះពាល់ គប្បីត្រូវបានរាប់បញ្ចូលក្នុងកិច្ចដំណើរការពិគ្រោះយោបល់ ស្របតាមកថាខណ្ឌ ៣ខ ៦ និង ៩.៩។ រដ្ឋគប្បីផ្តល់លទ្ធភាពទទួលបានយុត្តិធម៌ ស្របតាមកថាខណ្ឌ ៤.៩ ប្រសិនបើប្រជាពលរដ្ឋជឿថាសិទ្ធិកាន់កាប់របស់ពួកគេមិនត្រូវបានទទួលស្គាល់។

៧.៤ រដ្ឋគប្បីធានាថា ស្ត្រី និងបុរស ទទួលសិទ្ធិដូចគ្នា នៅក្នុងសិទ្ធិកាន់កាប់ថ្មីដែលទើបត្រូវបានទទួលស្គាល់ និង ធានាថាសិទ្ធិទាំងនោះត្រូវបានឆ្លុះបញ្ចាំងក្នុងការចុះបញ្ជី។ ក្នុងករណីដែលអាចធ្វើទៅបាន ការទទួលស្គាល់ស្របច្បាប់ និង ការបែងចែកសិទ្ធិកាន់កាប់របស់បុគ្គល គ្រួសារ និងសហគមន៍ គប្បីត្រូវធ្វើជាប្រព័ន្ធ ដោយដំណើរការពីតំបន់មួយទៅតំបន់មួយ ស្របតាមអាទិភាពជាតិ ដើម្បីផ្តល់ជូនជនក្រីក្រ និង ជនងាយរងគ្រោះនូវកាលានុវត្តភាពពេញលេញក្នុងការទទួលបានការទទួលស្គាល់ស្របច្បាប់លើសិទ្ធិកាន់កាប់របស់គេ។ ការជួយគាំទ្រផ្នែកច្បាប់ គប្បីផ្តល់ជូនដល់ជនក្រីក្រ និងជនងាយរងគ្រោះជាពិសេស។ គប្បីប្រើប្រាស់អភិក្រមសមស្របក្នុងមូលដ្ឋាន ដើម្បីបង្កើនតម្លាភាព នៅពេលដែលការចុះបញ្ជីអំពីសិទ្ធិកាន់កាប់ត្រូវបានបង្កើតឡើងដំបូង រួមទាំងការកំណត់ផែនទីសិទ្ធិកាន់កាប់ផងដែរ។

៧.៥ រដ្ឋគប្បីធានាថា ប្រជាពលរដ្ឋទាំងឡាយដែលសិទ្ធិកាន់កាប់របស់ពួកគេត្រូវបានទទួលស្គាល់ ឬ ត្រូវបានបែងចែកជូននូវសិទ្ធិកាន់កាប់ថ្មី មានចំណេះដឹងពេញលេញអំពីសិទ្ធិរបស់គេ ក៏ដូចជាកាតព្វកិច្ចរបស់ពួកគេ។ ក្នុងករណីចាំបាច់ រដ្ឋគប្បីផ្តល់ការជួយគាំទ្រជូនប្រជាពលរដ្ឋទាំងនេះ ដើម្បីឱ្យពួកគេអាចអនុវត្តសិទ្ធិកាន់កាប់ និង បំពេញកាតព្វកិច្ចរបស់ពួកគេ ។

៧.៦ ក្នុងករណីដែលមិនអាចផ្តល់ការទទួលស្គាល់ស្របច្បាប់លើសិទ្ធិកាន់កាប់ រដ្ឋគប្បីទប់ស្កាត់ការបណ្តេញចេញដោយបង្ខំ ដែលមិនមានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួន ក្រោមច្បាប់ជាតិ និង អន្តរជាតិ និង ស្របតាមស្មារតីនៃគោលការណ៍ណែនាំទាំងនេះ។

៣

## ៨. ដីសាធារណៈ ជលផល និង ព្រៃឈើសាធារណៈ

៨.១ ក្នុងករណីដែលរដ្ឋជាម្ចាស់កម្មសិទ្ធិ ឬ ត្រួតត្រាដី ជលផល និង ព្រៃឈើ រដ្ឋគប្បីកំណត់ការប្រើប្រាស់ និងការត្រួតត្រាលើធនធានទាំងនេះ ដោយគិតគូរដល់គោលបំណងទូលំទូលាយអំពីផ្នែកសង្គម សេដ្ឋកិច្ច និង បរិស្ថាន។ រដ្ឋគប្បីធានាថា រាល់សកម្មភាពទាំងអស់មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។

៨.២ ក្នុងករណីដែលរដ្ឋជាម្ចាស់កម្មសិទ្ធិ ឬ ត្រួតត្រាដី ជលផល និង ព្រៃឈើ សិទ្ធិកាន់កាប់ស្របច្បាប់របស់បុគ្គល និង សហគមន៍ រួមទាំង ក្នុងករណីដែលអាចអនុវត្តបាន បុគ្គល និងសហគមន៍ទាំងឡាយដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី គប្បីត្រូវបានទទួលស្គាល់ គោរព និង ការពារស្របតាមកាតព្វកិច្ចជាធរមាន ក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និង អន្តរជាតិដែលអាចយកមកអនុវត្តបាន។ ក្នុងន័យនេះ លក្ខណៈវិនិច្ឆ័យនៃសិទ្ធិកាន់កាប់ស្របច្បាប់ គប្បីត្រូវកំណត់ឱ្យបានច្បាស់លាស់ និងផ្សព្វផ្សាយ តាមរយៈកិច្ចដំណើរការប្រកបដោយតម្លាភាព និង ស្របតាមច្បាប់ជាតិ។

៨.៣ ដោយកត់សម្គាល់ឃើញថាមានដី ជលផល និង ព្រៃឈើជាកម្មសិទ្ធិសាធារណៈ ដែលត្រូវបានប្រើប្រាស់ និងគ្រប់គ្រងដោយសមូហភាព (ក្នុងបរិបទជាតិខ្លះ ត្រូវបានគេហៅថាទ្រព្យសម្បត្តិរួម) ក្នុងករណីដែលអាចអនុវត្តបាន រដ្ឋគប្បីទទួលស្គាល់ និង ការពារដី ជលផល និង ព្រៃឈើដែលជាកម្មសិទ្ធិសាធារណៈទាំងនេះ ព្រមទាំងប្រព័ន្ធប្រើប្រាស់ និង គ្រប់គ្រងដែលពាក់ព័ន្ធជាសមូហភាព រួមទាំងនៅក្នុងកិច្ចដំណើរការនៃការបែងចែកដោយរដ្ឋ។

៨.៤ រដ្ឋគប្បីខិតខំបង្កើតព័ត៌មានបច្ចុប្បន្នភាពនៃការកាន់កាប់ស្តីពីដី ជលផល និង ព្រៃឈើ ដែលរដ្ឋជាម្ចាស់កម្មសិទ្ធិ ឬ ត្រួតត្រា ដោយបង្កើត និងរក្សាបញ្ជីសារពើភ័ណ្ឌដែលអាចរកប្រើប្រាស់បាន។ បញ្ជីសារពើភ័ណ្ឌទាំងនេះ គប្បីកត់ត្រាទីភ្នាក់ងារទទួលខុសត្រូវផ្នែករដ្ឋបាល ព្រមទាំងសិទ្ធិកាន់កាប់ស្របច្បាប់ណាដែលគ្រប់គ្រងដោយជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី និង វិស័យឯកជន។ ក្នុងករណីដែលអាចធ្វើទៅបាន រដ្ឋគប្បីធានាថា សិទ្ធិកាន់កាប់ដែលគ្រប់គ្រងដោយសាធារណៈ ត្រូវបានចុះបញ្ជីជាមួយសិទ្ធិកាន់កាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ព្រមទាំងវិស័យឯកជន នៅក្នុងប្រព័ន្ធចុះបញ្ជីតែមួយ ឬ ត្រូវបានតភ្ជាប់ទៅនឹងសិទ្ធិកាន់កាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី និង វិស័យឯកជន ដោយក្របខ័ណ្ឌរួមមួយ។

៨.៥ រដ្ឋគប្បីកំណត់ថាតើដី ជលផល និង ព្រៃឈើមួយណាដែលខ្លួនជាម្ចាស់កម្មសិទ្ធិ ឬ ត្រួតត្រាដែលនឹងត្រូវរក្សាទុក និងប្រើប្រាស់ដោយវិស័យសាធារណៈ និង ដី ជលផល និង ព្រៃឈើមួយណាដែលនឹងត្រូវបែងចែកសម្រាប់ការប្រើប្រាស់ដោយអ្នកដទៃ និង ក្រោមលក្ខខណ្ឌណាខ្លះ។

៨.៦ រដ្ឋគប្បីអភិវឌ្ឍ និង ផ្សព្វផ្សាយគោលនយោបាយស្តីពីការប្រើប្រាស់ និងការត្រួតត្រាដី ជលផល និង ព្រៃឈើ ដែលត្រូវរក្សាទុកដោយវិស័យសាធារណៈ និង គប្បីខិតខំអភិវឌ្ឍគោលនយោបាយនានាដែលជំរុញការបែងចែកប្រកបដោយសមធម៌នូវអត្ថប្រយោជន៍ពីដី ជលផល និង ព្រៃឈើជាកម្មសិទ្ធិរបស់រដ្ឋ។ គោលនយោបាយទាំងនេះ គប្បីគិតគូរដល់សិទ្ធិកាន់កាប់របស់អ្នកដទៃ ហើយជនណាដែលអាចទទួលរងផលប៉ះពាល់ គប្បីត្រូវរាប់បញ្ចូលក្នុងកិច្ចដំណើរការពិគ្រោះយោបល់ស្របតាមស្មារតីនៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ។ រដ្ឋបាលនៃធនធានទាំងនេះ និង ប្រតិបត្តិការនានាទាក់ទងទៅនឹងធនធានទាំងនេះ គប្បីអនុវត្តក្នុងលក្ខណៈមួយដែលមានប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព ដើម្បីបំពេញគោលនយោបាយសាធារណៈ។

៨.៧ រដ្ឋគប្បីអភិវឌ្ឍ និង ផ្សព្វផ្សាយគោលនយោបាយស្តីពីការបែងចែកសិទ្ធិកាន់កាប់ជូនអ្នកដទៃ និង ក្នុងករណីសមស្រប រដ្ឋគប្បីផ្ទេរការទទួលខុសត្រូវផ្នែកអភិបាលកិច្ចលើការកាន់កាប់។ គោលនយោបាយសម្រាប់ការបែងចែកសិទ្ធិកាន់កាប់ គប្បីមានសង្គតភាពទៅនឹងគោលដៅទូលំទូលាយអំពីផ្នែកសង្គម សេដ្ឋកិច្ច និង បរិស្ថាន។ សហគមន៍មូលដ្ឋានដែលបានប្រើប្រាស់ដី ជលផល និង ព្រៃឈើ បែបប្រពៃណី គប្បីទទួលបានការពិចារណាសមស្របក្នុងការបែងចែកសិទ្ធិកាន់កាប់ឡើងវិញ។ គោលនយោបាយគប្បីគិតគូរដល់សិទ្ធិកាន់កាប់របស់អ្នកដទៃ ហើយជនណាដែលអាចទទួលរងផលប៉ះពាល់ គប្បីត្រូវបានរាប់បញ្ចូលក្នុងការពិគ្រោះយោបល់ ការចូលរួម និង ដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ គោលនយោបាយទាំងនេះ គប្បីធានាថាការបែងចែកសិទ្ធិកាន់កាប់នឹងមិនគម្រាមកំហែងដល់ជីវភាពរបស់ប្រជាពលរដ្ឋ ដោយធ្វើឱ្យពួកគេបាត់បង់លទ្ធភាពស្របច្បាប់ក្នុងការទទួលបានធនធានទាំងនេះឡើយ។

៨.៨ រដ្ឋមានអំណាចបែងចែកសិទ្ធិកាន់កាប់ក្នុងទម្រង់ផ្សេងៗ តាំងពីការប្រើប្រាស់មានកម្រិតរហូតដល់កម្មសិទ្ធិពេញលេញ។ គោលនយោបាយគប្បីទទួលស្គាល់សិទ្ធិកាន់កាប់ និង សាមីជនដែលមានសិទ្ធិកាន់កាប់។ គោលនយោបាយគប្បីកំណត់មធ្យោបាយនៃការបែងចែកសិទ្ធិ ដូចជាការបែងចែកផ្អែកលើការប្រើប្រាស់កន្លងមក ឬ មធ្យោបាយផ្សេងទៀត។ ក្នុងករណីចាំបាច់ អ្នកដែលទទួលបានការបែងចែកសិទ្ធិកាន់កាប់ គប្បីទទួលបានការគាំទ្រ ដើម្បីឱ្យពួកគេអាចអនុវត្តសិទ្ធិរបស់ពួកគេបាន។ រដ្ឋគប្បីកំណត់ នូវទម្រង់ណាមួយនៃការត្រួតត្រាលើដី ជលផល និង ព្រៃឈើដែលត្រូវបានបែងចែក ដើម្បីរក្សាទុក ។

៨.៩ រដ្ឋគប្បីបែងចែកសិទ្ធិកាន់កាប់ និង ផ្ទេរអភិបាលកិច្ចលើការកាន់កាប់ ប្រកបដោយតម្លាភាព និងមានការចូលរួម ដោយប្រើប្រាស់នីតិវិធីសាមញ្ញដែលមានលក្ខណៈច្បាស់លាស់ អាចយកប្រើប្រាស់បាន និង ងាយយល់សម្រាប់មនុស្សគ្រប់រូប ជាពិសេសជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី។ ព័ត៌មានជាភាសាសមស្រប គប្បីផ្តល់ជូនគ្រប់មុខសញ្ញាចូលរួម រាប់បញ្ចូលតាមរយៈសារដែលគិតគូរដល់យេនឌ័រ។ ក្នុងករណីដែលអាចធ្វើទៅបាន រដ្ឋគប្បីធានាថាសិទ្ធិកាន់កាប់ដែលទើបបែងចែកថ្មី ត្រូវបានចុះបញ្ជីជាមួយសិទ្ធិកាន់កាប់ផ្សេងទៀត ក្នុងប្រព័ន្ធចុះបញ្ជីតែមួយ ឬ ត្រូវបានតភ្ជាប់ដោយក្របខ័ណ្ឌរួមមួយ។ រដ្ឋ និងតួអង្គមិនមែនរដ្ឋ គប្បីខិតខំទប់ស្កាត់ថែមទៀតនូវអំពើពុករលួយក្នុងការបែងចែកសិទ្ធិកាន់កាប់។

៨.១០ យោងតាមលទ្ធភាពធនធាន រដ្ឋគប្បីធានាថា ស្ថាប័នមានសមត្ថកិច្ចដែលទទួលខុសត្រូវផ្នែកដី ជលផល និង ព្រៃឈើមានសមត្ថភាពធនធានមនុស្ស សមត្ថភាពរូបវន្ត និង សមត្ថភាពហិរញ្ញវត្ថុ ព្រមទាំងសមត្ថភាពក្នុងទម្រង់ដទៃទៀត។ ក្នុងករណីដែលការទទួលខុសត្រូវផ្នែកអភិបាលកិច្ចលើការកាន់កាប់ត្រូវបានផ្ទេរ អ្នកទទួលគប្បីទទួលការបណ្តុះបណ្តាល និង ការគាំទ្រផ្សេងទៀត ដើម្បីឱ្យពួកគេអាចបំពេញការទទួលខុសត្រូវទាំងនោះបាន។

៨.១១ រដ្ឋគប្បីតាមដានលទ្ធផលនៃកម្មវិធីបែងចែក រួមមានផលប៉ះពាល់ផ្សេងគ្នាតាមយេនឌ័រចំពោះសន្តិសុខស្បៀង និង ការលុបបំបាត់ភាពក្រីក្រ ក៏ដូចជាផលប៉ះពាល់នៃកម្មវិធីទៅលើគោលដៅសង្គម សេដ្ឋកិច្ច និង បរិស្ថាន ព្រមទាំងណែនាំវិធានការកែតម្រូវ ទៅតាមភាពចាំបាច់។

## ៩. ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី

៩.១ តួអង្គរដ្ឋ និងមិនមែនរដ្ឋ គប្បីទទួលស្គាល់ថាដី ជលផល និង ព្រៃឈើ មានគុណតម្លៃផ្នែកសង្គម វប្បធម៌ ជំនឿ សេដ្ឋកិច្ច បរិស្ថាន និង នយោបាយ ចំពោះជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី។

៩.២ ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ដែលអនុវត្តស្វ័យអភិបាលកិច្ចលើដី ជលផល និង ព្រៃឈើ គប្បីជំរុញ និងផ្តល់សិទ្ធិប្រកបដោយសមធម៌ ស្មេរភាព និងនិរន្តរភាព ចំពោះធនធានទាំងនោះ ដោយយកចិត្តទុកដាក់ជាពិសេស លើការផ្តល់លទ្ធភាពប្រើប្រាស់ប្រកបដោយសមធម៌ជូនស្ត្រី។ ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់សមាជិក បុរស ស្ត្រី និង យុវជនទាំងអស់ ក្នុងសេចក្តីសម្រេចចិត្តអំពីប្រព័ន្ធកាន់កាប់របស់ពួកគេ គប្បីត្រូវបានជំរុញតាមរយៈស្ថាប័នមូលដ្ឋាន ឬ ស្ថាប័នប្រពៃណីរបស់ពួកគេ រួមទាំងករណីនៃប្រព័ន្ធកាន់កាប់ជាសមូហភាព។ ក្នុងករណីចាំបាច់ សហគមន៍គប្បីទទួលបានជំនួយដើម្បីបង្កើន

សមត្ថភាពរបស់សមាជិកខ្លួន សំដៅចូលរួមឱ្យបានពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្ត និង អភិបាលកិច្ចលើប្រព័ន្ធកាន់កាប់របស់ពួកគេ។

៩.៣ រដ្ឋគប្បីធានាថារាល់សកម្មភាពទាំងអស់ ត្រូវមានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួន ក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។ ក្នុងករណីជនជាតិដើមភាគតិច រដ្ឋគប្បីបំពេញកាតព្វកិច្ចពាក់ព័ន្ធរបស់ខ្លួន និង ការប្តេជ្ញាដោយស្ម័គ្រចិត្ត ដើម្បីការពារ លើកកម្ពស់ និង អនុវត្តសិទ្ធិមនុស្ស រួមមាន សិទ្ធិមនុស្សពីអនុសញ្ញាអង្គការពលកម្មអន្តរជាតិ (លេខ ១៦៩) ស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធក្នុងប្រទេសឯករាជ្យ អនុសញ្ញាស្តីពីជីវចម្រុះ និង សេចក្តីថ្លែងការណ៍អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ទៅតាមភាពសមស្រប។

៩.៤ រដ្ឋគប្បីផ្តល់ការទទួលស្គាល់ និង កិច្ចការពារសមស្រប ចំពោះសិទ្ធិកាន់កាប់ស្របច្បាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ស្របតាមកាតព្វកិច្ចជាធរមាន ក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។ ការទទួលស្គាល់នេះ គប្បីរាប់បញ្ចូលដី ជលផល និង ព្រៃឈើទាំងឡាយដែលត្រូវបានប្រើប្រាស់ដោយសហគមន៍ និង ដី ជលផល និង ព្រៃឈើទាំងឡាយដែលត្រូវបានចែករំលែក ព្រមទាំងគោរពតាមគោលការណ៍ទូទៅនៃអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវ។ ព័ត៌មានស្តីពីការទទួលស្គាល់នេះ គប្បីផ្សព្វផ្សាយនៅកន្លែងដែលគេងាយទទួលបាន ក្នុងទម្រង់សមស្របមួយដែលងាយយល់ ជាភាសាសមស្រប។

៩.៥ ក្នុងករណីដែលជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី មានសិទ្ធិកាន់កាប់ស្របច្បាប់ចំពោះដីបុព្វបុរសដែលពួកគេរស់នៅ រដ្ឋគប្បីទទួលស្គាល់ និង ការពារសិទ្ធិកាន់កាប់ទាំងនេះ។ ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី មិនគួរគប្បីត្រូវបានបណ្តេញចេញដោយបង្ខំពីដីបុព្វបុរសទាំងនេះឡើយ។

៩.៦ រដ្ឋគប្បីពិចារណាកែសម្រួលក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និង ក្របខ័ណ្ឌស្ថាប័នរបស់ខ្លួន ដើម្បីទទួលស្គាល់ប្រព័ន្ធកាន់កាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី។ ក្នុងករណីដែលកំណែទម្រង់រដ្ឋធម្មនុញ្ញ ឬ កំណែទម្រង់ច្បាប់ ពង្រឹងទៅលើសិទ្ធិរបស់ស្ត្រី និង នាំឱ្យពួកគេមានទំនាស់ជាមួយទំនៀមទម្លាប់ នោះគ្រប់ភាគីទាំងអស់គប្បីសហការគ្នា ដើម្បីសម្របសម្រួលការផ្លាស់ប្តូរទាំងនេះនៅក្នុងប្រព័ន្ធកាន់កាប់តាមទំនៀមទម្លាប់។

៩.៧ ក្នុងការតាក់តែងគោលនយោបាយ និងច្បាប់ ស្តីពីការកាន់កាប់ រដ្ឋគប្បីគិតគូរដល់គុណតម្លៃផ្នែកសង្គម វប្បធម៌ ជំនឿ សេដ្ឋកិច្ច និង បរិស្ថាននៃដី ជលផល និង ព្រៃឈើ ដែលស្ថិតនៅក្រោមប្រព័ន្ធកាន់កាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី។ គប្បីមានការចូលរួមពេញលេញ និង ប្រកបដោយប្រសិទ្ធភាពរបស់សមាជិកទាំងអស់ ឬ តំណាងនៃសហគមន៍រងផលប៉ះពាល់ រួមមានសមាជិកងាយរងគ្រោះ និង សមាជិកដែលត្រូវគេមើលរំលង នៅពេលអភិវឌ្ឍគោលនយោបាយ និង ច្បាប់នានាទាក់ទងទៅនឹងប្រព័ន្ធកាន់កាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី។

៩.៨ រដ្ឋគប្បីការពារជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ប្រឆាំងនឹងការប្រើប្រាស់ដី ជលផល និង ព្រៃឈើរបស់ពួកគេ ពីសំណាក់អ្នកដទៃដោយគ្មានការអនុញ្ញាត។ ក្នុងករណីដែលសហគមន៍មួយមិនបដិសេធ រដ្ឋគប្បីជួយចងក្រងឯកសារជាផ្លូវការ និង ផ្សព្វផ្សាយព័ត៌មានស្តីពីប្រភេទ និងទីតាំងនៃដី ជលផល និង ព្រៃឈើដែលត្រូវបានប្រើប្រាស់ និងត្រួតត្រាដោយសហគមន៍នោះ។ ក្នុងករណីសិទ្ធិកាន់កាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណីត្រូវបានចងក្រងជាឯកសារជាផ្លូវការ សិទ្ធិកាន់កាប់ទាំងនេះគប្បីត្រូវបានចុះបញ្ជីជាមួយសិទ្ធិកាន់កាប់របស់សាធារណៈ ឯកជន និង សហគមន៍ផ្សេងទៀត ដើម្បីទប់ស្កាត់ការទាមទារជណ្តើមយក។

៩.៩ រដ្ឋ និង ភាគីដទៃទៀតគប្បីធ្វើការពិគ្រោះយោបល់ប្រកបដោយសុឆន្ទៈ ជាមួយជនជាតិដើមភាគតិច មុនពេលផ្តួចផ្តើមគម្រោងណាមួយ ឬ មុនពេលអនុម័ត និងអនុវត្តវិធានការច្បាប់ ឬ រដ្ឋបាលណាមួយ ដែលប៉ះពាល់ដល់ធនធានទាំងឡាយដែលសហគមន៍មានសិទ្ធិកាន់កាប់។ គម្រោងទាំងនេះ គប្បីផ្អែកលើការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព និង អត្ថន័យ ជាមួយជនជាតិដើមភាគតិច តាមរយៈស្ថាប័នតំណាងពួកគេផ្ទាល់ ដើម្បីទទួលបានការយល់ព្រមដោយសេរីជាមុន និង ដោយមានព័ត៌មានគ្រប់គ្រាន់ពីពួកគេ ស្របតាមសេចក្តីថ្លែងការណ៍អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច និង ដោយគោរពតាមជំហរ និងការយល់ដោយឡែករបស់រដ្ឋនីមួយៗ។ ការពិគ្រោះយោបល់ និង កិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តគប្បីធ្វើឡើងដោយគ្មានការបំភិតបំភ័យ និង ត្រូវធ្វើក្នុងបរិយាកាសទុកចិត្តគ្នា។ គោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួម ដូចមានចែងក្នុងកថាខ័ណ្ឌ ៣ខ.៦ គប្បីត្រូវអនុវត្ត ក្នុងករណីសហគមន៍ផ្សេងទៀតដែលត្រូវបានពណ៌នាក្នុងផ្នែកនេះ។

៩.១០ ក្នុងករណីចាំបាច់ រដ្ឋ និងភាគីមិនមែនរដ្ឋ រួមជាមួយស្ថាប័នតំណាងនៃសហគមន៍រងផលប៉ះពាល់ និង ដោយសហការជាមួយសហគមន៍រងផលប៉ះពាល់ គប្បីខិតខំផ្តល់ជំនួយបច្ចេកទេស និងជំនួយផ្នែកច្បាប់ ជូនដល់សហគមន៍រងផលប៉ះពាល់ ក្នុងការចូលរួមការអភិវឌ្ឍគោលនយោបាយ ច្បាប់ និង គម្រោងស្តីពីការកាន់កាប់ ក្នុងលក្ខណៈមិនមានការរើសអើង និង គិតគូរដល់យេនឌ័រ។

៩.១១ រដ្ឋគប្បីគោរព និង ជំរុញអភិក្រមបែបទំនៀមទម្លាប់ដែលប្រើប្រាស់ដោយជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ចំពោះការដោះស្រាយវិវាទកាន់កាប់ ក្នុងសហគមន៍ ស្របតាមកាតព្វកិច្ចជាធរមានរបស់ខ្លួន អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតូបករណ៍តំបន់ និងអន្តរជាតិជាធរមាន។ ចំពោះដី ជលផល និង ព្រៃឈើទាំងឡាយដែលត្រូវបានប្រើប្រាស់ដោយសហគមន៍លើសពី មួយឡើងទៅ មធ្យោបាយនៃការដោះស្រាយវិវាទរវាងសហគមន៍ គប្បីត្រូវបានពង្រឹង ឬ អភិវឌ្ឍ។

៩.១២ រដ្ឋ និង ភាគីមិនមែនរដ្ឋ គប្បីខិតខំទប់ស្កាត់អំពើពុករលួយ ទាក់ទងទៅនឹងប្រព័ន្ធកាន់កាប់របស់ ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី តាមរយៈការពិគ្រោះយោបល់ និង ការចូលរួម និង ដោយការផ្តល់អំណាចដល់សហគមន៍។

## ១០. ការកាន់កាប់ក្រៅប្រព័ន្ធ

៣

១០.១ ក្នុងករណីដែលមានការកាន់កាប់ក្រៅប្រព័ន្ធលើដី ជលផល និង ព្រៃឈើ រដ្ឋគប្បីទទួលស្គាល់ ការកាន់កាប់ក្រៅព័ន្ធនោះ តាមរបៀបមួយដែលគោរពសិទ្ធិក្នុងប្រព័ន្ធស្របដែលមានស្រាប់តាម ច្បាប់ជាតិ និង តាមរបៀបនានាដែលទទួលស្គាល់ការពិតនៃស្ថានភាព និង ជំរុញសុខុមាលភាព ផ្នែកសង្គម សេដ្ឋកិច្ច និង បរិស្ថាន។ រដ្ឋគប្បីជំរុញគោលនយោបាយ និងច្បាប់ ដើម្បីផ្តល់ ការទទួលស្គាល់ចំពោះការកាន់កាប់ក្រៅប្រព័ន្ធនេះ។ កិច្ចដំណើរការបង្កើតគោលនយោបាយ និង ច្បាប់ទាំងនេះ គប្បីមានលក្ខណៈចូលរួម គិតគូរដល់យេនឌ័រ និង ខិតខំចាត់ឱ្យមានការជួយគាំទ្រ ផ្នែកបច្ចេកទេស និងច្បាប់ ជូនដល់សហគមន៍ និងបុគ្គលរងផលប៉ះពាល់ទាំងឡាយ។ ជាពិសេស រដ្ឋគប្បីទទួលស្គាល់ការលេចឡើងនូវការកាន់កាប់ក្រៅប្រព័ន្ធដែលកើតឡើងពី ការចំណាកស្រុកក្នុងទ្រង់ទ្រាយធំ។

១០.២ រដ្ឋគប្បីធានាថា រាល់សកម្មភាពទាំងអស់ទាក់ទងទៅនឹងការកាន់កាប់ក្រៅប្រព័ន្ធ មានសង្គតភាព ទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញា ដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និង អន្តរជាតិដែលអាចយកមក អនុវត្តបាន រួម ទាំង ការគិតគូរដល់សិទ្ធិមានលំនៅឋានគ្រប់គ្រាន់ ទៅតាមភាពសមស្រប។

១០.៣ នៅពេលដែល រដ្ឋផ្តល់ការទទួលស្គាល់ស្របច្បាប់ចំពោះការកាន់កាប់ក្រៅប្រព័ន្ធ ការទទួលស្គាល់ នេះគប្បីធ្វើតាមរយៈកិច្ចដំណើរការដោយមានការចូលរួម និងគិតគូរដល់យេនឌ័រ ដោយយកចិត្ត ទុកដាក់ដោយឡែកចំពោះអ្នកជួល។ ក្នុងការធ្វើដូច្នេះ រដ្ឋគប្បីយកចិត្តទុកដាក់ជាពិសេសចំពោះ កសិករ និង អ្នកផលិតស្បៀងខ្នាតតូច។ កិច្ចដំណើរការទាំងនេះ គប្បីសម្រួលលទ្ធភាពទទួលបាន សេវានីត្យានុកូលកម្ម និង ធ្វើឱ្យមានថ្លៃចំណាយអប្បបរមា។ រដ្ឋគប្បីខិតខំផ្តល់ការជួយគាំទ្រផ្នែក បច្ចេកទេស និងច្បាប់ជូនដល់សហគមន៍ និង អ្នកចូលរួម។

១០.៤ រដ្ឋគប្បីចាត់វិធានការសមស្របដើម្បីរឹតបន្តឹងការកាន់កាប់ក្រៅប្រព័ន្ធដែលបណ្តាលមកពីលក្ខខណ្ឌច្បាប់ និងរដ្ឋបាលដែលមានលក្ខណៈស្មុគ្រស្មាញហួសប្រមាណ សម្រាប់ការផ្លាស់ប្តូរការប្រើប្រាស់ដី និង ការអភិវឌ្ឍន៍លើដី។ លក្ខខណ្ឌ និងកិច្ចដំណើរការអភិវឌ្ឍន៍ គប្បីមានលក្ខណៈច្បាស់លាស់ សាមញ្ញ និង មានតម្លៃសមរម្យ ដើម្បីកាត់បន្ថយបន្ទុកនៃអនុលោមភាព។

១០.៥ រដ្ឋគប្បីខិតខំទប់ស្កាត់អំពើពុករលួយ ជាពិសេស តាមរយៈការបង្កើនតម្លាភាព ដោយតម្រូវឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្តមានគណនេយ្យភាព និង ដោយធានាថាសេចក្តីសម្រេចចិត្តមិនលំអៀងត្រូវបានអនុវត្តជាប្រញាប់។

១០.៦ ក្នុងករណីដែលមិនអាចផ្តល់ការទទួលស្គាល់ស្របច្បាប់ដល់ការកាន់កាប់ក្រៅប្រព័ន្ធ រដ្ឋគប្បីទប់ស្កាត់ការបណ្តេញចេញដោយបង្ខំដែលរំលោភកាតព្វកិច្ចជាធរមាន អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ និង ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធក្នុងផ្នែក ១៦។

៣

# ជំពូកទី ៤

## ការផ្ទេរ និង ការផ្លាស់ប្តូរផ្សេងទៀតនៃសិទ្ធិកាន់កាប់ និង ភាគពាក់ព័ន្ធនានា

ជំពូកនេះចែងពីអភិបាលកិច្ចលើការកាន់កាប់ដី ជលផល និង ព្រៃឈើ នៅពេលដែលសិទ្ធិជាធរមាន និងកាតព្វកិច្ចពាក់ព័ន្ធនានាត្រូវបានផ្ទេរ ឬ បែងចែកឡើងវិញ តាមរយៈវិធីស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្ត តាមរយៈទីផ្សារ ការប្រតិបត្តិការនៃសិទ្ធិកាន់កាប់ ដែលជាលទ្ធផលនៃការវិនិយោគ ការប្រមូលផ្តុំដី និង អភិក្រមកែតម្រូវឡើងវិញផ្សេងទៀត បដិទាន កំណែទម្រង់លើការបែងចែកដីឡើងវិញ ឬ អស្សាមិករណ៍។

### ១១. ទីផ្សារ

១១.១ ក្នុងករណីសមស្រប រដ្ឋគប្បីទទួលស្គាល់ និង សម្រួលទីផ្សារលក់ និងជួល ប្រកបដោយយុត្តិធម៌ និងតម្លាភាព ដែលជាមធ្យោបាយមួយនៃការផ្ទេរសិទ្ធិប្រើប្រាស់ និង កម្មសិទ្ធិលើដី ជលផល និង ព្រៃឈើ។ ក្នុងករណីដែលទីផ្សារសិទ្ធិកាន់កាប់មានដំណើរការ រដ្ឋគប្បីធានាថា រាល់សកម្មភាពទាំងអស់មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និងដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតុបករណ៍តំបន់ និង អន្តរជាតិដែលអាចយកមកអនុវត្តបាន។ ប្រតិបត្តិការនៃសិទ្ធិកាន់កាប់ចំពោះដី ជលផល និង ព្រៃឈើ គប្បីអនុលោមតាមបទប្បញ្ញត្តិជាតិស្តីពីការប្រើប្រាស់ដី និង មិនធ្វើឱ្យមានហានិភ័យដល់គោលដៅអភិវឌ្ឍន៍សំខាន់ៗ។

១១.២ រដ្ឋគប្បីសម្រួលកិច្ចប្រតិបត្តិការទីផ្សារឱ្យមានប្រសិទ្ធភាព និង តម្លាភាព ដើម្បីលើកកម្ពស់ការចូលរួមក្រោមលក្ខខណ្ឌ និង ឱកាសស្មើភាពគ្នា សម្រាប់ការផ្ទេរសិទ្ធិកាន់កាប់ដែលផ្តល់ប្រយោជន៍ទៅវិញទៅមក កាត់បន្ថយវិវាទ និងអស្ថេរភាព , លើកកម្ពស់ការប្រើប្រាស់ដី ជលផល និង ព្រៃឈើប្រកបដោយនិរន្តរភាព និងការអភិរក្សបរិស្ថាន , លើកកម្ពស់ការប្រើប្រាស់ប្រកបដោយយុត្តិធម៌ និងសមធម៌នូវធនធានទូទៅ ដែលទាក់ទងទៅនឹង ដី ជលផល និង ព្រៃឈើ ស្របតាមសន្ធិសញ្ញាជាធរមាន , ពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច និង បង្កើនការចូលរួមពីប្រជាពលរដ្ឋក្រីក្រ។ រដ្ឋគប្បីចាត់វិធានការដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និង ក្រុមជនងាយរងគ្រោះ ដែលអាចកើតឡើងជាអាទិ៍ ពីការជួញដូរដី ការប្រមូលផ្តុំដី និង ការរំលោភបំពានទៅលើទម្រង់នៃការកាន់កាប់បែបទំនៀមទម្លាប់ ។ រដ្ឋ និងភាគីដទៃទៀត គប្បីទទួលស្គាល់ថាគុណតម្លៃនានា ដូចជាគុណតម្លៃផ្នែកសង្គម វប្បធម៌ និង បរិស្ថាន ជាដើម មិនមែនសុទ្ធតែទទួលបានការគាំទ្រល្អប្រសើរដោយគ្មានការធ្វើនិយ័តកម្មទីផ្សារនោះទេ។ រដ្ឋគប្បីការពារផលប្រយោជន៍របស់សង្គមឱ្យបានទូលំទូលាយ តាមរយៈគោលនយោបាយ និង ច្បាប់សមស្រប ស្តីពីការកាន់កាប់។

១១.៣ រដ្ឋគប្បីបង្កើតគោលនយោបាយ ច្បាប់ និង ប្រព័ន្ធ និងស្ថាប័ននិយ័តកម្ម ដើម្បីធានាឱ្យបាននូវកិច្ចប្រតិបត្តិការទីផ្សារប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីផ្តល់លទ្ធភាពចូលរួមដោយគ្មានការរើសអើង និង ដើម្បីទប់ស្កាត់ការអនុវត្តគ្មានការប្រកួតប្រជែង។ រដ្ឋគប្បីសម្រួលនីតិវិធីរដ្ឋបាលដើម្បីដើម្បីជៀសវាងការរារាំងដល់ការចូលរួមនៅក្នុងទីផ្សារពីប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះបំផុត។

១១.៤ រដ្ឋ និងភាគីដទៃទៀតគប្បីធានាថា ព័ត៌មានស្តីពីប្រតិបត្តិការទីផ្សារ និង ព័ត៌មានស្តីពីតម្លៃទីផ្សារមានតម្លាភាព និង ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដោយគោរពតាមកម្រិតលក្ខខណ្ឌឯកជនភាព។ រដ្ឋគប្បីតាមដានព័ត៌មាននេះ និង ធ្វើសកម្មភាព ក្នុងករណីដែលទីផ្សារមានផលប៉ះពាល់អវិជ្ជមាន ឬ រារាំងការចូលរួមទីផ្សារដោយទូលំទូលាយ និង ដោយសមធម៌។

១១.៥ រដ្ឋគប្បីបង្កើតប្រព័ន្ធចុះបញ្ជីសមស្រប និងអាចទុកចិត្តបាន ដូចជាបញ្ជីដីធ្លីជាដើម ដែលផ្តល់ព័ត៌មានងាយទទួលបានស្តីពីសិទ្ធិកាន់កាប់ និង កាតព្វកិច្ចនានា ដើម្បីបង្កើនសុវត្ថិភាពកាន់កាប់ និង ដើម្បីកាត់បន្ថយថ្លៃចំណាយ និង ហានិភ័យនៃប្រតិបត្តិការ។

១១.៦ រដ្ឋគប្បីបង្កើតវិធានការការពារដើម្បីការពារសិទ្ធិកាន់កាប់ស្របច្បាប់របស់សហព័ទ្ធ សមាជិកគ្រួសារ និងអ្នកដទៃទៀត ដែលមិនត្រូវបានបង្ហាញជាសម៉ីជនមានសិទ្ធិកាន់កាប់នៅក្នុងប្រព័ន្ធចុះបញ្ជី ដូចជា បញ្ជីដីធ្លីជាដើម។

៤

១១.៧ ភាគីរដ្ឋ និង ភាគីមិនមែនរដ្ឋ គប្បីប្រកាន់ខ្ជាប់នូវបទដ្ឋានសីលធម៌ជាធរមាន។ ពួកគេគប្បីផ្សព្វផ្សាយ និង តាមដានការអនុវត្តន៍បទដ្ឋានទាំងនេះនៅក្នុងកិច្ចប្រតិបត្តិការទីផ្សារ ដើម្បីទប់ស្កាត់អំពើពុករលួយ ជាពិសេស តាមរយៈការផ្សាយពត៌មានជាសាធារណៈ។

១១.៨ ដោយយោងទៅតាមសារៈសំខាន់នៃអ្នកផលិតខ្នាតតូចសម្រាប់សន្តិសុខស្បៀងជាតិ និង ស្ថេរភាពសង្គម រដ្ឋគប្បីធានាថា នៅពេលសម្រួលកិច្ចប្រតិបត្តិការទីផ្សារប្រតិបត្តិការនៃការកាន់កាប់ រដ្ឋការពារសិទ្ធិកាន់កាប់របស់អ្នកផលិតខ្នាតតូច ។

## ១២. ការវិនិយោគ

១២.១ រដ្ឋ និង ភាគីមិនមែនរដ្ឋគប្បីទទួលស្គាល់ថាការវិនិយោគសាធារណៈ និង ឯកជនប្រកបដោយការទទួលខុសត្រូវមានសារៈសំខាន់ជាសារវន្តដល់ការលើកកម្ពស់សន្តិសុខស្បៀង។ អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និង ព្រៃឈើ លើកទឹកចិត្តដល់សាម៉ីជនមានសិទ្ធិកាន់កាប់ ឱ្យធ្វើការវិនិយោគប្រកបដោយការទទួលខុសត្រូវលើធនធានទាំងនេះ ដោយបង្កើនផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាព និង រកបានចំណូលកាន់តែខ្ពស់។ រដ្ឋគប្បីជំរុញ និងគាំទ្រការវិនិយោគប្រកបដោយការទទួលខុសត្រូវលើដី ជលផល និង ព្រៃឈើទាំងឡាយ ដែលគាំទ្រដល់គោលដៅទូលំទូលាយរបស់សង្គម សេដ្ឋកិច្ច និង បរិស្ថាន ក្នុងប្រព័ន្ធកសិកម្មផ្សេងៗ។ រដ្ឋគប្បីធានាថា រាល់សកម្មភាពទាំងអស់មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។

១២.២ ដោយយល់ឃើញថាអ្នកផលិតខ្នាតតូច និង អង្គការរបស់ពួកគេនៅក្នុងប្រទេសកំពុងអភិវឌ្ឍផ្តល់ការវិនិយោគកសិកម្មមួយចំណែកធំ ដែលរួមចំណែកយ៉ាងសំខាន់ដល់សន្តិសុខស្បៀង អាហារូបត្ថម្ភ ការលុបបំបាត់ភាពក្រីក្រ និង ភាពធន់ទ្រាំទៅនឹងបរិស្ថាន រដ្ឋគប្បីគាំទ្រការវិនិយោគរបស់អ្នកផលិតខ្នាតតូច ក៏ដូចជាការវិនិយោគសាធារណៈ និងឯកជនដែលគិតគូរដល់អ្នកផលិតខ្នាតតូច ។

១២.៣ រាល់ទម្រង់ទាំងអស់នៃប្រតិបត្តិការនៅក្នុងសិទ្ធិកាន់កាប់ ដែលជាលទ្ធផលនៃការវិនិយោគលើដី ជលផល និង ព្រៃឈើ គប្បីត្រូវធ្វើប្រកបដោយតម្លាភាព ស្របតាមគោលនយោបាយជាតិតាមវិស័យពាក់ព័ន្ធ និង មានសង្គតភាពជាមួយគោលដៅនៃភាពរីកចម្រើននៅក្នុងសង្គម និងកំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍មនុស្សប្រកបដោយនិរន្តរភាព ដោយផ្តោតលើអ្នកផលិតខ្នាតតូច។

១២.៤ ការវិនិយោគប្រកបដោយការទទួលខុសត្រូវ មិនគប្បីធ្វើឱ្យគ្រោះថ្នាក់ ប៉ុន្តែគប្បីការពារប្រឆាំងនឹងការដកហូតទ្រព្យរបស់សាម៉ីជនមានសិទ្ធិកាន់កាប់ស្របច្បាប់ និង ការធ្វើឱ្យខូចខាតបរិស្ថាន និង

គប្បីគោរពសិទ្ធិមនុស្ស។ ការវិនិយោគទាំងនេះគប្បីត្រូវបានធ្វើឡើងក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាលគ្រប់កម្រិតពាក់ព័ន្ធ និង សាមីជនមាន សិទ្ធិកាន់កាប់ក្នុងមូលដ្ឋានចំពោះដីជលផល និង ព្រៃឈើ ដោយគោរពសិទ្ធិកាន់កាប់ស្របច្បាប់របស់ពួកគេ។ ការវិនិយោគទាំងនេះគប្បីខិតខំរួមចំណែកថែមទៀតដល់គោលដៅគោលនយោបាយនានា ដូចជា ការលុបបំបាត់ភាពក្រីក្រ សន្តិសុខស្បៀង និង ការប្រើប្រាស់ដី ជលផល និង ព្រៃឈើប្រកបដោយនិរន្តរភាព គាំទ្រសហគមន៍មូលដ្ឋាន រួមចំណែកដល់ការអភិវឌ្ឍន៍ជនបទ ជំរុញ និងទ្រទ្រង់ប្រព័ន្ធផលិតកម្មស្បៀងក្នុងមូលដ្ឋាន លើកកម្ពស់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព បង្កើតការងារ ធ្វើពិពិធកម្មជីវភាព ផ្តល់អត្ថប្រយោជន៍ដល់ប្រទេស និង ប្រជាជន រួមមានជនក្រីក្រ និងជនងាយរងគ្រោះបំផុត និង គោរពតាមច្បាប់ជាតិ និងអន្តរជាតិ បទដ្ឋានពលកម្មសំខាន់ៗ ក៏ដូចជាកាតព្វកិច្ចដែលទាក់ទៅនឹងបទដ្ឋានរបស់អង្គការពលកម្មអន្តរជាតិ ក្នុងករណីដែលអាចអនុវត្តបាន។

១២.៥ ដោយមានការពិគ្រោះយោបល់ និងការចូលរួមសមស្រប រដ្ឋគប្បីផ្តល់វិធាននៃច្បាប់ប្រកបដោយតម្លាភាពស្តីពីមាត្រដ្ឋាន វិសាលភាព និង ប្រភេទនៃប្រតិបត្តិការដែលអាចអនុញ្ញាតឲ្យដំណើរបាននៅក្នុងសិទ្ធិកាន់កាប់ និង គប្បីកំណត់ថាតើអ្វីជាប្រតិបត្តិការក្នុងទ្រង់ទ្រាយធំនៅក្នុងសិទ្ធិកាន់កាប់នៅក្នុងបរិបទជាតិរបស់ខ្លួន។

១២.៦ រដ្ឋគប្បីផ្តល់វិធានការការពារដើម្បីការពារសិទ្ធិកាន់កាប់ស្របច្បាប់ សិទ្ធិមនុស្ស ជីវភាព សន្តិសុខស្បៀង និង បរិស្ថាន ពីហានិភ័យនានាដែលអាចកើតចេញពីប្រតិបត្តិការក្នុងសិទ្ធិកាន់កាប់ក្នុងទ្រង់ទ្រាយធំ។ វិធានការការពារទាំងនេះ អាចរួមមានការណែនាំនូវកម្រិតនៃប្រតិបត្តិការដីធ្លីដែលអាចអនុញ្ញាតបាន និង ការធ្វើនិយ័តកម្មថាតើ ការផ្ទេរដែលលើសពីមាត្រដ្ឋានមួយជាក់លាក់ គប្បីមានការយល់ព្រមយ៉ាងណា ដូចជា ដោយមានការយល់ព្រមពីរដ្ឋសភាជាដើម។ រដ្ឋគប្បីពិចារណាជំរុញផលិតកម្ម និង ម៉ូដែលវិនិយោគផ្សេងៗដែលមិនបណ្តាលឱ្យមានការផ្ទេរសិទ្ធិកាន់កាប់ក្នុងទ្រង់ទ្រាយធំទៅឱ្យវិនិយោគិន និង គប្បីលើកទឹកចិត្តដល់ភាពជាដៃគូជាមួយសាមីជនមានសិទ្ធិកាន់កាប់ក្នុងមូលដ្ឋាន។

១២.៧ ក្នុងករណីជនជាតិដើមភាគតិច និង សហគមន៍របស់ពួកគេ រដ្ឋគប្បីធានាថា រាល់សកម្មភាពទាំងអស់មានសង្គតិភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និងដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន រួមមាន អនុសញ្ញាអង្គការពលកម្មអន្តរជាតិ (លេខ ១៦៩) ស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធក្នុងប្រទេសឯករាជ្យ និង សេចក្តីថ្លែងការណ៍អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ទៅតាមភាពសមស្រប ។ រដ្ឋ និង ភាគីដទៃទៀត គប្បីធ្វើការពិគ្រោះយោបល់ប្រកបដោយសុឆន្ទៈ ជាមួយជនជាតិដើមភាគតិច មុនពេលផ្តួចផ្តើមគម្រោងវិនិយោគណា ដែលប៉ះពាល់ដល់ធនធានទាំងឡាយដែលសហគមន៍មានសិទ្ធិកានកាប់។

គម្រោងបែបនេះ គប្បីផ្អែកលើការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព និង អត្ថន័យ ជាមួយសមាជិកជនជាតិដើមភាគតិច ដូចមានចែងនៅក្នុងកថាខណ្ឌ ៩.៩។ គោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ គប្បីអនុវត្តសម្រាប់ការវិនិយោគទាំងឡាយដែលប្រើប្រាស់ធនធានរបស់សហគមន៍ដទៃទៀត។

១២.៨ ស្របតាមគោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ រដ្ឋគប្បីកំណត់ ជាមួយភាគីរងផលប៉ះពាល់ទាំងអស់ នូវលក្ខខណ្ឌទាំងឡាយដែលជំរុញការវិនិយោគប្រកបដោយការទទួលខុសត្រូវ ហើយបន្ទាប់មក គប្បីអភិវឌ្ឍ និង ផ្សព្វផ្សាយគោលនយោបាយ និងច្បាប់ទាំងឡាយដែលលើកទឹកចិត្តដល់ការវិនិយោគប្រកបដោយការទទួលខុសត្រូវ គោរពសិទ្ធិមនុស្ស និងជំរុញសន្តិសុខស្បៀង ព្រមទាំងការប្រើប្រាស់បរិស្ថានប្រកបដោយនិរន្តរភាព។ ច្បាប់គប្បីតម្រូវឱ្យមានការព្រមព្រៀងសម្រាប់ការវិនិយោគ ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវសិទ្ធិ និង កាតព្វកិច្ចទាំងឡាយរបស់គ្រប់ភាគីទាំងអស់ចំពោះកិច្ចព្រមព្រៀង។ កិច្ចព្រមព្រៀងសម្រាប់ការវិនិយោគ គប្បីគោរពតាមក្របខ័ណ្ឌគតិយុត្តិ និង ក្រមវិនិយោគជាតិ។

១២.៩ រដ្ឋគប្បីត្រៀមលក្ខណៈសម្រាប់ការវិនិយោគ ដែលពាក់ព័ន្ធនឹងគ្រប់ទម្រង់នៃប្រតិបត្តិការសិទ្ធិកាន់កាប់ រួមមានលទ្ធកម្ម និង កិច្ចព្រមព្រៀងភាពជាដៃគូ ដែលត្រូវមានសង្គតភាពទៅនឹងគោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ ជាមួយអ្នកដែលសិទ្ធិកាន់កាប់របស់ខ្លួន រួមទាំងសិទ្ធិបន្ទាប់បន្សំ អាចត្រូវទទួលរងផលប៉ះពាល់។ រដ្ឋ និង ភាគីពាក់ព័ន្ធដទៃទៀតគប្បីប្រាប់បុគ្គល គ្រួសារ និង សហគមន៍ អំពីសិទ្ធិកាន់កាប់របស់ពួកគេ និង ជួយអភិវឌ្ឍសមត្ថភាពពួកគេក្នុងការពិគ្រោះយោបល់ និង ការចូលរួម រួមទាំងការផ្តល់ជំនួយវិជ្ជាជីវៈ ទៅតាម តម្រូវការ។

១២.១០ នៅពេលដែលការវិនិយោគពាក់ព័ន្ធនឹងប្រតិបត្តិការទ្រង់ទ្រាយធំនៃសិទ្ធិកាន់កាប់ ដែលរួមមានលទ្ធកម្ម និង កិច្ចព្រមព្រៀងភាពជាដៃគូ កំពុងត្រូវបានពិចារណា រដ្ឋគប្បីខិតខំចាត់ឱ្យភាគីផ្សេងៗធ្វើការវាយតម្លៃដោយឯករាជ្យជាមុន លើផលប៉ះពាល់វិជ្ជមាន និង អវិជ្ជមានជាសក្តានុពល ដែលការវិនិយោគទាំងនោះអាចមានផលប៉ះពាល់លើសិទ្ធិកាន់កាប់ សន្តិសុខស្បៀង និង ការសម្រេចបានជាលំដាប់នូវសិទ្ធិទទួលបានស្បៀងអាហារគ្រប់គ្រាន់ ជីវភាព និង បរិស្ថាន។ រដ្ឋគប្បីធានាថា សិទ្ធិកាន់កាប់ និងការទាមទារស្របច្បាប់ដែលមានស្រាប់ រួមមានសិទ្ធិនៃការកាន់កាប់បែបប្រពៃណី និង ក្រៅប្រព័ន្ធ ត្រូវបានកំណត់ក្នុងលក្ខណៈជាប្រព័ន្ធ ដោយមិនលំអៀងព្រមទាំងសិទ្ធិ និងជីវភាពរបស់ប្រជាពលរដ្ឋផ្សេងទៀតដែលរងផលប៉ះពាល់ពីការវិនិយោគផងដែរ ដូចជាអ្នកផលិតខ្នាតតូចជាដើម។ កិច្ចដំណើរការនេះ គប្បីធ្វើឡើងតាមរយៈការពិគ្រោះយោបល់ជាមួយភាគីរងផលប៉ះពាល់ទាំងអស់ ស្របតាមគោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ។ រដ្ឋគប្បីធានាថា សិទ្ធិកាន់កាប់ស្របច្បាប់ដែលមានស្រាប់ មិនត្រូវបានបន្ធូរបន្ថយដោយការវិនិយោគបែបនេះឡើយ។

១២.១១ ភាគីកិច្ចសន្យាគប្បីផ្តល់ព័ត៌មានពេញលេញ ដើម្បីធានាឱ្យបានថាជនពាក់ព័ន្ធទាំងអស់បានចូលរួម និងបានទទួលព័ត៌មាននៅក្នុងការចរចារ និង គប្បីខិតខំធានាឱ្យបានថាកិច្ចព្រមព្រៀងទាំងនេះត្រូវបានចងក្រងជាឯកសារ និង ហើយអ្នកដែលរងផលប៉ះពាល់ទាំងអស់បានយល់អំពីកិច្ចព្រមព្រៀងទាំងនេះ។ កិច្ចដំណើរការចរចារ គប្បីមានលក្ខណៈមិនរើសអើង និង គិតគូរដល់យេនឌ័រ។

១២.១២ វិនិយោគិនមានកាតព្វកិច្ចត្រូវគោរពច្បាប់ និងនីតិកម្មជាតិ ព្រមទាំងទទួលស្គាល់ និង គោរពសិទ្ធិកាន់កាប់របស់អ្នកដទៃ និង វិធាននៃច្បាប់ ស្របតាមគោលការណ៍ទូទៅសម្រាប់តួអង្គមិនមែនរដ្ឋ ដូចមានចែងក្នុងគោលការណ៍ណែនាំទាំងនេះ។ ការវិនិយោគគប្បីមិនរួមចំណែកដល់អសន្តិសុខស្បៀង និង ការវិចរិលបរិស្ថានឡើយ។

១២.១៣ អ្នកជំនាញដែលផ្តល់សេវាជូនរដ្ឋ វិនិយោគិន និង សមីជនមានសិទ្ធិកាន់កាប់ចំពោះដី ជលផល និង ព្រៃឈើ គប្បីមានការយកចិត្តទុកដាក់ខ្ពស់តាមលទ្ធភាពប្រសើរបំផុតរបស់ខ្លួន នៅពេលផ្តល់សេវា ដោយមិនគិតថាតើការយកចិត្តទុកដាក់នោះត្រូវបានស្នើសុំជាក់លាក់ ឬយ៉ាងណាឡើយ។

១២.១៤ រដ្ឋ និង ភាគីរងផលប៉ះពាល់ គប្បីរួមចំណែកដល់ការតាមដានប្រកបដោយប្រសិទ្ធភាពលើការអនុវត្តន៍ និង ឥទ្ធិពលនៃកិច្ចព្រមព្រៀងទាំងឡាយដែលពាក់ព័ន្ធនឹងប្រតិបត្តិការទ្រង់ទ្រាយធំនៅក្នុងសិទ្ធិកាន់កាប់ រួមមានលទ្ធកម្ម និង កិច្ចព្រមព្រៀងភាពជាដៃគូ។ ក្នុងករណីចាំបាច់ រដ្ឋគប្បីធ្វើសកម្មភាពកែតម្រូវ ដើម្បីអនុវត្តកិច្ចព្រមព្រៀង និង ការពារសិទ្ធិកាន់កាប់ និងសិទ្ធិផ្សេងទៀត និង ផ្តល់យន្តការ ដែលភាគីមិនសុខចិត្តអាចស្នើសុំសកម្មភាពបែបនេះ។

១២.១៥ នៅពេលណារដ្ឋវិនិយោគ ឬ ជំរុញការវិនិយោគនៅបរទេស រដ្ឋគប្បីធានាថាអំពើរបស់ខ្លួនមានសង្គតភាពទៅនឹងកិច្ចការពារសិទ្ធិកាន់កាប់ស្របច្បាប់ ការជំរុញសន្តិសុខស្បៀង និង កាតព្វកិច្ចជាធរមានរបស់ខ្លួន ក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និង អន្តរជាតិដែលអាចយកមកអនុវត្តបាន។

## ១៣. ការប្រមូលផ្តុំដី និង អភិក្រមកែតម្រូវឡើងវិញផ្សេងទៀត

១៣.១ ក្នុងករណីសមស្រប រដ្ឋអាចពិចារណាការប្រមូលផ្តុំដី ការដោះដូរ ឬ អភិក្រមស្ម័គ្រចិត្តផ្សេងទៀតសម្រាប់ការកែតម្រូវឡើងវិញនូវក្បាលដី ឬ កម្មសិទ្ធិ ដើម្បីជួយម្ចាស់កម្មសិទ្ធិ និងអ្នកប្រើប្រាស់ក្នុងការកែលម្អប្លង់ និងការប្រើប្រាស់ក្បាលដី ឬ កម្មសិទ្ធិរបស់ខ្លួន ដើម្បីជំរុញសន្តិសុខស្បៀង និង ការអភិវឌ្ឍន៍ជនបទ ក្នុងលក្ខណៈនិរន្តរភាព។ រដ្ឋគប្បីធានាថា រាល់សកម្មភាពទាំងអស់មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួន ក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និង អន្តរជាតិដែលអាចយកមកអនុវត្តបាន និង ធានាថាអ្នកចូលរួមយ៉ាងហោចណាស់មានភាពប្រសើរឡើង

ក្រោយពេលមានកម្មវិធី បើធៀបទៅនឹងមុនពេលមានកម្មវិធី។ អភិក្រមទាំងនេះគប្បីយកមកប្រើប្រាស់ ដើម្បីសម្របសម្រួលដល់ការចង់បានរបស់ម្ចាស់កម្មសិទ្ធិ និង អ្នកប្រើប្រាស់ច្រើននៅក្នុងការកែតម្រូវឡើងវិញដ៏ស្របច្បាប់មួយ ។

១៣.២ ក្នុងករណីសមស្រប រដ្ឋអាចពិចារណាការបង្កើតធនាគារដី ជាផ្នែកមួយនៃកម្មវិធីប្រមូលផ្តុំដី ដើម្បីធ្វើលទ្ធកម្ម និងរក្សាទុកជាបណ្តោះអាសន្ននូវក្បាលដី រហូតដល់ពេលដែលក្បាលដីទាំងនេះត្រូវបានបែងចែកជូនអ្នកទទួលផល។

១៣.៣ ក្នុងករណីសមស្រប រដ្ឋអាចពិចារណាលើកទឹកចិត្ត និងជួយសម្រួលការប្រមូលផ្តុំដី និង ធនាគារដីក្នុងគម្រោងការពារបរិស្ថាន និង ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជួយសម្រួលលទ្ធកម្មដីឯកជន សម្រាប់គម្រោងសាធារណៈទាំងនេះ និង ដើម្បីផ្តល់ជូនម្ចាស់កម្មសិទ្ធិ កសិករ និង អ្នកផលិតស្បៀងខ្នាតតូចដែលរងផលប៉ះពាល់ នូវដីជាថ្នូរ ដែលនឹងអនុញ្ញាតឱ្យពួកគេអាចបន្ត និង បង្កើនផលិតកម្មរបស់ពួកគេ។

១៣.៤ ក្នុងករណីដែលការពុះចែកកសិដ្ឋានគ្រួសារខ្នាតតូច និង ព្រៃឈើទៅជាជាក្បាលដីជាច្រើន បង្កើនថ្លៃចំណាយផលិតកម្ម រដ្ឋអាចពិចារណាប្រមូលផ្តុំដី និង ធនាគារដី ដើម្បីកែលម្អរចនាសម្ព័ន្ធនៃកសិដ្ឋាន និងព្រៃឈើទាំងនោះ។ រដ្ឋគប្បីចៀសវាងពីប្រើប្រាស់ការប្រមូលផ្តុំដី ក្នុងករណីដែលការពុះដីផ្តល់អត្ថប្រយោជន៍ ដូចជាការកាត់បន្ថយហានិភ័យ ឬ ពិពិធកម្មដំណាំ។ គម្រោងប្រមូលផ្តុំដីដើម្បីរៀបចំកសិដ្ឋានឡើងវិញ គប្បីដាក់បញ្ចូលជាមួយកម្មវិធីគាំទ្រកសិករ ដូចជាការស្តារប្រព័ន្ធធារាសាស្ត្រ និង ផ្លូវថ្នល់ក្នុងមូលដ្ឋានជាដើម។ វិធានការនានាគប្បីបង្កើតដើម្បីការពារការវិនិយោគលើការការប្រមូលផ្តុំដី តាមរយៈការដាក់កំហិតចំពោះការពុះចែកលើក្បាលដីដែលបានប្រមូលផ្តុំ។

១៣.៥ រដ្ឋគប្បីបង្កើតយុទ្ធសាស្ត្រសម្រាប់អភិក្រមកែតម្រូវឡើងវិញ ដែលត្រូវនឹងតម្រូវការដោយឡែកក្នុងមូលដ្ឋាន។ យុទ្ធសាស្ត្រទាំងនេះគប្បីមាននិរន្តរភាពខាងសង្គម សេដ្ឋកិច្ច និង បរិស្ថាន និង គិតគូរដល់យេនឌ័រ។ យុទ្ធសាស្ត្រគប្បីកំណត់គោលការណ៍ និង គោលដៅនៃអភិក្រមកែតម្រូវឡើងវិញ អ្នកទទួលផល និង ការអភិវឌ្ឍសមត្ថភាព និងចំណេះដឹងនៅក្នុងវិស័យសាធារណៈ វិស័យឯកជន អង្គការកសិករ និងអ្នកផលិតខ្នាតតូច អ្នកនេសាទ និង អ្នកប្រើប្រាស់ព្រៃឈើ និង គ្រឹះស្ថានសិក្សា។ ច្បាប់គប្បីបង្កើតនីតិវិធីច្បាស់លាស់ និង ប្រកបដោយប្រសិទ្ធភាពចំណាយសម្រាប់ការរៀបចំឡើងវិញនូវក្បាលដី ឬ កម្មសិទ្ធិ និង ការប្រើប្រាស់របស់ពួកគេ។

១៣.៦ រដ្ឋគប្បីបង្កើតវិធានការការពារសមស្របក្នុងគម្រោងទាំងឡាយ ដែលប្រើប្រាស់អភិក្រមកែតម្រូវឡើងវិញ។ បុគ្គល សហគមន៍ ឬ ប្រជាពលរដ្ឋណាដែលទំនងនឹងទទួលរងផលប៉ះពាល់ពីគម្រោងគប្បីត្រូវបានទាក់ទង និង ផ្តល់ព័ត៌មានគ្រប់គ្រាន់ ជាភាសាសមស្រប។ គប្បីផ្តល់ជូននូវការជួយគាំទ្រផ្នែកបច្ចេកទេស និងច្បាប់។ អភិក្រមបែបចូលរួម និងគិតគូរដល់យេនឌ័រ គប្បីត្រូវ

បានយកមកប្រើប្រាស់ ដោយគិតគូរដល់សិទ្ធិរបស់ជនជាតិដើមភាគតិច។ វិធានការការពារបរិស្ថាន គប្បីត្រូវបានបង្កើតដើម្បីទប់ស្កាត់ ឬ កាត់បន្ថយការធ្វើឱ្យខូចខាត និង ការបាត់បង់ជីវចម្រុះ និង ផ្តល់រង្វាន់ដល់ការផ្លាស់ប្តូរ ដែលជំរុញឲ្យមានការគ្រប់គ្រងដីល្អ ការអនុវត្តល្អ ប្រសើរ និង ការកែលម្អដីឡើងវិញ។

## ១៤. បដិទាន

១៤.១ ដោយពិចារណាទៅលើបរិបទជាតិរបស់ខ្លួន ក្នុងករណីសមស្រប រដ្ឋគប្បីពិចារណាផ្តល់បដិទានចំពោះការបាត់បង់សិទ្ធិកាន់កាប់ស្របច្បាប់ចំពោះដី ជលផល និង ព្រៃឈើ។ រដ្ឋគប្បីធានាថារាល់សកម្មភាពទាំងអស់ មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និង អន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និង អន្តរជាតិដែលអាចយកមកអនុវត្តបាន។

១៤.២ ក្នុងករណីដែលអាចធ្វើទៅបាន ក្បាលដី ឬ កម្មសិទ្ធិដើម គប្បីប្រគល់ឱ្យអ្នកដែលរងការបាត់បង់ ឬ ទាយាទពួកគេវិញ ដោយសេចក្តីសម្រេចរបស់អាជ្ញាធរជាតិមានសមត្ថកិច្ច។ ក្នុងករណីដែលក្បាលដី ឬ កម្មសិទ្ធិដើមមិនអាចប្រគល់ឱ្យវិញបាន រដ្ឋគប្បីផ្តល់សំណងជាបន្ទាន់ និងប្រកបដោយយុត្តិធម៌ ក្នុងទម្រង់ជាប្រាក់ និង/ឬ ក្បាលដី ឬ កម្មសិទ្ធិផ្សេង ដោយធានាឱ្យបាននូវប្រព្រឹត្តិកម្មប្រកបដោយសមធម៌ចំពោះប្រជាពលរដ្ឋរងផលប៉ះពាល់ទាំងអស់។

១៤.៣ ក្នុងករណីសមស្រប ការបារម្ភរបស់ជនជាតិដើមភាគតិចទាក់ទងនឹងបដិទាន គប្បីដោះស្រាយក្នុងបរិបទជាតិ និង ស្របតាមច្បាប់ និង នីតិកម្មជាតិ។

១៤.៤ រដ្ឋគប្បីអភិវឌ្ឍគោលនយោបាយ និងច្បាប់គិតគូរដល់យេនឌ័រ ដែលចែងពីនីតិវិធីច្បាស់លាស់ប្រកបដោយតម្លាភាពសម្រាប់បដិទាន។ ព័ត៌មានស្តីពីនីតិវិធីបដិទាន គប្បីផ្សព្វផ្សាយឱ្យបានទូលាយ ជាភាសាសមស្រប។ អ្នកទាមទារគប្បីត្រូវបានផ្តល់ជូននូវជំនួយគ្រប់គ្រាន់ រួមមានតាមរយៈជំនួយផ្នែកច្បាប់ និង ជំនួយការមេធាវី នៅក្នុងកិច្ចដំណើរការទាំងមូល។ រដ្ឋគប្បីធានាថាការទាមទារបដិទានត្រូវបានពិនិត្យជាបន្ទាន់។ ក្នុងករណីចាំបាច់ អ្នកដែលធ្វើការទាមទារបានជោគជ័យ គប្បីទទួលបានសេវាគាំទ្រ ដើម្បីឱ្យពួកគេអាចអនុវត្តសិទ្ធិកាន់កាប់របស់ខ្លួន និង បំពេញកាតព្វកិច្ចរបស់ខ្លួនបាន។ វឌ្ឍនភាពនៃការអនុវត្តន៍ គប្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

៤

## ១៥. កំណែទម្រង់ទៅលើការបែងចែកដីឡើងវិញ

១៥.១ កំណែទម្រង់ទៅលើការបែងចែកដីឡើងវិញ អាចសម្រួលដល់លទ្ធភាពប្រើប្រាស់ដីយ៉ាងទូលំទូលាយ និង ប្រកបដោយសមធម៌ និង អភិវឌ្ឍន៍ជនបទគ្រប់ជ្រុងជ្រោយ។ ក្នុងន័យនេះ ក្នុងករណីសមស្របស្របតាមបរិបទជាតិ រដ្ឋអាចពិចារណាលើការបែងចែកដីសាធារណៈ យន្តការស្ម័គ្រចិត្ត និងផ្អែកលើទីផ្សារ ក៏ដូចជាអស្សាមិករណ៍ដីឯកជន ជលផល ឬ ព្រៃឈើ សម្រាប់គោលបំណងសាធារណៈ ។

១៥.២ រដ្ឋអាចពិចារណាយកកម្រិតអនុញ្ញាតខ្ពស់បំផុតនៃដី ជាជម្រើសគោលនយោបាយមួយ ក្នុងបរិបទនៃការអនុវត្តនកំណែទម្រង់ទៅលើការបែងចែកដីឡើងវិញ។

១៥.៣ ក្នុងបរិបទជាតិ និង ស្របតាមច្បាប់ និងនីតិកម្មជាតិ កំណែទម្រង់លើការបែងចែកដីឡើងវិញអាចត្រូវបានពិចារណា សម្រាប់បុព្វហេតុសង្គម សេដ្ឋកិច្ច និង បរិស្ថាន ព្រមទាំងមូលហេតុផ្សេងទៀត ក្នុងករណីដែលការប្រមូលផ្តុំភាពជាម្ចាស់ក្នុងកម្រិតមួយខ្ពស់ មានលាយឡំទៅនឹងភាពក្រីក្រជនបទ ក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ ដែលទំនងនឹងបង្កឡើងដោយកង្វះលទ្ធភាពប្រើប្រាស់ដី ជលផល និង ព្រៃឈើ ស្របតាមបទប្បញ្ញត្តិនៃផ្នែក ១៥ ដែលនិយាយអំពីសិទ្ធិរបស់សាមីជនកាន់កាប់ស្របច្បាប់គ្រប់រូប។ កំណែទម្រង់លើការបែងចែកដីឡើងវិញ គប្បីធានាលទ្ធភាពស្មើភាពគ្នារបស់បុរស និងស្ត្រី ក្នុងការប្រើប្រាស់ដី ជលផល និង ព្រៃឈើ។

១៥.៤ ក្នុងករណីដែលរដ្ឋសម្រេចអនុវត្តកំណែទម្រង់លើការបែងចែកដីឡើងវិញ រដ្ឋគប្បីធានាថា កំណែទម្រង់មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និង អន្តរជាតិ ដែលអាចយកមកអនុវត្តបាន។ កំណែទម្រង់គប្បីគោរពតាមវិធាននៃច្បាប់ និង ត្រូវអនុវត្តស្របតាមច្បាប់ និង នីតិវិធីជាតិ។ រដ្ឋគប្បីសម្រួលដល់ការរៀបចំការពិគ្រោះយោបល់ ស្របតាមស្មារតីនៃគោលការណ៍ណែនាំទាំងនេះ ស្តីពីការបែងចែកដីឡើងវិញ រួមទាំងការធ្វើឱ្យមានតុល្យភាពចំពោះសេចក្តីត្រូវការរបស់គ្រប់ភាគីទាំងអស់ និង អភិក្រមទាំងឡាយដែលនឹងត្រូវប្រើប្រាស់។ គប្បីអភិវឌ្ឍឱ្យមានភាពជាដៃគូរវាងរដ្ឋ សហគមន៍ សង្គមស៊ីវិល វិស័យឯកជន អង្គការកសិករ និងអ្នកផលិតស្បៀងខ្នាតតូច អ្នកនេសាទ និង អ្នកប្រើប្រាស់ព្រៃឈើ និង ភាគីដទៃទៀត។ វិភាគទានហិរញ្ញវត្ថុ និង ការរួមចំណែកផ្សេងទៀតដែលគេរំពឹងឱ្យអ្នកទទួលផល គប្បីមានលក្ខណៈសមរម្យ និង មិន មានបន្ទុកបំណុលដែលមិនអាចគ្រប់គ្រងបានដល់ពួកគេឡើយ។ អ្នកដែលបោះបង់សិទ្ធិកាន់កាប់របស់ខ្លួនចំពោះដី ជលផល និង ព្រៃឈើ គប្បី ទទួលបានការទូទាត់ក្នុងតម្លៃស្មើគ្នា ដោយមិនមានការយឺតយ៉ាវណាមួយដែលមិនសមហេតុផល។

១៥.៥ ក្នុងករណីដែលរដ្ឋសម្រេចអនុវត្តកំណែទម្រង់លើការបែងចែកដីឡើងវិញ រដ្ឋគប្បីបញ្ជាក់ឱ្យបានច្បាស់នូវគោលបំណងនៃកម្មវិធីកំណែទម្រង់ និង ចង្អុលបង្ហាញដីដែលត្រូវបានលើកលែងពីការបែងចែកឡើងវិញនេះ។ មុខសញ្ញាអ្នកទទួលផល ដូចជាគ្រួសារ រួមទាំងអ្នកថៃសួនដំណាំនៅផ្ទះ ស្ត្រី អ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ អ្នកចិញ្ចឹមសត្វ ក្រុមជនជួបផលវិបាកជាប្រវត្តិសាស្ត្រ ក្រុមជនត្រូវគេមើលរំលង ជនជាតិដើមភាគតិច អ្នកដើរប្រមូលផល និង អ្នកផលិតស្បៀងខ្នាតតូច គប្បីត្រូវកំណត់ឱ្យបានច្បាស់លាស់។

១៥.៦ ក្នុងករណីដែលរដ្ឋសម្រេចអនុវត្តកំណែទម្រង់លើការបែងចែកដីឡើងវិញ រដ្ឋគប្បីអភិវឌ្ឍគោលនយោបាយ និងច្បាប់ តាមរយៈកិច្ចដំណើរការមានការចូលរួម ដើម្បីធ្វើឱ្យកំណែទម្រង់ទាំងនេះមាននិរន្តរភាព។ រដ្ឋគប្បីធានាថាគោលនយោបាយ និងច្បាប់ទាំងនោះ ជួយដល់អ្នកទទួលផល មិនចំពោះថាសហគមន៍ គ្រួសារ ឬ បុគ្គលនោះទេ ដើម្បីឱ្យពួកគេទទួលបានកម្រិតជីវភាពសមរម្យពីដី ជលផល និង ព្រៃឈើទាំងឡាយ ដែលពួកគេមាន និង ធានាឱ្យបាននូវប្រព្រឹត្តកម្មស្មើភាពគ្នាចំពោះបុរស និងស្ត្រី នៅក្នុងកំណែទម្រង់លើការបែងចែកដីឡើងវិញ។ រដ្ឋគប្បីកែសម្រួលឡើងវិញនូវគោលនយោបាយទាំងឡាយដែលអាចរារាំងដល់ការសម្រេចបាន និង និរន្តរភាពនៃឥទ្ធិពលដែលគេចង់បានពីកំណែទម្រង់លើការបែងចែកដីឡើងវិញ។

១៥.៧ នៅពេលដែលកំណែទម្រង់លើការបែងចែកដីឡើងវិញកំពុងត្រូវបានពិចារណា រដ្ឋអាចធ្វើការវាយតម្លៃលើសក្តានុពលនៃផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ដែលកំណែទម្រង់ទាំងនោះអាចមានលើសិទ្ធិកាន់កាប់ សន្តិសុខស្បៀង និង ការសម្រេចបានជាលំដាប់នូវសិទ្ធិមានស្បៀងអាហារគ្រប់គ្រាន់ ជីវភាព និង បរិស្ថាន ប្រសិនបើរដ្ឋពិតជាចង់បានយ៉ាងដូច្នេះមែន។ កិច្ចដំណើរការវាយតម្លៃនេះ គប្បីត្រូវបានធ្វើស្របតាមគោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ។ ការវាយតម្លៃ អាចត្រូវបានប្រើប្រាស់ជាមូលដ្ឋាន ដើម្បីកំណត់វិធានការទាំងឡាយដែលចាំបាច់ដើម្បីគាំទ្រអ្នកទទួលផល និង កែលម្អកម្មវិធីបែងចែកដីឡើងវិញ។

១៥.៨ រដ្ឋគប្បីធានាថាកម្មវិធីកំណែទម្រង់លើការបែងចែកដីឡើងវិញ ផ្តល់វិធានការគាំទ្រពេញលេញ ដែលអ្នកទទួលផលត្រូវការ ដូចជាលទ្ធភាពទទួលបានឥណទាន ការធានារ៉ាប់រងផលដំណាំ ធាតុចូល ទីផ្សារ ជំនួយបច្ចេកទេសលើការផ្សព្វផ្សាយជនបទ ការអភិវឌ្ឍន៍កសិដ្ឋាន និង លំនៅឋាន។ ការផ្តល់សេវាគាំទ្រ គប្បីសម្របសម្រួលជាមួយវឌ្ឍនភាពលើដីដោយអ្នកទទួលផល។ ថ្លៃចំណាយទាំងស្រុងនៃកំណែទម្រង់ដីធ្លី រួមទាំងថ្លៃចំណាយនៃសេវាគាំទ្រ គប្បីត្រូវបានកំណត់ជាមុន និង ដាក់បញ្ចូលក្នុងថវិកាពាក់ព័ន្ធ។

១៥.៩ រដ្ឋគប្បីអនុវត្តកំណែទម្រង់លើការបែងចែកដីឡើងវិញ តាមរយៈអភិក្រម និងនីតិវិធីមានតម្លាភាព មានការចូលរួម និង មានគណនេយ្យភាព។ ភាគីរងផលប៉ះពាល់ទាំងអស់ គប្បីទទួលបាននីតិវិធី

ត្រឹមត្រូវ និង សំណងប្រកបដោយយុត្តិធម៌ ស្របតាមច្បាប់ជាតិ និង បទប្បញ្ញត្តិទាំងឡាយនៃផ្នែក ១៦។ ភាគីរងផលប៉ះពាល់ទាំងអស់ រួមទាំងក្រុមជនជួបការលំបាក គប្បីទទួលបានព័ត៌មានពេញលេញ និងច្បាស់លាស់អំពីកំណែទម្រង់ រួមទាំងតាមរយៈសារដែលផ្តោតគោលដៅលើយេនឌ័រ។ អ្នកទទួលផលគប្បីត្រូវបានជ្រើសរើសតាមរយៈកិច្ចដំណើរការបើកទូលាយ ហើយពួកគេគប្បីទទួលសិទ្ធិកាន់កាប់មានសុវត្ថិភាពដែលត្រូវបានចុះបញ្ជីជាសាធារណៈ។ លទ្ធភាពទទួលបានមធ្យោបាយនៃការដោះស្រាយជម្លោះ គប្បីត្រូវបានផ្តល់ឲ្យ ស្របតាមច្បាប់ជាតិ។ រដ្ឋគប្បីខិតខំទប់ស្កាត់អំពើពុករលួយនៅក្នុងកម្មវិធីកំណែទម្រង់លើការបែងចែកដីឡើងវិញ ជាពិសេសតាមរយៈ តម្លាភាព និង ការចូលរួមកាន់តែច្រើនជាងមុន។

១៥.១០ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ រដ្ឋគប្បីតាមដាន និង វាយតម្លៃលទ្ធផលនៃកម្មវិធីកំណែទម្រង់លើការបែងចែកដីឡើងវិញ រួមទាំងគោលនយោបាយគាំទ្រពាក់ព័ន្ធ ដូចមានលើកឡើងក្នុងកថាខណ្ឌ ១៥.៨ និង ផលប៉ះពាល់របស់វាលើលទ្ធភាពមានដី និង សន្តិសុខស្បៀងរបស់បុរស និងស្ត្រី និង ក្នុងករណីចាំបាច់ រដ្ឋគប្បីដាក់ឱ្យអនុវត្តវិធានការកែតម្រូវ។

## ១៦. អស្សាមិករណ៍ និងសំណង

១៦.១ ដោយអនុលោមតាមច្បាប់ និងនីតិកម្មជាតិរបស់ខ្លួន និង ស្របតាមបរិបទជាតិ រដ្ឋគប្បីធ្វើអស្សាមិករណ៍តែក្នុងករណីដែលសិទ្ធិចំពោះ ដី ជលផល ឬ ព្រៃឈើ មានភាពចាំបាច់សម្រាប់តែគោលបំណងសាធារណៈប៉ុណ្ណោះ។ រដ្ឋគប្បីកំណត់ឱ្យបានច្បាស់នូវទស្សនាទាននៃគោលបំណងសាធារណៈនៅក្នុងច្បាប់ ដើម្បីអនុញ្ញាតឱ្យមានការពិនិត្យមើលឡើងវិញតាមផ្លូវតុលាការបាន។ រដ្ឋគប្បីធានាឱ្យបានថារាល់សកម្មភាពទាំងអស់មានសង្គតភាពទៅនឹងច្បាប់ជាតិរបស់ខ្លួន ក៏ដូចជាកាតព្វកិច្ចជាធរមានរបស់ខ្លួន ក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។ រដ្ឋគប្បីគោរពសាមីជនមានសិទ្ធិកាន់កាប់ស្របច្បាប់ទាំងអស់ ជាពិសេស ក្រុមជនងាយរងគ្រោះ និង ក្រុមជនដែលគេមើលរំលង ដោយធ្វើលទ្ធកម្មធនធានអប្បបរមាដែលចាំបាច់ និង ដោយផ្តល់ជាប្រញាប់នូវសំណងប្រកបដោយយុត្តិធម៌ស្របតាមច្បាប់ជាតិ។

១៦.២ រដ្ឋគប្បីធានាថាការធ្វើផែនការ និង កិច្ចដំណើរការសម្រាប់អស្សាមិករណ៍ មានតម្លាភាព និងមានការចូលរួម។ អ្នកណា ដែលទំនងនឹងទទួលរងផលប៉ះពាល់ គប្បីត្រូវបានកំណត់អត្តសញ្ញាណ និងផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ឱ្យបានសមស្រប ក្នុងគ្រប់ដំណាក់កាលទាំងអស់។ ការពិគ្រោះយោបល់ ស្របតាមស្មារតីនៃគោលការណ៍ណែនាំទាំងនេះ គប្បីផ្តល់ព័ត៌មានអំពីអភិក្រមផ្សេងដែលអាចមាន ដើម្បីសម្រេចឱ្យបាននូវគោលបំណងសាធារណៈ និង គប្បីគិតគូរដល់យុទ្ធសាស្ត្រ

កាត់បន្ថយការរំខានលើជីវភាព។ រដ្ឋគប្បីមានការប្រុងប្រយ័ត្នខ្ពស់ ក្នុងករណីដែលគ្រោងការណ៍អស្សាមិករណ៍មានពាក់ព័ន្ធតំបន់ ដែលមានសារៈសំខាន់ជាពិសេស លើផ្នែកវប្បធម៌ សាសនា ឬ បរិស្ថាន ឬ ក្នុងករណីដែលដី ជលផល និង ព្រៃឈើដែលជាកម្មវត្ថុទាំងនោះ មានសារៈសំខាន់ជាពិសេសចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ឬ ងាយរងគ្រោះ។

១៦.៣ រដ្ឋគប្បីធានាឱ្យបាននូវការកំណត់តម្លៃប្រកបដោយយុត្តិធម៌ និង សំណងជាប្រញាប់ ស្របតាមច្បាប់ជាតិ។ ក្នុងចំណោមទម្រង់ផ្សេងទៀត សំណង ជាអាទិ៍ អាចមានទម្រង់ជាប្រាក់ សិទ្ធិទទួលបានកន្លែងជំនួស ឬ ទាំងពីរ។

១៦.៤ យោងតាមលទ្ធភាពធនធាន រដ្ឋគប្បីធានាឱ្យបានថាទីភ្នាក់ងារអនុវត្ត មានសមត្ថភាពផ្នែកធនធានមនុស្ស សមត្ថភាពរូបវន្ត និង សមត្ថភាពហិរញ្ញវត្ថុ ព្រមទាំងសមត្ថភាពក្នុងទម្រង់ផ្សេងទៀត។

១៦.៥ ក្នុងករណីដែលគេលែងត្រូវការដី ជលផល និង ព្រៃឈើ ដោយសារការផ្លាស់ប្តូរផែនការ រដ្ឋគប្បីផ្តល់ឱកាសដំបូងជូនដល់សាមីជនម្ចាស់សិទ្ធិដើម ក្នុងការទទួលបានធនធានទាំងនេះមកវិញ។ ក្នុងករណីនេះ ការទទួលបានធនធានទាំងនេះមកវិញ គប្បីគិតគូរដល់បរិមាណសំណងដែលបានទទួល ជាថ្នូរនឹងអស្សាមិករណ៍។

១៦.៦ គ្រប់ភាគីទាំងអស់គប្បីខិតខំទប់ស្កាត់អំពើពុករលួយ ជាពិសេស តាមរយៈការប្រើប្រាស់តម្លៃដែលត្រូវបានប៉ាន់ប្រមាណដោយមិនលំអៀង កិច្ចដំណើរការ និង សេវាប្រកបដោយតម្លាភាព និង វិមជ្ឈការ ព្រមទាំងសិទ្ធិប្តឹងឧទ្ធរណ៍។

១៦.៧ ក្នុងករណីដែលការបណ្តេញចេញត្រូវបានចាត់ទុកថាមានលក្ខណៈត្រឹមត្រូវ សម្រាប់គោលបំណងសាធារណៈ ដែលបណ្តាលមកពីអស្សាមិករណ៍ដី ជលផល និង ព្រៃឈើ រដ្ឋគប្បីធ្វើការបណ្តេញចេញបែបនេះ និង រកផ្លូវដោះស្រាយលភាគីរងផលប៉ះពាល់ទាំងអស់ ក្នុងលក្ខណៈមួយដែលមានសង្គតភាព ទៅនឹងកាតព្វកិច្ចរបស់ខ្លួនក្នុងការគោរព ការពារ និង បំពេញសិទ្ធិមនុស្ស។

១៦.៨ មុនពេលធ្វើការបណ្តេញចេញ ឬ ការផ្លាស់ប្តូរក្នុងការប្រើប្រាស់ដី ដែលអាចបណ្តាលឱ្យមានការបំបែកបុគ្គល និងសហគមន៍ចេញពីលទ្ធភាពប្រើប្រាស់ផលិតផលធនធានរបស់ពួកគេ រដ្ឋគប្បីរិះរក ជម្រើសផ្សេងៗដែលអាចអនុវត្តបាន នៅក្នុងការពិគ្រោះយោបល់ជាមួយភាគីរងផលប៉ះពាល់ ស្របតាមស្មារតីនៃគោលការណ៍ណែនាំទាំងនេះ សំដៅជៀសវាង ឬ យ៉ាងហោចណាស់ កាត់បន្ថយជាអតិបរមា នូវភាពចាំបាច់ក្នុងការបណ្តេញចេញ។

១៦.៩ ការបណ្តេញចេញ និង ការតាំងលំនៅថ្មី មិនគប្បីធ្វើឱ្យបុគ្គលក្លាយខ្លួនជាអ្នកគ្មានលំនៅឋាន ឬ ជាជនងាយរងគ្រោះចំពោះការរំលោភសិទ្ធិមនុស្សឡើយ។ ក្នុងករណីដែលជនរងផលប៉ះពាល់មិន

អាចទ្រទ្រង់ខ្លួនឯងបាន រដ្ឋគប្បីចាត់វិធានការសមស្របដើម្បីផ្ដល់ជម្រើសលំនៅឋានគ្រប់គ្រាន់ ការតាំងលំនៅថ្មី ឬ លទ្ធភាពប្រើប្រាស់ដី ជលផល និង ព្រៃឈើឱ្យផល តាមករណីជាក់ស្ដែង ទៅតាមលទ្ធភាពធនធាន។

# ជំពូកទី ៥

៥

## រដ្ឋបាលនៃការកាន់កាប់

ជំពូកនេះថែងពីអភិបាលកិច្ចលើរដ្ឋបាលនៃការកាន់កាប់ដី ជលផល និង ព្រៃឈើ ពាក់ព័ន្ធនឹងការចុះបញ្ជីសិទ្ធិកាន់កាប់ ការកំណត់តម្លៃ ការយកពន្ធ ការធ្វើផែនការរៀបចំដែនដីដោយមាននិយ័តកម្ម ដំណោះស្រាយវិវាទលើការកាន់កាប់ និង បញ្ហាឆ្លងដែន។

### ១៧. ការចុះបញ្ជីសិទ្ធិកាន់កាប់

១៧.១ រដ្ឋគប្បីផ្តល់ប្រព័ន្ធនានា (ដូចជាការចុះបញ្ជី សុរិយោដី និង ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ជាដើម) ដើម្បីចុះបញ្ជីសិទ្ធិកាន់កាប់បុគ្គល និង សិទ្ធិកាន់កាប់ជាសមូហភាពដើម្បីកែលម្អសុវត្ថិភាពនៃសិទ្ធិកាន់កាប់ រួមមានសិទ្ធិកាន់កាប់ទាំងឡាយដែលគ្រប់គ្រងដោយរដ្ឋ និង វិស័យសាធារណៈ វិស័យឯកជន និង ជនជាតិដើមភាគតិច ព្រមទាំងសហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី និង ដើម្បីកិច្ចដំណើរការមុខងារនៃសង្គមមូលដ្ឋាន និងទីផ្សារ។ ប្រព័ន្ធទាំងនេះគប្បីកត់ត្រា រក្សាទុក និង ផ្សព្វផ្សាយសិទ្ធិកាន់កាប់ និង កាតព្វកិច្ចនានា រាប់បញ្ចូលអ្នកដែលមានសិទ្ធិ និង កាតព្វកិច្ចទាំងនោះ ព្រមទាំងក្បាលដី ឬ កម្មសិទ្ធិដី ជលផល ឬ ព្រៃឈើ ដែលសិទ្ធិ និង កាតព្វកិច្ចទាំងនោះមានការពាក់ព័ន្ធ។

១៧.២ រដ្ឋគប្បីផ្តល់ប្រព័ន្ធចុះបញ្ជីដែលមានលក្ខណៈសមស្រប សម្រាប់កាលៈទេសៈដោយឡែករបស់ខ្លួន រួមមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលមាន។ គប្បីអភិវឌ្ឍ និងប្រើប្រាស់វិធីសមស្រប ផ្នែកសង្គម-វប្បធម៌នៃការចុះបញ្ជីសិទ្ធិរបស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ។ ដើម្បីលើកកម្ពស់តម្លាភាព និងភាពស្របគ្នាជាមួយប្រភពព័ត៌មានផ្សេងទៀតសម្រាប់ការធ្វើផែនការរៀបចំដែនដី និង គោលបំណងផ្សេងទៀត រដ្ឋនីមួយៗ គប្បីខិតខំអភិវឌ្ឍក្របខ័ណ្ឌរួមមួយ ដែលរួមមានមានប្រព័ន្ធចុះបញ្ជីដែលមានស្រាប់ និង ប្រព័ន្ធព័ត៌មានស្តីពីការរៀបចំដែនដីដទៃទៀត។ នៅក្នុងយុត្តាធិការនីមួយៗ បញ្ជីនៃសិទ្ធិកាន់កាប់របស់រដ្ឋ និង វិស័យសាធារណៈ វិស័យឯកជន និង ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី គប្បីត្រូវបានរក្សាទុកក្នុងប្រព័ន្ធចុះបញ្ជីរួម។ នៅពេលណាដែល សិទ្ធិកាន់កាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ឬ ការកាន់កាប់នៅក្នុងកន្លែងតាំងទីលំនៅក្រៅប្រព័ន្ធ មិនអាចចុះបញ្ជី រដ្ឋគប្បីផ្តល់ការយកចិត្តទុកដាក់ជាពិសេស ដើម្បីទប់ស្កាត់ការចុះបញ្ជីសិទ្ធិប្រជែងគ្នានៅក្នុងតំបន់ទាំងនោះ។

១៧.៣ រដ្ឋគប្បីខិតខំធានាថាប្រជាពលរដ្ឋគ្រប់រូបអាចចុះបញ្ជីសិទ្ធិកាន់កាប់របស់ខ្លួន និង ទទួលបានព័ត៌មានដោយគ្មានការរើសអើង ទោះជាផ្អែកលើមូលដ្ឋានអ្វីក៏ដោយ។ ក្នុងករណីសមស្រប ទីភ្នាក់ងារអនុវត្ត ដូចជាស្ថាប័នចុះបញ្ជីដីជាដើម គប្បីបង្កើតមណ្ឌលផ្តល់សេវា ឬ ការិយាល័យចល័ត ដោយគិតគូរដល់ការធ្វើដំណើររបស់ស្ត្រី ក្រុមជនក្រីក្រ និង ក្រុមជនងាយរងគ្រោះ។ រដ្ឋគប្បីពិចារណាប្រើប្រាស់អ្នកវិជ្ជាជីវៈក្នុងមូលដ្ឋាន ដូចជាមេធាវី សារការី អ្នកវាស់ដីអាជីព និង សង្គមវិទូ ដើម្បីផ្តល់ព័ត៌មានអំពីសិទ្ធិកាន់កាប់ ជូនសាធារណជន។

១៧.៤ ទីភ្នាក់ងារអនុវត្តគប្បីអនុម័តនីតិវិធីសាមញ្ញ និងបច្ចេកវិទ្យាសមស្របក្នុងមូលដ្ឋាន ដើម្បីកាត់បន្ថយថ្លៃចំណាយ និង ពេលវេលាដែលចាំបាច់សម្រាប់ផ្តល់សេវា។ ភាពត្រឹមត្រូវនៃទំហំសម្រាប់ក្បាលដី និង ឯកតាដីផ្សេងទៀត គប្បីមានភាពគ្រប់គ្រាន់សម្រាប់ការកំណត់អត្តសញ្ញាណរបស់វា ដើម្បីបំពេញសេចក្តីត្រូវការក្នុងមូលដ្ឋាន ជាមួយនឹងកំណើននៃភាពត្រឹមត្រូវនៃទំហំដែលត្រូវបានផ្តល់ជូនជាបន្តបន្ទាប់ក្នុងករណីដែលត្រូវការឱ្យផ្តល់ជូន។ ដើម្បីជួយសម្រួលការប្រើប្រាស់បញ្ជីនៃសិទ្ធិកាន់កាប់ ទីភ្នាក់ងារអនុវត្ត គប្បីផ្សារភ្ជាប់ព័ត៌មានស្តីពីសិទ្ធិ សាមីជនដែលមានសិទ្ធិទាំងនោះ និង ឯកតាដីទាក់ទងនឹងសិទ្ធិទាំងនោះ។ បញ្ជីគប្បីរៀបចំជាលិបិក្រមតាមឯកតាដី ក៏ដូចជាតាមអ្នកកាន់កាប់ ដើម្បីអនុញ្ញាតឱ្យគេអាចកំណត់បានសិទ្ធិប្រជែងគ្នា ឬ សិទ្ធិត្រួតស៊ីគ្នា។ ជាផ្នែកមួយនៃការចែករំលែកព័ត៌មានសាធារណៈទូលំទូលាយ បញ្ជីនៃសិទ្ធិកាន់កាប់គប្បីផ្តល់ជូនស្ថាប័នរដ្ឋ និង រដ្ឋាភិបាលមូលដ្ឋាន ដើម្បីកែលម្អសេវាពួកគេ។ ព័ត៌មានគប្បីត្រូវបានចែករំលែកស្របតាមបទដ្ឋានជាតិ និង រាប់បញ្ចូលការបំបែកទិន្នន័យលម្អិតអំពីសិទ្ធិកាន់កាប់។

៥

១៧.៥ រដ្ឋគប្បីធានាថា ព័ត៌មានអំពីសិទ្ធិកាន់កាប់អាចរកបានដោយងាយ សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដោយគោរពតាមបំរាមឯកជនភាព។ បំរាមទាំងនេះមិនគប្បីរាំងដោយមិនចាំបាច់ ចំពោះការត្រួតពិនិត្យសាធារណៈ ដើម្បីកំណត់រកប្រតិបត្តិការពុករលួយ និងខុសច្បាប់ឡើយ។ រដ្ឋ និងតួអង្គមិនមែនរដ្ឋ គប្បីខិតខំថែមទៀតដើម្បីទប់ស្កាត់អំពើពុករលួយ ក្នុងការចុះបញ្ជីសិទ្ធិកាន់កាប់ ដោយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីដំណើរការ លក្ខខណ្ឌ ថ្លៃសេវា និង ករណីលើកលែងដែលមាន ព្រមទាំងការិយបរិច្ឆេទសម្រាប់ការឆ្លើយតបចំពោះសំណើសុំសេវា។

## ១៨. ការកំណត់តម្លៃ

១៨.១ រដ្ឋគប្បីធានាថាប្រព័ន្ធសមស្របត្រូវបានប្រើប្រាស់ សម្រាប់ការកំណត់តម្លៃសិទ្ធិកាន់កាប់ប្រកបដោយយុត្តិធម៌ និងទាន់ពេលវេលា សម្រាប់គោលបំណងជាក់លាក់នានា ដូចជាកិច្ចប្រតិបត្តិការទីផ្សារ វត្ថុធានាសម្រាប់ប្រាក់កម្ចី ប្រតិបត្តិការនៅក្នុងសិទ្ធិកាន់កាប់ដែលជាលទ្ធផលនៃការវិនិយោគ អស្សាមិករណ៍ និងការយកពន្ធ។ ប្រព័ន្ធទាំងនេះគប្បីជំរុញគោលដៅអភិវឌ្ឍន៍ទូលំទូលាយប្រកបដោយនិរន្តរភាពផ្នែកសង្គម សេដ្ឋកិច្ច និង បរិស្ថាន។

១៨.២ គោលនយោបាយ និងច្បាប់ទាំងឡាយទាក់ទងនឹងការកំណត់តម្លៃ គប្បីខិតខំធានាឱ្យបានថាប្រព័ន្ធកំណត់តម្លៃគិតគូរដល់គុណតម្លៃមិនមែនទីផ្សារ ដូចជាគុណតម្លៃផ្នែកសង្គម វប្បធម៌ សាសនា ជំនឿ និង បរិស្ថាន ក្នុងករណីដែលអាចអនុវត្តបាន។

១៨.៣ រដ្ឋគប្បីអភិវឌ្ឍគោលនយោបាយ និងច្បាប់ទាំងឡាយដែលលើកទឹកចិត្ត និង តម្រូវឱ្យមានតម្លាភាព ក្នុងការកំណត់តម្លៃសិទ្ធិកាន់កាប់។ ថ្លៃលក់ និង ព័ត៌មានពាក់ព័ន្ធផ្សេងទៀត គប្បីត្រូវបានកត់ត្រាទុក វិភាគ និង ផ្សព្វផ្សាយ ដើម្បីផ្តល់មូលដ្ឋានមួយសម្រាប់ការប៉ាន់ប្រមាណតម្លៃដ៏ត្រឹមត្រូវ និងអាចទុកចិត្តបាន។

១៨.៤ រដ្ឋ និងភាគីដទៃទៀតគប្បីអភិវឌ្ឍ និង ផ្សព្វផ្សាយបទដ្ឋានជាតិសម្រាប់ការកំណត់តម្លៃ សម្រាប់គោលបំណងផ្នែករដ្ឋាភិបាល ពាណិជ្ជកម្ម និង គោលបំណងផ្សេងទៀត។ បទដ្ឋានជាតិគប្បីមានសង្គតភាពទៅនឹងបទដ្ឋានអន្តរជាតិពាក់ព័ន្ធ។ ការបណ្តុះបណ្តាលបុគ្គលិក គប្បីដាក់បញ្ចូលវិធីសាស្ត្រ និង បទដ្ឋានអន្តរជាតិ។

១៨.៥ ទីភ្នាក់ងារអនុវត្តគប្បីផ្សព្វផ្សាយព័ត៌មាន និងការវិភាគស្តីពីការកំណត់តម្លៃរបស់ខ្លួន ជូនសាធារណជនស្របតាមបទដ្ឋានជាតិ។ រដ្ឋគប្បីខិតខំទប់ស្កាត់អំពើពុករលួយក្នុងការកំណត់តម្លៃ តាមរយៈតម្លាភាពនៃព័ត៌មាន និងវិធីសាស្ត្រ នៅក្នុងរដ្ឋបាលលើធនធានសាធារណៈ និងសំណង និង នៅក្នុងគណនី និងការផ្តល់ប្រាក់កម្ចីរបស់ក្រុមហ៊ុន។

## ១៩. ការយកពន្ធ

១៩.១ រដ្ឋមានអំណាចក្នុងការប្រមូលចំណូលតាមរយៈការយកពន្ធទាក់ទងនឹងសិទ្ធិកាន់កាប់ ដើម្បីរួមចំណែកដល់ការសម្រេចបាននូវគោលដៅទូលំទូលាយផ្នែកសង្គម សេដ្ឋកិច្ច និង បរិស្ថាន។ គោលដៅទាំងនេះអាចរួមមានការលើកទឹកចិត្តដល់ការវិនិយោគ ឬ ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតឡើង ដូចជាផលប៉ះពាល់ពីការជួញដូរ និង ការប្រមូលផ្តុំកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ផ្សេងទៀត។ ពន្ធគប្បីលើកទឹកចិត្តដល់ឥរិយាបថចង់បានផ្នែកសង្គម សេដ្ឋកិច្ច និង បរិស្ថាន ដូចជាការចុះបញ្ជីប្រតិបត្តិការ ឬ ការប្រកាសអំពីតម្លៃពេញសម្រាប់លក់ ។

១៩.២ រដ្ឋគប្បីខិតខំអភិវឌ្ឍគោលនយោបាយ ច្បាប់ និង ក្របខ័ណ្ឌស្ថាប័ន ដើម្បីធ្វើនិយតកម្មលើគ្រប់ទិដ្ឋភាពទាំងអស់ទាក់ទងនឹងការយកពន្ធលើសិទ្ធិកាន់កាប់។ គោលនយោបាយ និងច្បាប់ស្តីពីពន្ធគប្បីត្រូវបានប្រើប្រាស់ ក្នុងករណីសមស្រប ដើម្បីគាំទ្រហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាពសម្រាប់កម្រិតវិមជ្ឈការនៃរដ្ឋាភិបាល និង ការផ្តល់សេវា និង ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន។

១៩.៣ រដ្ឋគប្បីអនុវត្តការងារយកពន្ធប្រកបដោយប្រសិទ្ធភាព និង តម្លាភាព។ បុគ្គលិកនៃទីភ្នាក់ងារអនុវត្ត គប្បីទទួលការបណ្តុះបណ្តាល រាប់បញ្ចូលទាំងវិធីសាស្ត្រ។ ពន្ធគប្បីត្រូវផ្អែកលើតម្លៃសមស្រប។ ការប៉ាន់ប្រមាណតម្លៃ និង បរិមាណបង់ពន្ធ គប្បីត្រូវផ្សព្វផ្សាយជាសាធារណៈ។ រដ្ឋគប្បីផ្តល់ជូនអ្នកបង់ពន្ធនូវសិទ្ធិតវ៉ាប្រឆាំងនឹងការកំណត់តម្លៃ។ រដ្ឋគប្បីខិតខំទប់ស្កាត់អំពើពុករលួយក្នុងរដ្ឋបាលពន្ធ តាមរយៈការបង្កើនតម្លាភាពនៅក្នុងការប្រើប្រាស់តម្លៃប៉ាន់ប្រមាណដោយមិនលំអៀង។

## ២០. ការធ្វើនិយ័តកម្មផែនការរៀបចំដែនដី

២០.១ ការធ្វើនិយ័តកម្មផែនការរៀបចំដែនដី ធ្វើឱ្យប៉ះពាល់សិទ្ធិកាន់កាប់តាមរយៈការបង្កការរាំងស្ទះស្របច្បាប់ទៅលើការប្រើប្រាស់ដី។ រដ្ឋគប្បីធ្វើនិយ័តកម្មផែនការរៀបចំដែនដី និង តាមដានព្រមទាំងអនុវត្តតាមផែនការទាំងនោះ រាប់បញ្ចូលការអភិវឌ្ឍន៍ដែនដីប្រកបដោយតុល្យភាព និង និរន្តរភាព ក្នុងវិធីមួយដែលលើកកម្ពស់គោលបំណងនៃគោលការណ៍ណែនាំទាំងនេះ។ ក្នុងន័យនេះ ការធ្វើផែនការរៀបចំដែនដីគប្បីបន្សុី និង ធ្វើសុខដុមនីយកម្មគោលបំណងខុសៗគ្នានៃការប្រើប្រាស់ដី ជលផល និង ព្រៃឈើ។

២០.២ តាមរយៈការពិគ្រោះយោបល់ និងការចូលរួម រដ្ឋគប្បីអភិវឌ្ឍ និង ផ្សព្វផ្សាយគោលនយោបាយ និងច្បាប់ ស្តីពីការធ្វើនិយតកម្មផែនការរៀបចំដែនដី ដោយគិតគូរដល់យេនឌ័រ។ ក្នុងករណីសមស្រប ប្រព័ន្ធធ្វើផែនការក្នុងប្រព័ន្ធ គប្បីគិតគូរដល់វិធីសាស្ត្រនៃការធ្វើផែនការ និង ការអភិវឌ្ឍន៍ដែនដី ដែលត្រូវបានប្រើប្រាស់ដោយជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមាន

ប្រព័ន្ធកាន់កាប់បែបប្រពៃណី និងកិច្ចដំណើរការធ្វើសេចក្ដីសម្រេចចិត្តក្នុងសហគមន៍ទាំងនោះ។

២០.៣ រដ្ឋគប្បីធានាថា ការធ្វើនិយតកម្មផែនការរៀបចំដែនដី ត្រូវបានធ្វើតាមវិធីមួយដែលទទួលស្គាល់ទំនាក់ទំនងប្រទាក់ក្រឡាគ្នារវាង ដី ជលផល និង ព្រៃឈើ និង ការប្រើប្រាស់ធនធានទាំងនេះ រួមទាំងទិដ្ឋភាពយេនឌ័រនៃការប្រើប្រាស់។ រដ្ឋគប្បីខិតខំបន្សុំ និងកំណត់អាទិភាពផលប្រយោជន៍សាធារណៈ សហគមន៍ និង ឯកជន និង សម្រួលលក្ខខណ្ឌសម្រាប់ការប្រើប្រាស់ផ្សេងៗ ដូចជា ជនបទ កសិកម្ម គោចរ ទីប្រជុំជន និង បរិស្ថាន។ ការធ្វើផែនការរៀបចំដែនដី គប្បីពិចារណាអំពីសិទ្ធិកាន់កាប់ទាំងអស់ រួមទាំងសិទ្ធិត្រួតស៊ីគ្នា និងសិទ្ធិមិនជាប់លាប់។ គប្បីតម្រូវឱ្យមានការវាយតម្លៃហានិភ័យសមស្រប សម្រាប់ការធ្វើផែនការរៀបចំដែនដី។ គប្បីមានការសម្រប សម្រួលគ្នាចំពោះផែនការរៀបចំដែនដីថ្នាក់ជាតិ តំបន់ និង មូលដ្ឋាន ។

២០.៤ រដ្ឋគប្បីធានាឱ្យមានការចូលរួមសាធារណៈទូលំទូលាយក្នុងការរៀបចំសំណើធ្វើផែនការ និង ការពិនិត្យមើលសេចក្ដីព្រាងផែនការរៀបចំដែនដី ដើម្បីធានាឱ្យបានថាអាទិភាព និងផលប្រយោជន៍របស់សហគមន៍ រួមមានជនជាតិដើមភាគតិច និង សហគមន៍ផលិតស្បៀងអាហារ ត្រូវបានឆ្លុះបញ្ចាំង។ ក្នុងករណីចាំបាច់ សហគមន៍គប្បីទទួលបានការគាំទ្រក្នុងកិច្ចដំណើរការរៀបចំផែនការ។ ទីភ្នាក់ងារអនុវត្ត គប្បីផ្សព្វផ្សាយថាតើធាតុចូលសាធារណៈពីការចូលរួម ត្រូវបានឆ្លុះបញ្ចាំងយ៉ាងដូចម្ដេចក្នុងផែនការរៀបចំដែនដីស្ថាពរ។ រដ្ឋគប្បីខិតខំទប់ស្កាត់អំពើពុករលួយដោយបង្កើតវិធានការការពារប្រឆាំងនឹងការប្រើប្រាស់មិនសមស្រប នូវអំណាចធ្វើផែនការរៀបចំដែនដី ជាពិសេស ទាក់ទងនឹងការផ្លាស់ប្ដូរឲ្យមានការប្រើប្រាស់ដោយនិយ័តកម្ម។ ទីភ្នាក់ងារអនុវត្ត គប្បីរាយការណ៍អំពីលទ្ធផលនៃការតាមដានលើអនុលោមភាព។

២០.៥ ការធ្វើផែនការរៀបចំដែនដី គប្បីគិតគូរឱ្យបានត្រឹមត្រូវដល់ភាពចាំបាច់ក្នុងការជំរុញការគ្រប់គ្រងប្រកបដោយនិរន្តរភាពនិងពិពិធភាពដី ជលផល និង ព្រៃឈើ រួមមានអភិក្រមអេកូឡូស៊ីកសិកម្ម ព្រមទាំងពិពិធភាពប្រកបដោយនិរន្តរភាព និង ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ និង សន្តិសុខស្បៀង។

## ២១. ដំណោះស្រាយវិវាទលើសិទ្ធិកាន់កាប់

២១.១ រដ្ឋគប្បីផ្ដល់លទ្ធភាពទទួលបាន តាមរយៈស្ថាប័នតុលាការ និងរដ្ឋបាលមិនលំអៀង នូវមធ្យោបាយទាន់ពេល មានតម្លៃសមរម្យ និង ប្រកបដោយប្រសិទ្ធភាពសម្រាប់ការដោះស្រាយជម្លោះលើសិទ្ធិកាន់កាប់ រួមទាំងមធ្យោបាយផ្សេងៗសម្រាប់ដោះស្រាយវិវាទបែបនេះ និង គប្បីផ្ដល់ដំណោះស្រាយកែតម្រូវប្រកបដោយប្រសិទ្ធភាព និង សិទ្ធិប្ដឹងឧទ្ធរណ៍។ ដំណោះស្រាយកែតម្រូវបែបនេះ គប្បីត្រូវប្រតិបត្តិជាបន្ទាន់។ រដ្ឋគប្បីផ្ដល់ជូនប្រជាពលរដ្ឋគ្រប់រូបនូវយន្តការនានាដើម្បីជៀសវាង ឬ ដោះស្រាយសក្ដានុពលជម្លោះនៅដំណាក់កាលបឋម ទាំងនៅក្នុង ឬ នៅក្រៅ

ទីភ្នាក់ងារអនុវត្ត ។ សេវាដោះស្រាយជម្លោះ គប្បីមានលក្ខណៈអាចប្រើប្រាស់បានសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ពោលគឺ ទាំងស្ត្រី និងបុរស ទាក់ទិននឹងទីកន្លែង ភាសា និង នីតិវិធី។

២១.២ រដ្ឋអាចពិចារណាដាក់ឱ្យប្រើប្រាស់នូវសាលាក្តី ឬ ស្ថាប័នឯកទេសដែលដោះស្រាយតែជម្លោះលើសិទ្ធិកាន់កាប់ និង បង្កើតតំណែងជំនាញនៅក្នុងអាជ្ញាធរតុលាការសម្រាប់ដោះស្រាយបញ្ហាបច្ចេកទេស។ រដ្ឋក៏អាចពិចារណាផងដែរអំពីការបង្កើតសាលាក្តីពិសេស សម្រាប់ដោះស្រាយជម្លោះលើការធ្វើផែនការរៀបចំដែនដីក្រោមការគ្រប់គ្រងពីនិយតកម្ម ការវាស់ព្រំដី និង ការកំណត់តម្លៃ។

២១.៣ រដ្ឋគប្បីពង្រឹង និងអភិវឌ្ឍទម្រង់ផ្សេងៗនៃដំណោះស្រាយជម្លោះ ជាពិសេស នៅកម្រិតមូលដ្ឋាន។ ក្នុងករណីដែលមានទម្រង់តាមទំនៀមទម្លាប់ ឬ ទម្រង់មានស្រាប់ផ្សេងទៀតនៃការដោះស្រាយវិវាទ ទម្រង់ដោះស្រាយវិវាទទាំងនេះគប្បីផ្តល់មធ្យោបាយប្រកបដោយយុត្តិធម៌ អាចទុកចិត្តបាន អាចរកប្រើប្រាស់បាន និង ដោយមិនមានការរើសអើង សម្រាប់ដោះស្រាយជម្លោះលើសិទ្ធិកាន់កាប់។

២១.៤ រដ្ឋអាចពិចារណាប្រើប្រាស់ទីភ្នាក់ងារអនុវត្ត ដើម្បីដោះស្រាយជម្លោះនៅក្នុងជំនាញបច្ចេកទេសរបស់ខ្លួន ដូចជា ស្ថាប័នដែលទទួលខុសត្រូវលើការវាស់ព្រំដីជាដើម ដើម្បីដោះស្រាយជម្លោះព្រំដីរវាងក្បាលដី នៅក្នុងបរិបទជាតិ។ សេចក្តីសម្រេចគប្បីចេញជាលាយល័ក្ខណ៍អក្សរ និង ផ្អែកលើការថ្លឹងថ្លែងមិនលំអៀង និង គប្បីមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅកាន់អាជ្ញាធរតុលាការ។

២១.៥ រដ្ឋគប្បីខិតខំទប់ស្កាត់អំពើពុករលួយនៅក្នុងកិច្ចដំណើរការដោះស្រាយវិវាទ។

២១.៦ នៅក្នុងការផ្តល់យន្តការដោះស្រាយវិវាទ រដ្ឋគប្បីខិតខំផ្តល់ជំនួយស្របច្បាប់ជូនប្រជាពលរដ្ឋងាយរងគ្រោះ និង ប្រជាពលរដ្ឋដែលគេមើលរំលង ដើម្បីធានាឱ្យបាននូវលទ្ធភាពទទួលបានយុត្តិធម៌ប្រកបដោយសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋទាំងអស់ ដោយគ្មានការរើសអើង។ អាជ្ញាធរតុលាការ និងស្ថាប័នផ្សេងទៀត គប្បីធានាឱ្យបានថាបុគ្គលិករបស់ខ្លួនមានជំនាញ និងសមត្ថភាពចាំបាច់សម្រាប់ផ្តល់សេវាប្រភេទនេះ។

## ២២. បញ្ហាឆ្លងដែន

២២.១ រដ្ឋគប្បីសហការគ្នា ក្នុងក្របខ័ណ្ឌនៃយន្តការសមស្រប និង ដោយមានការចូលរួមរបស់ភាគីរងផលប៉ះពាល់ ក្នុងការដោះស្រាយបញ្ហាកាន់កាប់ទាំងឡាយដែលទាក់ទងទៅនឹងដី ជលផល និង ព្រៃឈើ ដែលឆ្លងកាត់ព្រំដែនជាតិ។ រដ្ឋគប្បីធានាថារាល់សកម្មភាពទាំងអស់មានសង្គតភាព ទៅនឹង

កាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។ នៅក្នុងរដ្ឋទាំងឡាយ ដែលមានបញ្ហាឆ្លងដែនទាក់ទិននឹងសិទ្ធិកាន់កាប់កើតឡើង ភាគីទាំងឡាយគប្បីសហការគ្នាដើម្បីការពារសិទ្ធិកាន់កាប់ ជីវភាព និង សន្តិសុខស្បៀងរបស់ប្រជាជនចំណាកស្រុកដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន។

២២.២ រដ្ឋ និងភាគីដទៃទៀត គប្បីរួមចំណែកដល់ការយល់ដឹងអំពីបញ្ហាកាន់កាប់ឆ្លងដែនទាំងឡាយដែលប៉ះពាល់ដល់សហគមន៍ ដូចជាដីវាលធំ ឬ ផ្លូវធ្វើចំណាកស្រុកតាមរដូវរបស់អ្នកចិញ្ចឹមសត្វ និងតំបន់នេសាទរបស់អ្នកនេសាទខ្នាតតូច ដែលស្ថិតនៅឆ្លងព្រំដែនអន្តរជាតិ។

២២.៣ ក្នុងករណីសមស្រប រដ្ឋគប្បីធ្វើសុខដុមនីយកម្មបទដ្ឋានច្បាប់នៃអភិបាលកិច្ចលើការកាន់កាប់ស្របតាមកាតព្វកិច្ចជាធរមានអនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតូបករណ៍តំបន់ និងអន្តរជាតិជាធរមាន។ ក្នុងករណីសមស្របចំណុចនេះគប្បីសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធថ្នាក់តំបន់ និង ជាមួយភាគីរងផលប៉ះពាល់។ យោងតាមភាពសមស្រប ដោយមានការចូលរួមពីភាគីរងផលប៉ះពាល់ រដ្ឋគប្បីអភិវឌ្ឍ ឬ ពង្រឹងវិធានការអន្តរជាតិដែលមានស្រាប់ ដើម្បីគ្រប់គ្រងសិទ្ធិកាន់កាប់ឆ្លងព្រំដែនអន្តរជាតិ។ ក្នុងករណីសមស្រប រដ្ឋគប្បីសម្របសម្រួលជាមួយស្ថាប័នតំបន់ពាក់ព័ន្ធ។ ចំណុចនេះគប្បីត្រូវធ្វើជាពិសេស ដើម្បីការពារជីវភាព និង សិទ្ធិរបស់ជនទាំងឡាយដែលរងផលប៉ះពាល់ ស្របតាមកថាខណ្ឌ ៤.៨ ស្បិទ្ធិស្តីពីគ្រប់គ្នាដែលប៉ះពាល់។

៥

# ជំពូកទី ៦

## ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និង គ្រោះបន្ទាន់

ជំពូកនេះថែងពីអភិបាលកិច្ចលើការកាន់កាប់ដី ជលផល និង ព្រៃឈើ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយធម្មជាតិ និង វិវាទ។

៦

### ២៣. ការប្រែប្រួលអាកាសធាតុ

២៣.១ រដ្ឋគប្បីធានាឱ្យបានថាសិទ្ធិកាន់កាប់ស្របច្បាប់ចំពោះដី ជលផល និង ព្រៃឈើ របស់បុគ្គល សហគមន៍ ឬ ប្រជាពលរដ្ឋទាំងអស់ដែលទំនងនឹងទទួលរងផលប៉ះពាល់ ដោយសង្កត់ធ្ងន់លើកសិករ អ្នកផលិតស្បៀងខ្នាតតូច និង ប្រជាពលរដ្ឋងាយរងគ្រោះ និង ប្រជាពលរដ្ឋដែលត្រូវគេមើលរំលង ត្រូវបានគោរព និងការពារដោយច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និង សកម្មភាពទាំងឡាយ សំដៅទប់ស្កាត់ និង ឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ស្របតាមកាតព្វកិច្ចរបស់រដ្ឋ តាមដែលអាចអនុវត្តបាន ទាក់ទងទៅនឹងកិច្ចព្រមព្រៀងពាក់ព័ន្ធស្តីពីក្របខ័ណ្ឌនៃការប្រែប្រួលអាកាសធាតុ។

២៣.២ ក្នុងករណីសមស្រប រដ្ឋគប្បីខិតខំរៀបចំ និង អនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពនានា ដោយមានការពិគ្រោះយោបល់ និង មានការចូលរួមពីប្រជាពលរដ្ឋគ្រប់រូប ពោលគឺស្ត្រី និងបុរស ដែលអាចត្រូវជម្លៀសចេញដោយសារការប្រែប្រួលអាកាសធាតុ។ ការផ្តល់ជម្រើសដី ជលផល ព្រៃឈើ និង ជីវភាពជូនជនជម្លៀស គប្បីមិនធ្វើឱ្យហានិភ័យដល់ជីវភាពរបស់អ្នកដទៃឡើយ។ រដ្ឋក៏អាចពិចារណាផ្តល់ជំនួយពិសេសផងដែរជូនដល់កោះតូចៗ និង រដ្ឋកំពុងអភិវឌ្ឍផ្សេងទៀត។

២៣.៣ រដ្ឋគប្បីសម្រួលការចូលរួម ស្របតាមគោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ របស់បុគ្គល សហគមន៍ ឬ ប្រជាពលរដ្ឋទាំងអស់ដែលទំនងនឹងត្រូវរងផលប៉ះពាល់ ដោយសង្កត់ធ្ងន់លើកសិករ អ្នកផលិតស្បៀងខ្នាតតូច និង ប្រជាពលរដ្ឋងាយរងគ្រោះ និង ប្រជាពលរដ្ឋដែលត្រូវគេមើលរំលង ដែលមានសិទ្ធិកាន់កាប់ស្របច្បាប់ ក្នុងការចរចារ និង ការអនុវត្តន៍កម្មវិធីកាត់បន្ថយផលប៉ះពាល់ និង កម្មវិធីបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

## ២៤. គ្រោះមហន្តរាយធម្មជាតិ

២៤.១ គ្រប់ភាគីទាំងអស់ គប្បីធានាថាទិដ្ឋភាពកាន់កាប់ដី ជលផល និង ព្រៃឈើ ត្រូវបានដោះស្រាយនៅពេលទប់ស្កាត់ និងត្រៀមលក្ខណៈសម្រាប់គ្រោះមហន្តរាយធម្មជាតិ និង ក្នុងការឆ្លើយតបរបស់គេចំពោះគ្រោះមហន្តរាយធម្មជាតិទាំងនេះ។ ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការកាន់កាប់ រួមទាំងការធ្វើផែនការរៀបចំដែនដី គប្បីត្រូវបានរៀបចំ ដើម្បីជៀសវាង ឬ កាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់ជាសក្តានុពលនៃគ្រោះមហន្តរាយធម្មជាតិ។

២៤.២ រដ្ឋគប្បីធានាឱ្យបានថា រាល់សកម្មភាពទាំងអស់មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្តេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។ គ្រប់ភាគីទាំងអស់គប្បីធ្វើសកម្មភាព ដោយគិតគូរដល់គោលការណ៍អន្តរជាតិពាក់ព័ន្ធ រួមមាន គោលការណ៍អង្គការសហប្រជាជាតិ ស្តីពីលំនៅឋាន និង បដិទានអចលនទ្រព្យសម្រាប់ជនភៀសខ្លួន និង ជនជម្លៀស ("គោលការណ៍ពីញ៉េរ៉ូ (Pinheiro)") និង ធម្មនុញ្ញមនុស្សធម៌ ព្រមទាំង បទដ្ឋានអប្បបរមាក្នុងចម្លើយតបទៅនឹងគ្រោះមហន្តរាយ ទៅតាមភាពសមស្រប។

២៤.៣ រដ្ឋគប្បីដោះស្រាយបញ្ហាការកាន់កាប់ក្នុងកម្មវិធីទប់ស្កាត់គ្រោះមហន្តរាយ និង កម្មវិធីត្រៀមលក្ខណៈសម្រាប់គ្រោះមហន្តរាយ។ ព័ត៌មានស្តីពីសិទ្ធិកាន់កាប់ស្របច្បាប់ គប្បីត្រូវបានប្រមូលសម្រាប់តំបន់ទាំងឡាយដែលអាចរងផលប៉ះពាល់ តាមរយៈកិច្ចដំណើរការមួយដែលមានសង្គតភាពទៅនឹងគោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ។

៦

ប្រព័ន្ធសម្រាប់ចុះបញ្ជីសិទ្ធិកាន់កាប់ស្របច្បាប់ គប្បីមានលក្ខណៈធន់នឹងគ្រោះមហន្តរាយធម្មជាតិ រួមទាំងការទុកដាក់ឯកសារនៅក្រៅកន្លែងចុះបញ្ជី ដើម្បីអនុញ្ញាតឱ្យសាមីជនមានសិទ្ធិអាចបង្ហាញភស្តុតាងនៃសិទ្ធិរបស់ពួកគេ និង បែងចែកឡើងវិញនូវក្បាលដីរបស់ពួកគេ ព្រមទាំង ឯកតាដីដទៃទៀត។ រដ្ឋគប្បីខិតខំកំណត់កន្លែងទាំងឡាយសម្រាប់ការតាំងលំនៅបណ្ដោះអាសន្នរបស់ប្រជាពលរដ្ឋ ដែលអាចត្រូវជម្លៀសដោយគ្រោះមហន្តរាយធម្មជាតិ ហើយគប្បីបង្កើតវិធាន សម្រាប់ផ្ដល់សុវត្ថិភាពកាន់កាប់នៅតាមតំបន់ទាំងនេះ។

២៤.៤ រដ្ឋ និង ភាគីដទៃទៀត គប្បីដោះស្រាយការកាន់កាប់ក្នុងដំណាក់កាលឆ្លើយតបទៅនឹងគ្រោះបន្ទាន់។ ជម្រើសផ្ដល់ដី ជលផល ព្រៃឈើ និង ជីវភាពជូនជនជម្លៀស មិនគប្បីធ្វើឱ្យខូចខាតដល់សិទ្ធិ និងជីវភាពរបស់អ្នកដទៃឡើយ។ សិទ្ធិកាន់កាប់ស្របច្បាប់របស់ជនជម្លៀស ក៏គប្បីត្រូវបានទទួលស្គាល់ គោរព និង ការពារផងដែរ។ ព័ត៌មានស្ដីពីសិទ្ធិកាន់កាប់ និង ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត គប្បីត្រូវផ្សព្វផ្សាយជូនដល់ជនរងផលប៉ះពាល់ទាំងអស់។

២៤.៥ រដ្ឋ និងភាគីដទៃទៀត គប្បីដោះស្រាយការកាន់កាប់ក្នុងដំណាក់កាលសាងសង់ជាថ្មី។ ជនទាំងឡាយដែលត្រូវជម្លៀសជាបណ្ដោះអាសន្ន គប្បីត្រូវបានជួយដោយស្ម័គ្រចិត្ត ប្រកបដោយសុវត្ថិភាព និង សេចក្ដីថ្លៃថ្នូរ ក្នុងការវិលត្រឡប់ទៅកន្លែងដើមរបស់ពួកគេវិញ។ គប្បីផ្ដល់ជូននូវមធ្យោបាយដោះស្រាយជម្លោះលើសិទ្ធិកាន់កាប់ ។ ក្នុងករណីដែលព្រំនៃក្បាលដី និង ឯកតាដីផ្សេងទៀតត្រូវកំណត់ឡើងវិញ ចំណុចនេះគប្បីអនុវត្តស្របតាមគោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ។ ក្នុងករណីដែលប្រជាពលរដ្ឋមិនអាចវិលត្រឡប់ទៅកន្លែងដើមរបស់ខ្លួនវិញបាន ពួកគេគប្បីតាំងលំនៅជាអចិន្ត្រៃយ៍នៅកន្លែងផ្សេង។

## ២៥. វិវាទទាក់ទិននឹងការកាន់កាប់ដី ជលផល និង ព្រៃឈើ

២៥.១ គ្រប់ភាគីទាំងអស់គប្បីចាត់វិធានការដើម្បីទប់ស្កាត់ និង លុបបំបាត់បញ្ហានៃការកាន់កាប់ដី ជលផល និង ព្រៃឈើ ដែលជាមូលហេតុនៃវិវាទ និង គប្បីធានាថាទិដ្ឋភាពនានានៃការកាន់កាប់ត្រូវបានដោះស្រាយមុនពេល ក្នុងអំឡុងពេល និង ក្រោយពេលមានវិវាទ រួមទាំងក្នុងស្ថានភាពនៃការកាន់កាប់ ដែលនៅក្នុងនោះ ភាគីទាំងអស់គប្បីធ្វើសកម្មភាពស្របតាមច្បាប់មនុស្សធម៌អន្តរជាតិជាធរមាន។

២៥.២ រដ្ឋគប្បីធានាថា រាល់សកម្មភាពទាំងអស់មានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ដោយគោរពតាមការប្ដេជ្ញាដោយស្ម័គ្រចិត្ត ស្របតាមលិខិតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន រួមមាន លិខិតុបករណ៍នៃ

អនុសញ្ញាទាក់ទិននឹងឋានៈនៃជនភៀសខ្លួន និង ពិធីសារនៃអនុសញ្ញានេះ ព្រមទាំងគោលការណ៍អង្គការសហប្រជាជាតិស្តីពីលំនៅឋាន និង បដិទានអចលនទ្រព្យសម្រាប់ជនភៀសខ្លួន និង ជនជម្លៀស ("គោលការណ៍ពីញ៉េរ៉ូ (Pinheiro)") ទៅតាមភាពសមស្រប ។ ក្នុងអំឡុងពេល និង ក្រោយពេលមានវិវាទ រដ្ឋគប្បីគោរពច្បាប់មនុស្សធម៌អន្តរជាតិជាធរមាន ទាក់ទិននឹងសិទ្ធិកាន់កាប់ស្របច្បាប់។

២៥.៣ ដើម្បីជៀសវាងកុំឱ្យបញ្ហាកាន់កាប់នាំឱ្យឈានទៅដល់វិវាទ គ្រប់ភាគីទាំងអស់គប្បីចាត់វិធានការដើម្បីដោះស្រាយបញ្ហាទាំងនេះដោយសន្តិវិធី។ រដ្ឋគប្បីកែសម្រួលគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនានា ដើម្បីលុបបំបាត់ការរើសអើង និង កត្តាផ្សេងទៀតដែលអាចជាមូលហេតុនៃវិវាទ។ ក្នុងករណីសមស្រប រដ្ឋអាចពិចារណាប្រើប្រាស់យន្តការទំនៀមទម្លាប់ និង យន្តការផ្សេងទៀតក្នុងមូលដ្ឋាន ដែលអាចផ្តល់វិធីប្រកបដោយយុត្តិធម៌ អាចទុកចិត្តបាន គិតគូរដល់យេនឌ័រ អាចរកប្រើប្រាស់បាន និង មិនរើសអើង នៃការដោះស្រាយជាប្រញាប់នូវជម្លោះលើសិទ្ធិកាន់កាប់ដីជលផល និង ព្រៃឈើ។

២៥.៤ នៅពេលដែលមានវិវាទកើតឡើង រដ្ឋ និងភាគីដទៃទៀតគប្បីខិតខំគោរព និងការពារសិទ្ធិកាន់កាប់ស្របច្បាប់ជាធរមាន និង ធានាថាសិទ្ធិកាន់កាប់ទាំងនេះមិនត្រូវបានរំលត់ដោយភាគីដទៃឡើយ។ ស្របតាមកាតព្វកិច្ចជាធរមាន អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធ រដ្ឋមិនគប្បីទទួលស្គាល់សិទ្ធិកាន់កាប់ដី ជលផល និង ព្រៃឈើដែលត្រូវបានធ្វើលទ្ធកម្ម នៅក្នុងដែនដីរបស់ខ្លួន តាមរយៈមធ្យោបាយបង្ខំ និង/ឬ ហិង្សាឡើយ។ ជនភៀសខ្លួន និងជនជម្លៀស និង អ្នកដទៃទៀតដែលរងផលប៉ះពាល់ដោយវិវាទ គប្បីមានលំនៅឋានក្នុងស្ថានភាពមានសុវត្ថិភាព តាមវិធីនានាដែលការពារសិទ្ធិកាន់កាប់របស់សហគមន៍ជាម្ចាស់។ ការរំលោភលើសិទ្ធិកាន់កាប់ គប្បីត្រូវចងក្រងជាឯកសារ និងក្នុងករណីសមស្រប ត្រូវធ្វើការកែតម្រូវនៅពេលក្រោយ។ ឯកសារផ្លូវការនៃសិទ្ធិកាន់កាប់ គប្បីត្រូវបានការពារប្រឆាំងនឹងការបំផ្លាញ និង ចោរកម្ម សំដៅផ្តល់ភស្តុតាងសម្រាប់កិច្ចដំណើរការនៅពេលក្រោយ ដើម្បីដោះស្រាយការរំលោភបំពានទាំងនេះ និង ដើម្បីសម្រួលដល់សកម្មភាពកែតម្រូវនានាដែលអាចមាន ហើយនៅតំបន់ដែលមិនមានឯកសារបែបនេះ សិទ្ធិកាន់កាប់មានស្រាប់គប្បីត្រូវបានចងក្រងជាឯកសារឱ្យបានប្រសើរបំផុតតាមដែលអាចធ្វើបាន ដោយគិតគូរដល់យេនឌ័រ រួមមានតាមរយៈការផ្តល់ប្រវត្តិ និងសក្ខីកម្មផ្ទាល់មាត់។ សិទ្ធិកាន់កាប់ស្របច្បាប់របស់ជនភៀសខ្លួន និងជនជម្លៀស គប្បីត្រូវបានទទួលស្គាល់ គោរព និងការពារ។ ព័ត៌មានស្តីពីសិទ្ធិកាន់កាប់ និង ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត គប្បីត្រូវផ្សព្វផ្សាយជូនដល់ជនរងផលប៉ះពាល់ទាំងអស់។

២៥.៥ ក្នុងស្ថានភាពមានវិវាទ នៅពេលដែលអាចធ្វើបាន ឬ នៅពេលដែលវិវាទរលត់ រដ្ឋ និង ភាគីដទៃទៀត គប្បីធានាថាបញ្ហាកាន់កាប់ត្រូវបានដោះស្រាយតាមវិធីដែលរួមចំណែកដល់សមភាពយេនឌ័រ និង គាំទ្រដល់ដំណោះស្រាយជាប់លាប់ សម្រាប់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់។

ក្នុងករណីដែលបដិទានអាចធ្វើបាន និង យោងតាមភាពសមស្រប ដោយមានជំនួយពីឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) និង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ជនភៀសខ្លួន និងជនជម្លៀស គប្បីត្រូវបានជួយដោយស្ម័គ្រចិត្ត ប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ក្នុងការវិលត្រឡប់ទៅកន្លែងដើមរបស់ពួកគេវិញ ស្របតាមបទដ្ឋានអន្តរជាតិជាធរមាន។ នីតិវិធីសម្រាប់បដិទាន ការស្តារនីតិសម្បទា និង ការជួសជុល គប្បីមានលក្ខណៈមិនរើសអើង គិតគូរដល់យេនឌ័រ និង ត្រូវបានផ្សព្វផ្សាយទូលំទូលាយ ហើយការទាមទារបដិទានគប្បីត្រូវបានពិនិត្យដោះស្រាយជាបន្ទាន់។ នីតិវិធីសម្រាប់បដិទាននៃសិទ្ធិកាន់កាប់របស់ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី គប្បីផ្តល់ជូននូវការប្រើប្រាស់ប្រភពព័ត៌មានបែបប្រពៃណី។

២៥.៦ ក្នុងករណីដែលបដិទានមិនអាចធ្វើបាន ការផ្តល់លទ្ធភាពទទួលបានដី ជលផល និង ព្រៃឈើ និងជីវភាពផ្សេង ប្រកបដោយសុវត្ថិភាព សម្រាប់ជនភៀសខ្លួន និងជនជម្លៀស គប្បីត្រូវបានចរចារជាមួយសហគមន៍ជាម្ចាស់ និង ភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីធានាថាការតាំងលំនៅថ្មីមិនធ្វើឱ្យមានហានិភ័យ ដល់ជីវភាពរបស់អ្នកដទៃ។ ក្នុងករណីដែលអាចធ្វើបាន នីតិវិធីពិសេសគប្បីផ្តល់ជូនជនងាយរងគ្រោះ រួមមានស្ត្រីមេម៉ាយ និងកុមារកំព្រា នូវលទ្ធភាពទទួលបានដី ជលផល និងព្រៃឈើ ប្រកបដោយសុវត្ថិភាព។

២៥.៧ ក្នុងករណីសមស្រប គោលនយោបាយ និងច្បាប់ គប្បីកែសម្រួលដើម្បីដោះស្រាយការរើសអើងដែលមានកន្លងមក ក៏ដូចជាការរើសអើងដែលកើតឡើងក្នុងអំឡុងពេលមានវិវាទ។ ក្នុងករណីសមស្រប ឬ ចាំបាច់ ស្ថាប័នពាក់ព័ន្ធគប្បីបង្កើតឡើងវិញ ដើម្បីផ្តល់សេវាចាំបាច់សម្រាប់អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់។

៦

# ជំពូកទី ៧

## ការជំរុញ ការអនុវត្តន៍ ការតាមដាន និង ការវាយតម្លៃ

២៦.១ អនុលោមតាមលក្ខណៈស្ម័គ្រចិត្តនៃគោលការណ៍ណែនាំទាំងនេះ រដ្ឋមានការទទួលខុសត្រូវលើការអនុវត្តន៍ការតាមដាន និង ការវាយតម្លៃរបស់ខ្លួន។

២៦.២ រដ្ឋត្រូវបានលើកទឹកចិត្តឱ្យបង្កើតវេទិកា និងក្របខ័ណ្ឌពហុភាគីពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន ជាតិ និងតំបន់ ឬ ប្រើប្រាស់វេទិកា និងក្របខ័ណ្ឌមានស្រាប់ដើម្បីសហការលើការអនុវត្តន៍គោលការណ៍ណែនាំទាំងនេះ សំដៅតាមដាន និង វាយតម្លៃការអនុវត្តន៍នៅក្នុងដែនដីរបស់ខ្លួន និង ដើម្បីវាយតម្លៃផលប៉ះពាល់លើការកែលម្អអភិបាលកិច្ចលើការកាន់កាប់ដី ជលផល និង ព្រៃឈើ និងលើការកែលម្អសន្តិសុខស្បៀង និង ការសម្រេចបានជាលំដាប់នូវសិទ្ធិមានស្បៀងអាហារគ្រប់គ្រាន់ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ និង ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ កិច្ចដំណើរការនេះ គប្បីមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានការចូលរួម គិតគូរដល់យេនឌ័រ អាចអនុវត្តបាន មានប្រសិទ្ធភាពចំណាយ និង មានចីរភាព។ ក្នុងការអនុវត្តន៍ភារកិច្ចទាំងនេះ រដ្ឋអាចសុំការជួយគាំទ្រផ្នែកបច្ចេកទេសពីស្ថាប័នតំបន់ និង អន្តរជាតិ។

២៦.៣ ដៃគូអភិវឌ្ឍន៍ ស្ថាប័នឯកទេសនៃអង្គការសហប្រជាជាតិ និង អង្គការតំបន់ ត្រូវបានលើកទឹកចិត្តឱ្យជួយគាំទ្រដល់កិច្ចប្រឹងប្រែងដោយស្ម័គ្រចិត្តរបស់រដ្ឋក្នុងការអនុវត្តគោលការណ៍ណែនាំទាំងនេះ រួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍ។ ការគាំទ្រនេះ អាចរួមមានកិច្ចសហប្រតិបត្តិការបច្ចេកទេស ជំនួយហិរញ្ញវត្ថុ ការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន ការចែករំលែកចំណេះដឹង និង ការផ្លាស់ប្តូរបទពិសោធន៍គ្នា ជំនួយក្នុងការអភិវឌ្ឍគោលនយោបាយជាតិស្តីពីការកាន់កាប់ និង ការផ្ទេរបច្ចេកវិទ្យា។

៧

២៦.៤ គណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក គប្បីជាវេទិកាពិភពលោក ដែលតួអង្គពាក់ព័ន្ធទាំងអស់ រៀនសូត្រពីបទពិសោធន៍គ្នាទៅវិញទៅមក និង វាយតម្លៃទៅលើវឌ្ឍភាពឆ្ពោះទៅកាន់ការអនុវត្តន៍គោលការណ៍ណែនាំទាំងនេះ ព្រមទាំងវាយតម្លៃទៅលើភាពសមស្រប ប្រសិទ្ធភាព និង ផលប៉ះពាល់នៃគោលការណ៍ណែនាំទាំងនេះផងដែរ។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក ដោយមានកិច្ចសហការជាមួយក្រុមប្រឹក្សាយោបល់ គប្បីរាយការណ៍ជូនគណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក អំពីវឌ្ឍនភាពនៃការអនុវត្តន៍គោលការណ៍ណែនាំទាំងនេះ ព្រមទាំងវាយតម្លៃទៅលើផលប៉ះពាល់ និង ការរួមចំណែកនៃគោលការណ៍ណែនាំទាំងនេះ ចំពោះការកែលម្អអភិបាលកិច្ចលើការកាន់កាប់។ របាយការណ៍ទាំងនេះ គប្បីមានលក្ខណៈជាសកល និង រួមមានជាអាទិ៍ បទពិសោធន៍តំបន់ ការអនុវត្តល្អប្រសើរ និង មេរៀនដែលបានរៀនសូត្រ។

២៦.៥ គ្រប់ភាគីទាំងអស់ រួមទាំងអង្គការសង្គមស៊ីវិល និង វិស័យឯកជន ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់កិច្ចខិតខំសហការគ្នា ដើម្បីជំរុញ និងអនុវត្តគោលការណ៍ណែនាំទាំងនេះ ស្របតាមអាទិភាព និងបរិបទជាតិ។ គ្រប់ភាគីទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យផ្សព្វផ្សាយព័ត៌មានអំពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ ដើម្បីកែលម្អការអនុវត្តន៍។

អភិបាលកិច្ច នៃការកាន់កាប់

គោលការណ៍ណែនាំនេះ គឺជាឧបករណ៍គ្រប់គ្រងជ្រោយកម្រិតសកលដំបូងអំពីការ កាន់កាប់ និង រដ្ឋបាលលើការកាន់កាប់ ដែលត្រូវរៀបចំតាមរយៈការចរចារអន្តររដ្ឋាភិបាល។

គោលការណ៍ណែនាំនេះ ដាក់ចេញនូវគោលការណ៍ និង បទដ្ឋានដែលត្រូវបានទទួលយកជាអន្តរជាតិ នៃការអនុវត្តន៍ប្រកបដោយការទទួលខុសត្រូវសម្រាប់ការប្រើប្រាស់ និងការត្រួតត្រាដី ជលផល និង ព្រៃឈើ។ គោលការណ៍ណែនាំនេះផ្តល់ការណែនាំ សម្រាប់កែលម្អក្របខ័ណ្ឌ គោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និង ក្របខ័ណ្ឌស្ថាប័ន ដែលធ្វើនិយ័តកម្មលើសិទ្ធិកាន់កាប់ ដើម្បីលើកស្ទួយតម្លាភាព និង រដ្ឋបាលនៃប្រព័ន្ធកាន់កាប់ និង ដើម្បីពង្រឹងសមត្ថភាព និង កិច្ចប្រតិបត្តិការនៃស្ថាប័នសាធារណៈ វិស័យឯកជន សហគ្រាស អង្គការសង្គមស៊ីវិល និង ប្រជាជន ដែលចាប់អារម្មណ៍លើការកាន់កាប់ និង អភិបាលកិច្ចលើការកាន់កាប់។

គោលការណ៍ណែនាំនេះ ដាក់អភិបាលកិច្ចលើការកាន់កាប់នៅក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ និង មានឆន្ទៈរួមចំណែកដល់ការសម្រេចបានជាលំដាប់នូវសិទ្ធិមានស្បៀងអាហារគ្រប់គ្រាន់ ការលុបបំបាត់ភាពក្រីក្រ កិច្ចការពារបរិស្ថាន និង ការអភិវឌ្ឍន៍សង្គម និង សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

www.fao.org/nr/tenure

**គាំទ្រថវិកាដោយ**

**សហការបោះពុម្ពផ្សាយជាលើកទី២ដោយ**

សហភាពអឺរ៉ុប

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

actionaid

ISBN 978-92-5-107277-6

I2801E/1/06.12